សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង ឆ្នាំ២០២០-២០៣០

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ថុន ស្រីពេជ្រ**

**ក. ទេព កុលនីកា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង ឆ្នាំ២០២០-២០៣០

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


| ស្រាវជ្រាវដោយ | ណែនាំដោយ |
|---|---|
| និស្សិតឈ្មោះ **ក. ថុន ស្រីពេជ្រ** | សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា** |
| **ក. ទេព កុលនីកា** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន ២០១៩ |
| ជំនាន់ទី២៣ | ឆ្នាំសរសេរសារណា ២០២៣ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ចុន ស្រីពេជ្រ** និងនាងខ្ញុំឈ្មោះ **ទេព កុលនីកា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២២-២០២៣។

ជាបឋមនាងខ្ញុំទាំងពីរនាក់ មានកិត្តិយសសូមសេចក្តីអនុញ្ញាត ដើម្បីបានសម្តែងនូវគារវកិច្ចគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានប្រឹងប្រែងប្រកបដោយព្រហ្មវិហារធម៌ចិញ្ចឹមបីបាច់ថែរក្សា លះបង់អស់កម្លាំងកាយចិត្ត លះបង់ធនធាន សេចក្តីស្រឡាញ់ ភាពកក់ក្តៅសព្វបែបយ៉ាងបណ្តុះទឹកចិត្តកតញ្ញូតាធម៌ចំពោះអ្នកមានគុណ និងបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្រខ្ពង់ខ្ពស់ដើម្បីឱ្យកូនក្លាយខ្លួនជាពលរដ្ឋល្អ។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងគណៈគ្រប់គ្រង រួមទាំងសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំប្រឹងប្រែងក្នុងការដឹកនាំ សម្របសម្រួលក៏ដូចជាការបង្ហាត់បង្រៀនក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលមូលធនផ្នែកបញ្ញា ធនធានមនុស្សកម្ពុជាឱ្យមានចំណេះដឹង បទពិសោធន៍ និងមានសមត្ថភាពខ្ពស់ ដើម្បីក្លាយជាសសរទ្រូងស្របតាម កាលានុវត្តភាពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ។

សូមថ្លែងអំណរគុណដល់ **សាស្ត្រាចារ្យជំនួយ បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំកែលម្អ ក៏ដូចជាចង្អុលបង្ហាញតម្រង់ទិស ព្រមទាំងពន្យល់ពីវិធីសាស្ត្រល្អៗផ្តល់យោបល់ល្អៗទាក់ទងនឹងប្រធានបទសារណារបស់នាងខ្ញុំទាំងពីរ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃតាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវមួយនេះ។

ជាទីបញ្ចប់នាងខ្ញុំទាំងពីរនាក់ មានកិត្តិយសសូមសេចក្តីអនុញ្ញាត គោរពជូនពរដល់អ្នកមានគុណទាំងអស់ សូមមេត្តាទទួលយកដោយក្តីអនុគ្រោះបំផុតនូវភក្តីភាព គោរពស្រឡាញ់ក្នុងភាពសុចរិតដែលជាគុណតម្លៃដ៏ឧត្តុងឧត្តមនៃសេចក្តីថ្លៃថ្នូរ ភាពថ្កុំថ្កើង កិត្តិគុណដ៏ខ្ពង់ខ្ពស់ និងកតញ្ញូតាធម៌។ សូមគោរពជូនពរដល់លោកអ្នកមានគុណទាំងអស់ សូមទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា ប្រាជ្ញាវាងវៃ អាយុយឺនយូរ រកទទួលទានមានបានគ្រប់ៗគ្នា ព្រមទាំងជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីនាងខ្ញុំទាំងពីរនាក់ បានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ អស់រយៈពេល ៣ឆ្នាំ កន្លងទៅនេះ នាងខ្ញុំទាំងពីរនាក់បានទទួលនូវចំណេះដឹងជាច្រើនទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ស្ថិតនៅក្នុងដំណាក់កាលនេះ គឺជាឆ្នាំទី៤ របស់នាងខ្ញុំទាំងពីរនាក់ ដោយផ្អែកទៅតាមចំណេះដឹងនៃការសិក្សាទាំងអស់នេះហើយដែលជាកត្តាលីករជំរុញឱ្យនាងខ្ញុំទាំងពីរនាក់ទទួលបានឱកាស និងមានលទ្ធភាពបានសរសេរសារណាបញ្ចប់ការសិក្សាមួយសម្រាប់ទុកជាឯកសារជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយ។ ហើយនេះជាឱកាសដ៏មានតម្លៃមួយដែលអាចស្ទង់អំពីចំណេះដឹងរបស់នាងខ្ញុំទាំងពីរដែលមានពីមុនមក និងសិក្សាស្រាវជ្រាវបន្ថែម។

ហេតុនេះទើបនាងខ្ញុំទាំងពីរនាក់បានជ្រើសរើសយកប្រធានបទមួយដែលទាក់ទងនឹងនីតិនគរូបនីយកម្ម និងសំណង់ដែលស្តីអំពី **«ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០»** មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សា។

កម្មវត្ថុសំខាន់មួយទៀតនោះ គឺចង់ឱ្យនិស្សិតជំនាន់ក្រោយ និងសាធារណជនបានយល់ដឹងអំពីកត្តាដែលជំរុញនាំឱ្យមានការរៀបចំក្រុង ស្តង់ដានៃការរស់នៅល្អ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ លើសពីនេះទៅទៀត នាងខ្ញុំទាំងពីរមានគោលបំណងចង់បង្ហាញអំពី ផែនការអភិវឌ្ឍន៍ ទិសដៅនៃការអភិវឌ្ឍ ក៏ដូចជាសមិទ្ធផលដែលទទួលបាន ព្រមទាំងសក្តានុពលនៃការអភិវឌ្ឍដែលមាននៅក្នុងក្រុងបាត់ដំបងនៃខេត្តបាត់ដំបងផងដែរ។ ម៉្យាងវិញទៀតក៏ដើម្បីឱ្យសាធារណជនគ្រប់រូបមានការយល់ដឹងអំពីការអភិវឌ្ឍក្នុងក្រុងនេះ និងអាចជួយសម្រួលដល់ប្អូនៗនិស្សិតជំនាន់ក្រោយក្នុងការសិក្សា និងអាចយកមកធ្វើជាឯកសារពិគ្រោះបានផងដែរ។

មុននឹងបញ្ចប់ ដោយសេចក្តីគួរ ឬពុំគប្បីយ៉ាងណានោះ នាងខ្ញុំទាំងពីរសូមគោរពទទួលយកនូវរាល់កំហុសឆ្គាំឆ្គងណាមួយដោយចេតនា អចេតនាក្តី ឬនៅមានភាពខ្វះចន្លោះត្រង់កន្លែងណាមួយ សូមមេត្តាខន្តី អភ័យទោសដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំទាំងពីរ ហើយនាងខ្ញុំទាំងពីរនាក់រង់ចាំទទួលនូវមតិរិះគន់ កែលម្អរាល់ចំណុចខ្វះខាតទាំងឡាយក្នុងន័យស្ថាបនា ដើម្បីឱ្យការស្រាវជ្រាវមួយនេះមានអត្ថន័យគ្រប់គ្រាន់បន្ថែមទៀត។

ជាទីបញ្ចប់នាងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់មិត្តនិស្សិត មិត្តអ្នកអានទាំងអស់ សូមទទួលបាននូវជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា ប្រាជ្ញាវាងវៃ អាយុយឺនយូរ រកទទួលទានមានបានគ្រប់ៗគ្នា ព្រមទាំងជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**សេចក្តីផ្តើម** ............ ១

## ជំពូកទី១

## សញ្ញាណនៃការរៀបចំក្រុងបាត់ដំបង

**១.១. ទិដ្ឋភាពទូទៅក្នុងក្រុងបាត់ដំបង** ............ ៤

**១.១.១. ទីតាំងភូមិសាស្ត្រ** ............ ៤

១.១.១.១. ប្លង់គោល ............ ៥

១.១.១.២. តំបន់សេដ្ឋកិច្ច ............ ៧

១.១.១.៣. តំបន់ទេសចរណ៍ ............ ៩

**១.១.២. ស្ថានភាពប្រជាសាស្ត្រនៃក្រុងបាត់ដំបង** ............ ១០

១.១.២.១. ដង់ស៊ីតេប្រជាជន ............ ១០

១.១.២.២. ជីវភាពនៃការរស់នៅ ............ ១០

**១.២. កត្តាជំរុញនាំឱ្យមានការរៀបចំក្រុង** ............ ១១

**១.២.១. កំណើនប្រជាជន** ............ ១១

**១.២.២. កំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ** ............ ១២

**១.២.៣. ភាពក្រីក្រ** ............ ១៣

**១.២.៤. ស្តង់ដានៃការរស់នៅ** ............ ១៤

**១.២.៥. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ............ ១៤

**១.៣. រចនាសម្ព័ន្ធគ្រប់គ្រងក្រុងបាត់ដំបង** ............ ១៦

**១.៣.១. សមាសភាព** ............ ១៦

១.៣.១.១. ក្រុមប្រឹក្សាក្រុង ............ ១៦

១.៣.១.២. គណៈអភិបាលក្រុង ............ ១៦

**១.៣.២. តួនាទី និងភារកិច្ច** ............ ១៧

១.៣.២.១. ក្រុមប្រឹក្សាក្រុង ............ ១៧

១.៣.២.២. គណៈអភិបាលក្រុង ............ ២៣

# ជំពូកទី២

# ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០

**២.១. ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង** ........ ៣៤

**២.១.១. គោលបំណងក្នុងការអភិវឌ្ឍក្រុងបាត់ដំបង** ........ ៣៥

**២.១.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុងបាត់ដំបង** ........ ៣៦

**២.២. ទិសដៅនៃការអភិវឌ្ឍក្រុងបាត់ដំបង** ........ ៣៧

**២.២.១. ចក្ខុវិស័យក្នុងការអភិវឌ្ឍក្រុងបាត់ដំបង** ........ ៣៧

២.២.១.១. យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍក្រុងបាត់ដំបង ........ ៣៨

២.២.១.២. ទិសដៅផែនការក្នុងការអនុវត្តក្រុងបាត់ដំបង ........ ៣៩

**២.២.២. ការតម្រង់ទិសក្នុងការអភិវឌ្ឍក្រុងបាត់ដំបង** ........ ៤០

២.២.២.១. យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នគរូបនីយកម្មក្រុងបាត់ដំបង ........ ៤១

២.២.២.២. ការគ្រប់គ្រងប្រព័ន្ធនៃការដឹកជញ្ជូន និងអភិវឌ្ឍន៍រចនាសម្ព័ន្ធក្រុង ........ ៤២

**២.២.៣. ការអនុវត្តសកម្មភាពតាមវិស័យ** ........ ៤៤

២.២.៣.១. គម្រោងអាទិភាពក្នុងការអភិវឌ្ឍនគរូបនីយកម្មក្របខ័ណ្ឌតំបន់ជាតិ ........ ៤៥

២.២.៣.២. ការអនុវត្តប្រព័ន្ធដឹកជញ្ជូន និងអភិវឌ្ឍន៍វិស័យក្រុងបាត់ដំបង ........ ៤៦

២.២.៣.៣. ដំណើរការនីតិវិធីក្នុងការអនុវត្តសកម្មភាព ........ ៤៨

**២.៣. សមិទ្ធផលនៅក្នុងក្រុងបាត់ដំបង** ........ ៥០

**២.៣.១. វិស័យចម្បងនៅក្នុងក្រុងបាត់ដំបង** ........ ៥០

២.៣.១.១. វិស័យកសិកម្ម ឧស្សាហកម្ម ........ ៥០

២.៣.១.២. ពាណិជ្ជកម្ម និងសិប្បកម្ម ........ ៥៣

២.៣.១.៣. វិស័យទេសចរណ៍ ........ ៥៥

**២.៣.២. វិស័យអប់រំ សុខាភិបាល និង សង្គមកិច្ច** ........ ៥៩

២.៣.២.១. វិស័យអប់រំ យេនឌ័រ វប្បធម៌ ........ ៥៩

២.៣.២.២. សុខាភិបាល និងសង្គមកិច្ច ........ ៦១

**២.៣.៣. បញ្ហាប្រឈម** ........ ៦៣

**២.៣.៤. ដំណោះស្រាយ** ........ ៦៥

**សេចក្តីសន្និដ្ឋាន** ........ ៦៨
**អនុសាសន៍** ........ ៦៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសដែលទើបតែចាកផុតពីភ្លើងសង្គ្រាម និងទទួលបាននូវសុខសន្តិភាពពេញលេញប្រមាណជាជាង ៤០ឆ្នាំ។ បន្ទាប់ពីមានការបញ្ចប់សង្គ្រាមតាមរយៈនយោបាយ ឈ្នះឈ្នះ ដែលជារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺសង្កេតឃើញថាមានការអភិវឌ្ឍរីកលូតលាស់ទៅលើគ្រប់វិស័យទាំងវិស័យរដ្ឋ និងវិស័យឯកជនទាំងគ្រប់លំដាប់ថ្នាក់ ភូមិ ឃុំ ស្រុក/ខណ្ឌ ខេត្ត/ក្រុង។ ជាពិសេស គឺមានការអភិវឌ្ឍលើចំណុចក្នុងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគមនាគមន៍ មន្ទីរពេទ្យ សាលារៀន វត្តអារាម គ្រឹះស្ថាន ស្ថាប័នរដ្ឋ និងឯកជន ព្រមទាំងសំណង់លំនៅឋាន អគារខ្ពស់ៗទំនើបៗ កើតមានឡើងជាបន្តបន្ទាប់ក្នុងដំណាក់កាលប្រមាណជាជាង ១០ឆ្នាំចុងក្រោយនេះ។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយដីធ្លី នៅតាមលំនៅឋានហើយមានការអភិវឌ្ឍតាមរយៈផែនការ និងប្លង់គោល។ ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថេរភាពនយោបាយ និងភាពរឹងមាំការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យនីតិរដ្ឋ ការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខក្នុងការអភិវឌ្ឍសង្គមព្រមទាំងសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មីមុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក គ្រប់វិស័យក្នុងគោលដៅបង្កើននិងកែលម្អការផ្ដល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធិភាព និងស័ក្ដិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានដាក់ចេញនូវគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គឺសំដៅដល់ការធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ការពារ និងអភិវឌ្ឍន៍តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការដាក់នៅវិធានការការប្រើប្រាស់នៅឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ស្ថិរភាព និងវឌ្ឍនភាពសង្គមសេដ្ឋកិច្ចកម្ពុជា ជាកាលានុវត្តភាពជំរុញឱ្យមាននូវនិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ការប្រើប្រាស់ដីធ្លី លំនៅឋាន នគរូបនីយកម្ម និងតម្រូវការក្នុងការបង្កើតទីក្រុងតូចធំគ្រប់កម្រិតដែលមាននូវបណ្ដាញហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដូចជាសេវាកម្មបច្ចេកទេសថាមពល អគ្គិសនី សុខភាព និងទឹកស្អាតអេកូឡូស៊ី ព្រមទាំងធនធានធម្មជាតិការគ្រប់គ្រងកាកសំណល់រឹងរាវ។ ការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីឆ្លើយតបទៅនឹងការវិវត្តទាំងនេះចាំបាច់ត្រូវមានការគិតគូរនៃការកសាងឡើងនូវផែនការរៀបចំដែនដីនគរូបនីយកម្ម ប្លង់គោលប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាពសម្រាប់ធ្វើការគ្រប់គ្រងរួមទាំងការតម្រង់ទិស ការអភិវឌ្ឍលើគ្រប់វិស័យឱ្យមានដំណើរប្រកបដោយចីរភាព ហើយធានា

បាននូវការគ្រប់គ្រងដី កសិកម្មព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី ការការពារបរិស្ថាន និងធនធានធម្មជាតិ។ ផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវបានរៀបចំ និងកសាងឡើងនៅឆ្នាំ២០០៥ ស្របតាមតម្រូវការការវិវត្តជាក់ស្តែងនៃស្ថានភាពសង្គមសេដ្ឋកិច្ច និងបរិស្ថានដោយផ្អែកលើកត្តាទីតាំងភូមិសាស្ត្រជាតំបន់ស្នូលភាគពាយ័ព្យនៃប្រទេសកម្ពុជា កត្តាធនធានធម្មជាតិ បរិស្ថាន កត្តាប្រវត្តិសាស្ត្រ និងបេតិកភណ្ឌវប្បធម៌ ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។ ដោយមើលឃើញពីសមិទ្ធផលនៃការអភិវឌ្ឍដែលកើតមានឡើងទាំងអស់នេះទើប នាងខ្ញុំទាំងពីរនាក់សម្រេចជ្រើសរើសយកប្រធានបទមួយដែលសរសេរពីផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង ដោយក្រុងនេះស្ថិតនៅក្នុងខេត្តបាត់ដំបងនៃព្រះរាជាណាចក្រកម្ពុជាដែលមានការអភិវឌ្ឍយ៉ាងរីកចម្រើន។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ដោយមានការអភិវឌ្ឍឥតឈប់ឈរ និងកំពុងតែមានតម្រូវការចាំបាច់ក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនៃក្រុងបាត់ដំបង ក្នុងនាមនាងខ្ញុំទាំងពីរជាអ្នកពេញចិត្តក្នុងការអភិវឌ្ឍនេះ និងកំពុងសិក្សាជានិស្សិតផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងសារណានេះ នាងខ្ញុំទាំងពីរសូមលើកឡើងប្រធានបទមួយស្តីពី **«ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០»**។

១. មូលហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំក្រុងបាត់ដំបង?

២. តើផែនការអភិវឌ្ឍន៍ដែលជាទិសដៅគោលរបស់ក្រុងបាត់ដំបងបានអភិវឌ្ឍន៍លើវិស័យអ្វីខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណង ក្នុងការកំណត់យកប្រធានបទដែលទាក់ទងនឹងនីតិនគរូបនីយកម្មស្តីពីផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង យកមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ គឺចង់បង្ហាញឱ្យឃើញពីការកកើតក្រុងដំបូងរហូតមានការវិវត្តទៅជាទីក្រុងមួយដែលមានការអភិវឌ្ឍ មានសក្តានុពល ពីព្រោះក្រុងបាត់ដំបងត្រូវបានគេចាត់ទុកថាជាក្រុងមួយដ៏មានប្រជាប្រិយភាព ហើយក៏ជាតំបន់កសិកម្មមួយដ៏ល្អដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនោះក្រុងនេះ គឺជាតំបន់ប្រមូលផ្តុំទៅដោយបណ្តុំស្ថាបត្យកម្មពីសម័យមុន ផ្សារ ហាងទំនិញ តំបន់កម្សាន្ត ជាច្រើនដែលផ្តល់ភាពងាយស្រួលក្នុងការរស់នៅ។ លើសពីនេះទៅទៀតគោលបំណងនៃការបង្កើតស្នាដៃស្រាវជ្រាវនេះឡើង គឺមានបំណងក្នុងការជួយជំរុញឱ្យមានការអភិវឌ្ឍនៃផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងបន្ថែមទៀត។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធសឹងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ចំណែកការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង គឺនាងខ្ញុំទាំងពីរចង់បកស្រាយ និងបង្ហាញអំពី

យន្តការដំណើរការសមិទ្ធផលដែលទទួលបាន ព្រមទាំងគម្រោងការអភិវឌ្ឍនាពេលអនាគតដែលទាក់ទង នឹងផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើអត្ថបទនេះ គឺមានសារៈសំខាន់ណាស់ដល់មិត្តនិស្សិត មិត្តអ្នកអានរួមទាំង អ្នកស្រាវជ្រាវ សាធារណជនទាំងអស់ឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅអំពីការរៀបចំផែនការយុទ្ធសាស្ត្រក្នុង ការអភិវឌ្ឍក្នុងទីក្រុងនាពេលបច្ចុប្បន្នព្រមទាំងទិសដៅនៃការអភិវឌ្ឍនាពេលអនាគត និងរួមចំណែកក្នុងការ ជំរុញឱ្យមានការអភិវឌ្ឍថ្មីបន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវចំពោះប្រធានបទនេះ គឺនាងខ្ញុំទាំងពីរបានខិតខំស្វែងរកឯកសារដែលពាក់ព័ន្ធនានានៅ ក្នុងបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តាមស្ថាប័ន តាម អង្គភាពនានា គេហទំព័រផ្សេងៗ ក្នុងនោះនាងខ្ញុំទាំងពីរបានប្រមូលផ្តុំឯកសារទាំងនោះយកមកវិភាគ ពិភាក្សា ព្រមទាំងចុះរកទិន្នន័យជាក់ស្តែងនៅតាមបណ្តាស្ថាប័នដើម្បីសរសេរសារណាបញ្ចប់ការសិក្សា។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ នាងខ្ញុំទាំងពីរនាក់បានកំណត់បែងចែកសកម្មភាពតាមដំណាក់កាលជំពូក នីមួយៗដូចជា៖

- **ជំពូកទី១ សញ្ញាណនៃការរៀបចំក្រុងបាត់ដំបង៖** នៅក្នុងជំពូកនេះនាងខ្ញុំនឹងបែងចែកជាបី ចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពីទិដ្ឋភាពទូទៅក្នុងក្រុងបាត់ដំបង ចំណុចទី២ និយាយអំពី កត្តាជំរុញនាំឱ្យមានការរៀបចំក្រុង ហើយចំណុចទី៣ បង្ហាញអំពីរចនាសម្ព័ន្ធគ្រប់គ្រងក្រុងបាត់ដំបង។
- **ជំពូកទី២ ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០៖** នៅក្នុងជំពូកនេះនាងខ្ញុំនឹង បែងចែកជាបីចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពីផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង ហើយ ចំណុចទី២ និយាយអំពីទិសដៅនៃការអភិវឌ្ឍក្រុងបាត់ដំបង ចំណុចទី៣ បង្ហាញអំពីសមិទ្ធផលនៃការអភិវឌ្ឍ ក្រុងបាត់ដំបង។

# ជំពូកទី១
# សញ្ញាណនៃការរៀបចំក្រុងបាត់ដំបង

# ជំពូកទី១
# សញ្ញាណនៃការរៀបចំក្រុងបាត់ដំបង

បាត់ដំបង គឺជាខេត្តធំមួយនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត មានទីក្រុងដ៏ស្រស់ឆើតឆាយនៅអមតាមបណ្តោយដងស្ទឹងសង្កែ ដែលមានសំណង់រចនាបទផ្ទះសល់ពីសម័យអាណានិគមបារាំងកំពុងបានក្លាយជាសម្បត្តិបេតិកភណ្ឌជាតិ និងពិភពលោកដែលទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ភ្ញៀវទេសចរជាតិ ព្រមទាំងភ្ញៀវអន្តរជាតិ។ បច្ចុប្បន្ននេះខេត្តបាត់ដំបងជាខេត្តដែលមានសក្តានុពលខ្លាំងទៅលើវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងជាទីក្រុងស្អាតសម្រាប់ប្រកបអាជីវកម្ម ហើយគួរឱ្យចង់រស់នៅ។ ពីមួយថ្ងៃទៅមួយថ្ងៃកំណើនភ្ញៀវទេសចរជាតិ ព្រមទាំងភ្ញៀវអន្តរជាតិជាច្រើននាក់បានធ្វើដំណើរយ៉ាងច្រើនកុះករមកទស្សនានៅលើទឹកដីប្រវត្តិសាស្ត្រមួយនេះដែលអាចគយគន់មើលនូវប្រាសាទនានាជុំវិញខេត្ត ក៏ដូចជាទស្សនាភូមិទេសភាពដែលស្ថិតនៅក្នុងក្រុងបាត់ដំបងផងដែរ។ នៅក្នុងនោះសេវាកម្មដ៏មានប្រជាប្រិយភាពខ្លាំងជាងគេ គឺទូរ្សី (Bamboo Train) និងសេវាកម្មទូកទេសចរណ៍ដែលអាចធ្វើដំណើរតភ្ជាប់ខេត្តបាត់ដំបងទៅខេត្តសៀមរាប ព្រមទាំងគយគន់មើលទេសភាពនានាជាពិសេសភូមិលើទឹករបស់ប្រជាជននៅទីនោះបានដែរ។

ដូចដែលបានរៀបរាប់ខាងលើ ក្រុងបាត់ដំបង គឺជាទីក្រុងមួយដ៏សំខាន់ដែលរួមមានសម្រស់ស្អាតនៃសំណង់អាគារបុរាណមានផ្សារដែលប្រមូលផ្តុំទៅដោយអាជីវករមកពីគ្រប់ទិសទីព្រមទាំងមានសេវាកម្មនានាដូចជាសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានដែលរង់ចាំទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិផងដែរ។ ទន្ទឹមនឹងនេះ ភ្ញៀវទេសចរជាច្រើនដែលបានធ្វើដំណើរកម្សាន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានមកទស្សនាក្រុងបាត់ដំបងដោយបច្ចុប្បន្ននេះក្នុងក្រុងបាត់ដំបង គឺជាក្រុងគោលដៅទេសចរណ៍បែបវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ និងកែច្នៃ។

## ១.១. ទិដ្ឋភាពទូទៅក្នុងក្រុងបាត់ដំបង

### ១.១.១. ទីតាំងភូមិសាស្ត្រ

ខេត្តបាត់ដំបង គឺជាខេត្តមួយស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជាតាមបណ្តោយផ្លូវជាតិលេខ៥ ដែលមានចម្ងាយ ២៩១គីឡូម៉ែត្រពីរាជធានីភ្នំពេញ ហើយមានព្រំប្រទល់ខាងលិចជាប់នឹងខេត្តប៉ៃលិន នៃព្រះរាជាណាចក្រថៃឡង់ដ៏ ខាងកើតជាប់នឹងខេត្តពោធិ៍សាត់ និងបឹងទន្លេសាប ហើយខាងជើងនៃខេត្តនេះ ជាប់នឹងខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប រីឯខាងត្បូងជាប់នឹងខេត្តពោធិ៍សាត់។ ទិសភាគខាងលិច ដែលមានព្រំប្រទល់ប្រវែង ១,៤៤៨គីឡូម៉ែត្រ ជាប់ខេត្តចន្ទបុរីត្រាត និងស្រះកែវរបស់ប្រទេសថៃ។[១]

[១] គេហទំព័រ https://www.battambang.gov.kh/ ដកស្រង់នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣

រីឯក្រុងបាត់ដំបងមានទីតាំងស្ថិតនៅតាមបណ្តោយដងស្ទឹងសង្កែនឹងចំណុចប្រសព្វផ្លូវជាតិលេខ៥ និង៧។ សព្វថ្ងៃនេះក្រុងបាត់ដំបងមានផ្ទៃដី ១១,៥៤៤គីឡូម៉ែត្រការ៉េ។ ក្រុងបាត់ដំបង គឺជាក្រុងមួយក្នុងចំណោមក្រុងស្រុកសរុប ១៤នៃខេត្តបាត់ដំបងហើយក្រុងបាត់ដំបង គឺមានសង្កាត់ចំនួន ១០ ភូមិចំនួន ៦២ ដែលមានព្រំប្រទល់ខាងលិចទល់ស្រុកថ្មគោល ខាងកើតទល់ស្រុកសង្កែ ខាងជើងទល់ស្រុកឯកភ្នំ ខាងត្បូងទល់ស្រុកបាណន់។[២] អាកាសធាតុក្តៅបំផុតនារដូវប្រាំងមានរហូតដល់ ៣៨អង្សាសេ ត្រជាក់បំផុតដល់ ១២អង្សាសេ ហើយអាកាសធាតុមានការប្រែប្រួលទៅតាមរដូវកាលនីមួយៗ។

| ល.រ | ឈ្មោះសង្កាត់ជាអក្សរខ្មែរ | ឈ្មោះសង្កាត់ជាអក្សរឡាតាំង |
|---|---|---|
| ១ | ទួលតាឯក | Toul Ta Aek |
| ២ | ព្រែកព្រះស្តេច | Preaek Preah Sdech |
| ៣ | រតនៈ | Rotanak |
| ៤ | ចំការសំរោង | Chamkar Samraong |
| ៥ | ស្លាកែត | Sla Kaet |
| ៦ | ក្តុលដូនទាវ | Kdoul Doun Teav |
| ៧ | អូរម៉ាល់ | Ou Mal |
| ៨ | វត្តគរ | Voat Kor |
| ៩ | អូរចារ | Ou Char |
| ១០ | ស្វាយប៉ោ | Svay Pao |

**១.១.១.១. ប្លង់គោល**

ប្លង់គោលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥០ ដែលបានអនុម័តជាផ្លូវការដោយក្រសួងនៅខែមេសា ឆ្នាំ១៩៥០ ដែលត្រូវបានធ្វើឡើងដោយការិយាល័យសិក្សាគម្រោងរបស់លោក Chauchon។

- **និយមន័យ**

ប្លង់គោលជាឯកសារ ឬគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍហើយជាប្លង់គ្រឹះសម្រាប់រៀបចំដែនដីនៃក្រុងនីមួយៗ ពីព្រោះថាប្លង់គោលជាអ្នកតម្រង់ទិសក្នុងការរៀបចំបែងចែក ឬកំណត់ផ្ទៃដីសម្រាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈតំបន់សម្រាប់

[២] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី១

ចាក់សំរាម តំបន់សាលារៀន តំបន់ត្រូវការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍។[៣] រីឯប្លង់គោលប្រើប្រាស់ដី គឺជាប្លង់ ឬផែនទី ដែលកើតចេញពីការគិតគូរ និងរៀបចំផែនការទុកជាមុនសម្រាប់បំពេញតម្រូវការនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍរបស់សង្គមណាមួយ គ្រប់ផ្នែក គ្រប់វិស័យ។ រាល់សម័យកាលសង្គម សុទ្ធតែត្រូវការដីធ្លីដើម្បីទ្រទ្រង់ជីវិត និងធ្វើការអភិវឌ្ឍជាបន្តបន្ទាប់។[៤]

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺពុំទាន់ឃើញមានការឱ្យនិយមន័យណាមួយដែលជាក់លាក់ទៅលើប្លង់គោលនោះទេ ប៉ុន្តែប្លង់គោលនេះក៏ត្រូវបានយកមកប្រើប្រាស់ផងដែរនៅក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ នៅត្រង់មាត្រា៥ ដែលបានចែងថាគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដីសំណង់ ខេត្ត ក្រុង នីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំអភិវឌ្ឍន៍ ខេត្ត ក្រុង របស់ខ្លួនហើយការរៀបចំប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ត្រូវបានកំណត់ដោយអនុក្រឹត្យ។ ដើម្បីការពារនូវសម្បត្តិបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់គណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់មានភារៈការរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។ ជាទូទៅប្លង់គោលនេះ គឺមិនត្រូវបានប្រជាពលរដ្ឋយកមកធ្វើជាកម្មវត្ថុនៃបណ្តឹងតាមផ្លូវច្បាប់បានឡើយពីព្រោះ ប្លង់គោលចែងអំពីទស្សនៈវិស័យនៃការអភិវឌ្ឍដីធ្លីនៅក្នុងតំបន់ដែលត្រូវរៀបចំតែប៉ុណ្ណោះ ដូច្នេះភ្នាក់ងាររដ្ឋបាលដែលមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យទៅលើអត្ថន័យនៃប្លង់គោលជាមុនសិនមុននឹងធ្វើការរៀបចំប្លង់ប្រើប្រាស់ដីធ្លី និងសំណង់តំបន់ណាមួយ។ រាល់ប្លង់ប្រើប្រាស់ដីធ្លី សំណង់ និងលិខិតអនុញ្ញាតសាងសង់ត្រូវគោរពទៅតាមប្លង់គោលជានិច្ច។

➢ **អត្ថប្រយោជន៍នៃការរៀបចំប្លង់គោលប្រើប្រាស់ដី**

ការរៀបចំប្លង់គោលប្រើប្រាស់ដីបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍក្រុងដូចជាៈ

- ធ្វើឱ្យការសាងសង់មានបទដ្ឋានតាមការកំណត់របស់ប្លង់គោល
- រាល់ឧទ្យានសួនច្បារ រមណីយដ្ឋាន មហាស្រប ទីធ្លាកម្សាន្តដែលត្រូវបានសាងសង់ដោយមានសណ្តាប់ធ្នាប់
- ការកំណត់របស់ប្លង់គោលទីក្រុងមានសោភ័ណភាព ស្រស់បំព្រង គ្មានសំណង់អនាធិបតេយ្យ មានអនាម័យ ព្រមទាំងគ្មានភក់ ជ្រាំ ដែលអាចចម្លងមេរោគ

[៣] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១១៣

[៤] គេហទំព័រ https://propertyarea.asia/archives/59915 ដកស្រង់នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣

- គ្មានភាពច្របូកច្របល់សួនច្បារក្លាយជាស្ពានីយបូមប្រេង ចំណែកឆ្នេរទន្លេដែលជាទីលានយកខ្យល់អាកាសសម្រាប់បម្រើឱ្យអ្នកទេសចរ ប្រែក្លាយទៅជាផ្ទះស្លឹកឈើភូមិអនាធិបតេយ្យដែលនៅក្នុងក្រុង
- ប្លង់គោលជាប្លង់ដែលបង្ហាញពីសោភ័ណភាពតំបន់សណ្តាប់ធ្នាប់ដែលមានបណ្តាញផ្គត់ផ្គង់ទឹក បណ្តាញលូបង្ហូរទឹក ទឹកស្អុយ មានបណ្តាញអគ្គីសនី មានទីកម្សាន្ត មានសាលារៀន ដីសម្រាប់កីឡាដ្ឋាន ដីសម្រាប់រដ្ឋ ទីធ្លាសម្រាប់ផ្សារ គ្រឹះស្ថានពាណិជ្ជកម្ម និងវប្បធម៌។[៥]

ជារួមប្លង់គោលប្រើប្រាស់ដី គឺជាឧបករណ៍មួយសម្រាប់ព្យាករណ៍ការអភិវឌ្ឍចីរភាពនៃផែនការអនាគត។ វាបានគិតគូរ រួមទាំងបង្ហាញពីទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងបរិស្ថានប្រកបដោយប្រសិទ្ធភាព ជាពិសេសការផ្តោតលើកំណើនប្រជាសាស្ត្រ តម្រូវការរស់នៅការអភិវឌ្ឍរបស់មនុស្សជាតិនៅតាមតំបន់។ គម្រោងប្លង់គោលនឹងជួយពង្រឹងដល់ដំណើរការអភិវឌ្ឍ ការអភិរក្ស និងភាពសមាហរណកម្មដោយសុខដុមនីយកម្មក្នុងសង្គមជាតិ និងអន្តរជាតិ។[៦] ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបងមានចក្ខុវិស័យឆ្នាំ២០៣០ បានសម្រេចដាក់ឱ្យអនុវត្តតាមអនុសេចក្តីសម្រេចលេខ០១៤សសរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ សម្រាប់ការអភិវឌ្ឍក្រុងបាត់ដំបងរហូតដល់ឆ្នាំ២០៣០។[៧]

**១.១.១.២. តំបន់សេដ្ឋកិច្ច**

ជាក់ស្តែងស្ថានភាពសេដ្ឋកិច្ចនៃក្រុងបាត់ដំបងឈានមុខគេនៅក្នុងការនាំចេញអង្ករទៅក្រៅប្រទេសជាការចូលរួមចំណែកបង្កើនសេដ្ឋកិច្ចជាតិ ជាពិសេសចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋផងដែរ។ ជាមួយគ្នានេះដែរ ក្រុងបាត់ដំបង ក៏ដូចជាខេត្តបាត់ដំបងទាំងមូលបាននាំអង្ករចេញទៅក្រៅប្រទេសតាមរយៈក្រុមហ៊ុនបៃតងកម្ពុជាប្រមាណជាជាង ៧ម៉ឺនតោន។ បន្ថែមលើសពីនេះទៅទៀត ការបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ១៨,៣៨៩ហិកតា ស្មើនឹង ៥,៦៩%នៃផែនការដាំដុះស្រូវរដូវវស្សាឆ្នាំ២០២០ ចំនួន ៣២៣,២០០ហិកតា។ នេះបញ្ជាក់ថាសក្តានុពលសេដ្ឋកិច្ចទាំងក្នុងក្រុង និងខេត្តបាត់ដំបងទាំងមូល គឺជាការពឹងផ្អែកលើវិស័យកសិកម្មជាចម្បងតែម្តង ដោយសារមានកត្តាអំណោយផលពីធម្មជាតិ អាកាសធាតុ សណ្ឋានដី ដីដែលមានជីវជាតិខ្ពស់ និងប្រព័ន្ធស្រោចស្រពសម្បូរបែប។ ជាពិសេសមានប្រភពទឹក និងប្រព័ន្ធបង្ហូរទឹកជាច្រើនកន្លែងដែលជាចំណុចខ្លាំងសម្រាប់វិស័យកសិកម្មហើយប្រភពទឹកមានស្ទឹងបីឆ្លងកាត់សំខាន់ៗ ស្ទឹងមោង ស្ទឹងសង្កែ និងស្ទឹងមង្គលបុរី។

[៥] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១១៤

[៦] គេហទំព័រ https://propertyarea.asia/archives/59915 ដកស្រង់នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣

[៧] គេហទំព័រ https://www.mlmupc.gov.kh ដកស្រង់នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣

ដោយសារតែសកម្មភាពដ៏មមាញឹករបស់ប្រជាពលរដ្ឋក្នុងតំបន់សេដ្ឋកិច្ចនៃក្រុងបាត់ដំបង ជាហេតុធ្វើឱ្យក្រុងនេះបានក្លាយជាស្នូលមួយដែលទ្រទ្រង់សេដ្ឋកិច្ច ក្រុង ខេត្ត និងប្រទេសកម្ពុជាទាំងមូល។ តំបន់សេដ្ឋកិច្ចសំខាន់ៗនៅក្នុងក្រុងបាត់ដំបងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងជំរុញឱ្យសេដ្ឋកិច្ចនៃក្រុងនេះឱ្យមានការរីកចម្រើនលូតលាស់។ បន្ថែមលើសពីនេះទៅទៀត ក្រុងបាត់ដំបងមានទីផ្សារសេដ្ឋកិច្ចជាច្រើនដែលនៅផ្តុំគ្នាផ្តល់លក្ខណៈងាយស្រួលដល់អតិថិជនក្នុងការស្វែងរក ហើយផ្សារទាំងអស់នោះក៏បានបង្កើនសេដ្ឋកិច្ចនៃក្រុងផងដែរ។

➢ **តំបន់សេដ្ឋកិច្ចសំខាន់ៗមានៈ**

- រោងចក្រកែច្នៃដំឡូងមី និងពោត
- រោងម៉ាស៊ីនកិនស្រូវ
- រោងចក្រស៊ីម៉ង់ត៍
- រោងចក្រផលិតថ្នាំពេទ្យ
- រោងចក្រកែច្នៃក្រដាស រោងចក្រស្បែកជើង
- រោងចក្រសហគ្រាសគ្រឹះស្ថានផ្សេងៗទៀតចំនួន ៦១៩ដែលបានផ្តល់ការងារដល់កម្មករចំនួនជាង ១៤០០០នាក់[៤]
- ផ្សារធំថ្មី (ណាត់)
- ផ្សារបឹងឈូក
- ផ្សារថ្មីបាត់ដំបង
- ផ្សារលើ
- ផ្សារទំនើបបុរីបាត់ដំបង (កំពុងសាងសង់បាន ៨០%)
- ផ្សារទំនើបក្រុងបាត់ដំបង (កំពុងសាងសង់បាន ៥០%)
- ផ្សារទំនើបបុរីកាណាឌីយ៉ា (កំពុងសាងសង់បាន ១០%)។

ក្នុងចំណោមផ្សារធំៗទាំងនេះយើងឃើញថាផ្សារទំនើបបុរីបាត់ដំបងមានលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ ព្រោះថាផ្សារនេះ គឺបិតនៅចំកណ្តាលក្រុងជាងផ្សារទំនើបផ្សេងៗទៀត។ ចំណែកផ្សារទំនើបក្រុងបាត់ដំបងមានលក្ខណៈឆ្ងាយប្រហែល ៣គីឡូម៉ែត្រពីទីប្រជុំជន ឯផ្សារទំនើបបុរីកាណាឌីយ៉ាបិតនៅចំងាយ ១,៥គីឡូម៉ែត្រតែប៉ុណ្ណោះ។ ទីប្រជុំជនក្រុង គឺបិតនៅចំផ្សារធំថ្មីតែម្តងដែលទីកន្លែងប្រសព្វរវាងផ្លូវលេខ១ ២ និង៣ ផ្លូវព្រះវិហារ

[៤] គេហទំព័រ https://dap-news.com/national/2020/05/13/54298/ ដកស្រង់នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣

និងផ្លូវឡាអេ។[៩] បន្ថែមពីនេះទៅទៀតភោជនីយដ្ឋាន ហាងលក់ទំនិញ និងក្លឹបកម្សាន្តជាច្រើនដែលនៅក្នុងក្រុងបាត់ដំបង ក៏ជាតំបន់សេដ្ឋកិច្ចយ៉ាងសំខាន់ដែលនាំឱ្យក្រុងបាត់ដំបងមានការរីកចម្រើន និងលូតលាស់ផងដែរ។

**១.១.១.៣. តំបន់ទេសចរណ៍**

ផ្អែកតាមទិន្នន័យរបស់គេហទំព័រ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ក្រៅពីដំណាំកសិកម្ម ខេត្តបាត់ដំបងមានគោលដៅទេសចរណ៍ជាង ១០០កន្លែង។ នៅក្នុងគោលដៅទេសចរណ៍ គឺមានរមណីយដ្ឋានទេសចរណ៍ ២០ទីតាំង សហគមន៍ និងអេកូទេសចរណ៍ ៤ទីតាំង ទេសចរណ៍សាសនា ២២ទីតាំង កសិ-ទេសចរណ៍ ៤ទីតាំង ព្រមទាំងគោលដៅទេសចរណ៍ផ្សេងៗ ៥៤ទីតាំង។

បើយោងទៅតាមការស្រាវជ្រាវ ក្រុងបាត់ដំបងជាតំបន់មួយដែលមានសក្តានុពលទាក់ទាញភ្ញៀវទេសចរខ្លាំងណាស់ដូចជា ផ្ទះខ្មែរបុរាណ អគារស្ថាបត្យកម្មកម្រ សណ្ឋាគារខេត្ត សារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង វត្តអារាម ក្រៅពីនេះនៅមាន ដងស្ទឹងសង្កែ បឹងប្បូរ និងតំបន់កសិ-ទេសចរណ៍បែបជាគោលដៅទេសចរណ៍បែបវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ និងកៃច្នៃ ជាសក្តានុពលដ៏សំខាន់បម្រើឱ្យវិស័យទេសចរណ៍ ក៏ដូចជាសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាកម្សាន្តស្រាវជ្រាវ សម្រាកលំហែកាយដែលមានកំណើនកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ជាការពិតណាស់ភ្ញៀវទេសចរអាចទៅកម្សាន្តនៅក្រុងបាត់ដំបងគ្រប់រដូវកាល ព្រោះតំបន់ទេសចរណ៍ក្នុងក្រុងនេះមានគ្រប់សណ្ឋានហើយក្រុងបាត់ដំបងជាក្រុងដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ ម្យ៉ាងវិញទៀតមានប្រវត្តិសាស្ត្រដ៏ចំណាស់ផងដែរ និងជាទីក្រុងធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- **គោលដៅទេសចរណ៍ក្នុងក្រុងត្រូវបានចែកចេញជាប្រាំគោលដៅធំសំខាន់ៗដូចជា៖**
  - រមណីយដ្ឋានទេសចរណ៍មានដូចជា សួនទឹកសុភមង្គល
  - សហគមន៍ និងអេកូទេសចរណ៍មានដូចជា សហគមន៍ទេសចរណ៍វប្បធម៌វត្តគរ
  - តំបន់គោលដៅទេសចរណ៍មានដូចជា កន្លែងធ្វើនំបញ្ចុករំចេក៣ ប៉មវត្តសំពៅ (ប៉មជប៉ុន) ផ្សារធំបាត់ដំបង (ផ្សារណាត់) ផ្សាររាត្រី មន្ទីរទេសចរណ៍ខេត្ត រូបសំណាកនាគសន្តិភាព វិថីទេសចរណ៍ក្រុងបាត់ដំបង វិថីលក់ម្ហូបអាហារ សារៈមន្ទីរខេត្ត សារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង សួនសម្តេចក្រឡាហោម ស ខេង ស្ពានថ្មចាស់ ស្ពានរថភ្លើង សំណង់អគារអភិរក្ស ហ្វារពន្លឺសិល្បៈ អាងក្រពើ

[៩] គេហទំព័រ https://battambanglife.wordpress.com/ ដកស្រង់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣

- ទេសចរណ៍សាសនាមានដូចជា រូបសំណាកលោកតាដំបងក្រញូង ព្រះមហាគន្ធកុដ្ឋ វត្តវិបុល្លថារាម (វត្តកណ្តាល) វត្តពិភិទ្ធារាម (វត្តពិភិទ) វត្តពោធិ៍វាល វត្តសង្កែធារាម (វត្តសង្កែ) វត្តគរ វត្តទេពធិមារាជនិវេស (វត្តកំផែង) វត្តចម្រើនសិរីជ័យមង្គល (កំពង់សីមា) វត្តស្វេតធ័ត្រគុញ្ជជ័យ (វត្តដំរីស)
- កសិ-ទេសចរណ៍មានដូចជា កសិ-ទេសចរណ៍ភូមិវត្តគរ។

មានសំណង់បុរាណជាច្រើនផ្សេងទៀតដូចជា សំណង់ស្ថាបត្យកម្មសម័យបារាំង សំណង់វប្បធម៌ សារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង សារមន្ទីរខេត្ត ស្ពានថ្មចាស់ និងសំណង់អាគារអភិរក្សក្នុងក្រុង។[១០] សហគមន៍ទេសចរណ៍ក៏ត្រូវបានយកចិត្តទុកដាក់រៀបចំ ដោយដាក់បញ្ចូលនូវសកម្មភាពទេសចរណ៍ទៅក្នុងសហគមន៍នានាដែលមានស្រាប់ និងជំរុញភាពសម្បូរបែបនៃផលិតផលទេសចរណ៍ជួយផ្តល់ផលប្រយោជន៍ជូនប្រជាជនក្នុងសហគមន៍ ការធ្វើដំណើរ ទស្សនាកម្សាន្តតាមផ្លូវទឹកទស្សនាតាមភូមិអ្នកនេសាទ តំបន់នេសាទ ដែលមានទេសភាពដ៏ស្រស់ត្រកាលនៃដងស្ទឹងសង្កែ ផ្តល់ជម្រើសថ្មីដល់ភ្ញៀវទេសចរថែមទៀត។[១១]

### ១.១.២. ស្ថានភាពប្រជាសាស្ត្រនៃក្រុងបាត់ដំបង

#### ១.១.២.១. ដង់ស៊ីតេប្រជាជន

ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងបាត់ដំបងមានចំនួន ៣៣,០៣៥គ្រួសារស្មើនឹងប្រជាពលរដ្ឋសរុបចំនួន ១១៥២,០២៧នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ៧៨,១៨៧នាក់។ ប្រជាពលរដ្ឋមានអាយុ ១៨ឆ្នាំឡើងទៅចំនួន ១២១,៧៤៨នាក់ និងចំនួនប្រជាពលរដ្ឋ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៨២,៨៤៣នាក់។[១២]

#### ១.១.២.២. ជីវភាពនៃការរស់នៅ

កម្រិតជីវភាព និងប្រាក់បៀវត្សខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញមនុស្សឱ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង ហើយជនបទមានគម្លាតខ្ពស់ប្រជាពលរដ្ឋនៅជនបទនៅតែចង់ចូលមករស់នៅក្នុងក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពមានអត្រាខ្ពស់ដែលជាកត្តាជំរុញចំណាកស្រុកដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូច្នេះទោះបីជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ទីក្រុងដែរ។ នៅទីក្រុងបានប្រមូលផ្តុំដោយកត្តាសង្គមនយោបាយឱ្យល្អប្រសើរខណៈពេលវិស័យសុខាភិបាល

---

[១០] គេហទំព័រ https://hunnghivietnamcampuchia.thoidai.com.vn/dtail-article-11917.html ដកស្រង់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣

[១១] គេហទំព័រ https://hunnghivietnamcampuchia.thoidai.com.vn/dtail-article-11917.html ដកស្រង់នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

[១២] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី៣

និងការអប់រំមានភាពសម្បូរបែបតឹងរ៉ឹងធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថា មានសុខសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។[១៣]

## ១.២. កត្តាជំរុញនាំឱ្យមានការរៀបចំក្រុង

កត្តាដែលជំរុញនាំឱ្យមានការរៀបចំក្រុងមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសនិទានកម្មពោល គឺមានការគិតគូរយ៉ាងហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ។[១៤] ទន្ទឹមនឹងនេះ មុនឈានទៅដល់ការរៀបចំ ឬអភិវឌ្ឍន៍អ្វីមួយ គឺបណ្តាលមកពីភាពខ្វះចន្លោះមួយចំនួនដែលជាដើមហេតុនាំឱ្យកើតមាននូវបញ្ហាផ្សេងៗផងដែរតែយ៉ាងណាមិញ បើយើងក្រឡេកទៅមើលតាមបណ្តាតំបន់នានាដូចជា ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ក្នុងប្រទេសនានាក៏ដូចជាប្រទេសកម្ពុជារបស់យើងតែងតែមានការរៀបចំនូវគម្រោង ឬក៏ដាក់ផែនការសកម្មភាពអភិវឌ្ឍន៍នៅតាមតំបន់នានាដែលកំពុងជួបនូវបញ្ហាខ្វះខាតដែលត្រូវមានការរៀបចំឱ្យកាន់តែប្រសើរឡើងជាងមុន។

ដោយជារួមមកមុននឹងឈានដល់ការរៀបចំទីក្រុង គឺសំដៅដល់ការរៀបចំឱ្យមានសោភ័ណភាពមានសកម្មភាពល្អ សន្តិសុខ ភាពស្ងប់ស្ងាត់ និងអនាម័យ។ ដូច្នេះក្រុងមួយអាចមានការកកើតឡើងពុំមែនដោយសារកត្តាចៃដន្យនោះទេ គឺកើតឡើងដោយសារមូលហេតុជំរុញពីក្រោយជាច្រើន។

### ១.២.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនដែលពីមួយឆ្នាំទៅមួយឆ្នាំមនុស្សចេះតែកើនឡើង ដូច្នេះអាត្រាកំណើតប្រជាពលរដ្ឋថ្មីនេះ ហើយក៏ដូចជាចំនួនកំណើនប្រជាជនក្នុងទីក្រុងដែលស្ថិតក្នុងកាលៈទេសៈពេលវេលារំកិលទៅមុខអត្រាមរណៈភាពតិច រីឯអត្រាកើតក៏ច្រើនផងដែរ។ ចំណែកកំណើនដោយសារមានការចំណាកស្រុកពីជនបទ គឺដោយសារក្រុងបាត់ដំបងសម្បូរទៅដោយហាងលក់ទំនិញ កន្លែងកម្សាន្ត ហាងតូចធំជាច្រើនដែលជាហេតុនាំឱ្យប្រជាពលរដ្ឋនៅតាមស្រុកជនបទដែលមានជីវភាពខ្វះខាតសម្រេចចិត្តចាកចេញពីលំនៅដ្ឋានរបស់ពួកគេរៀងៗខ្លួនមកកាន់ទីក្រុងដើម្បីផ្គត់ផ្គង់ជីវភាព។ រីឯកំណើនប្រជាជនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទ គឺកើតឡើងដោយសារតែសណ្ឋានដីទីក្រុងថ្មីដែលពីមុនមកជាខេត្ត ឬទីជនបទ។

[១៣] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១៧

[១៤] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១៦

➢ **កំណើនប្រជាជននៅថ្ងៃអនាគត**

ចំនួនប្រជាជនពិភពលោកបានកើនឡើងដល់ចំនួន ៦,១ពាន់លាននាក់ ក្នុងពាក់កណ្តាលឆ្នាំ២០០០ ដោយឡែកបច្ចុប្បន្នកំពុងតែកើនឡើងជាមធ្យមចំនួន ៧,៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ខាងមុខ ចំនួនប្រជាជននៅក្នុងពិភពលោកនឹងមានការកើនឡើងខ្លាំងចន្លោះពីចំនួន ៧,៩ ទៅ ១០,៥លាននាក់ និងបាន កើនដល់ ៨,២៦៧លាននាក់ ក្នុងឆ្នាំ២០៥០នៃតំបន់ក្រុង។ បើទោះបីជាមាននូវប្រទេសមួយចំនួនដែលបាន លេចចេញនូវអត្តិភាពនៃអត្រាមរណៈភាពខ្ពស់ ដោយសារតែជំងឺអេដស៍ក៏ដោយក៏កំណើនរបស់ប្រជាជននៅតែ ខ្ពស់ដដែល។ ជាមួយគ្នានេះផងដែរចំនួនប្រជាជននៅក្នុងប្រទេសអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ គឺមិនត្រូវបានគេ រំពឹងថានឹងកើនឡើងក្នុងរយៈពេល ៥០ឆ្នាំខាងមុខដែលនេះជាហេតុផល គឺដោយសារតែកម្រិតនៃការមានកូនត្រូវ ដាក់ឱ្យស្ថិតក្រោមកម្រិតកំណត់មួយជាក់លាក់ តែមានការផ្ទុយទៅវិញចំនួនប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានព្យាករណ៍ថានឹងមានចំនួនកើនឡើងពី ៤,៩ពាន់លាននាក់។ ដោយនៅក្នុងឆ្នាំ២០០០ ដែលនឹងមានការ កើនឡើងដល់ ៨,២លាននាក់ នៅក្នុងឆ្នាំ២០៥០។ កំណើនយ៉ាងឆាប់រហ័សនេះត្រូវបានគេរំពឹងថានឹងកើនឡើង ក្នុងចំណោមក្រុមប្រទេសអភិវឌ្ឍន៍ចំនួន ៤៨ប្រទេស ដែលចំនួនប្រជាជនរបស់ពួកគេត្រូវបានរំពឹងថានឹងមានការ កើនឡើងជិតបីដងក្នុងរយៈពេល ៥០ឆ្នាំខាងមុខនេះ។ រីឯរឿងដែលទាក់ទងនឹងការអន្តោប្រវេសន៍អន្តរជាតិ វិញក៏ត្រូវបានព្យាករណ៍ថានឹងមានកំណើនផងដែរ រួមទាំងដង់ស៊ីតេប្រជាជនខ្ពស់ដែលស្ថិតនៅក្នុងសតវត្សទី២១ នេះផងដែរ។[១៥]

បញ្ហាកំណើនប្រជាជន គឺជាបញ្ហាចម្បងមួយ និងអាចចាត់ទុកបានជាបញ្ហាសំខាន់ដែលបានបង្កើតឱ្យ មានបញ្ហាផ្សេងៗ ជាច្រើនផ្សេងទៀត។ ដូចដែលបានរៀបរាប់ខាងលើប្រជាជន គឺមានអាត្រាកើនឡើងជារៀងរាល់ ឆ្នាំហើយតម្រូវការរបស់ប្រជាជន ក៏មានការកើនឡើងជាលំដាប់ផងដែរ។ ដោយសារតែកំណើនប្រជាជនមាន ការកើនឡើងច្រើនដែលជាហេតុនាំឱ្យមានការអភិវឌ្ឍ ព្រមទាំងដោះស្រាយបញ្ហា និងបំពេញនូវតម្រូវការប្រើប្រាស់ របស់ប្រជាពលរដ្ឋដែលកំពុងជួបប្រទះជាក់ស្តែង។

### ១.២.២. កំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ

ខេត្តបាត់ដំបងជាផ្នែកមួយក្នុងប្រទេសកម្ពុជាដែលមានក្រុងមួយ គឺក្រុងបាត់ដំបង។ ក្រុងបាត់ដំបង គឺជា ក្រុងដែលមានបរិយាកាសល្អសម្រាប់ការរស់នៅបំពេញការងារដែលមានសក្តានុពល និងជាចំណុចកណ្តាល នៃការផ្គត់ផ្គង់គាំទ្រ និងទាក់ទាញដល់វិស័យទេសចរណ៍យ៉ាងខ្លាំងខណៈភ្ញៀវទេសចរជាតិ និងអន្តរជាតិមាន ការចាប់អារម្មណ៍ទៅលើធនធានសំខាន់ៗនៅក្នុងក្រុង។[១៦] ស្ទឹង ទន្លេ ភ្នំ កសិ-ទេសចរណ៍ អេកូទេសចរណ៍

[១៥] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១៧

[១៦] គេហទំព័រ https://www.kampucheathmey.com/local-news/452620 ដកស្រង់នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

ប្រពៃណីវប្បធម៌ អគារ វត្តបុរាណ ម្ហូបប្រចាំតំបន់រមណីយដ្ឋានធម្មជាតិ និងការកែច្នៃជាច្រើនកន្លែង គឺជាភាពទាក់ទាញនៃទេសចរណ៍។ កំណើនភ្ញៀវទេសចរសរុបទាំងក្នុងក្រុង ស្រុក និងខេត្តបាត់ដំបងពីឆ្នាំ២០២២ មានការកើនឡើងក្នុងនោះចំនួនភ្ញៀវទេសចរ ៥៥៥,២៧៤នាក់ កើនឡើង ២៤៣% និងទេសចរអន្តរជាតិមានចំនួន ១៨៤,៦០០នាក់ កើនចំនួន ២១៨%។[១៧]

### ១.២.៣. ភាពក្រីក្រ

នៅក្នុងការកំណត់អំពី ស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់តែជាទូទៅភាពក្រីក្រសំដៅដល់ការខ្វះខាតដែលជាតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមមកប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលដែលរកបានរបស់ពួកគេ ដោយសារតែមិនអាចផ្គត់ផ្គង់នៅតម្រូវការចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃលើការចំណាយខាងរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារ ធនធានទឹក អគ្គិសនី អនាម័យ សុខមាលភាពសង្គមមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម ការនិយាយដោយឡែកសិទ្ធិរបស់ពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតផងដែរ។ ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបបុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យម គឺមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើងបានទេ។ ជាធម្មតាអ្នកដែលទទួលប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មតថាជនក្រីក្រយ៉ាងហោចណាស់ជាង២០%នៃចំនួនប្រជាជនពិភពលោកដែលរស់។ នៅក្នុងបន្ទាត់នៃភាពក្រីក្រហើយ៩០%ក្នុងចំនួននេះស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[១៨]

- **ភាពក្រីក្រនៅជនបទ**

ស្ថិតនៅក្នុងបរិការណ៍នៃបច្ចុប្បន្នភាពនេះស្ថានភាពក្រីក្រប្រទេសអភិវឌ្ឍន៍ គឺមានការកើនឡើងជាលំដាប់កំណើននេះអាស្រ័យទៅតាមស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជារាស្ត្រ ភូមិសាស្ត្រនយោបាយ គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅជនបទនាំឱ្យមានចំណាកស្រុកទៅទីក្រុងហើយវានឹងកើនឡើងនៅពេលដែលស្ថានភាពនៅតំបន់កាន់តែលំបាក។ ដូច្នេះការបង្កើនសកម្មភាពក្នុងសេដ្ឋកិច្ចនៅជនបទជាវិធីសាស្ត្រមួយមានប្រសិទ្ធិភាពដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកនេះ។

- **ភាពក្រីក្រនៅទីក្រុង**

កាលណាមានភាពក្រីក្រនៅទីក្រុង គឺពិតជាបង្កផលពិបាកយ៉ាងខ្លាំង។ ជាទូទៅយើងពុំមាននូវលក្ខណៈសមភាពទេ កាលណាប្រសិនជាយើងធ្វើការប្រៀបធៀបពីភាពក្រីក្រដោយការដាក់បន្ទាត់មួយក្រិតស្មើគ្នានោះ។

---

[១៧] គេហទំព័រ https://thmeythmey25.com/detail/93689 ដកស្រង់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

[១៨] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១៧

ឧទាហរណ៍ ការប្រើប្រាស់នូវថវិកា ៣លានដុល្លារសហរដ្ឋអាមេរិកដូចគ្នាតែបុគ្គលម្នាក់នោះនៅជនបទ ចំណែកបុគ្គលម្នាក់ទៀតនៅទីក្រុងមិនអាចស្មើគ្នាទេនៅក្នុងការចំណាយលុយ។ មូលហេតុដោយសារនៅទីក្រុងមានការចំណាយខ្ពស់ជាងជនបទដាច់ឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះអ្នករស់នៅតាមជនបទមានឱកាសស្វែងរកការចិញ្ចឹមជីវិតតាមរយៈទទួលអំណោយភោគផលធម្មជាតិច្រើនជាងអ្នកនៅក្នុងទីក្រុង។ ជារួមប្រសិនបើមានភាពក្រីក្រនៅក្នុងទីក្រុងហើយអាជ្ញាធរគ្រប់ជាន់ថ្នាក់ត្រូវតែបង្កើតឱ្យមានសេវាកម្មគ្រប់វិស័យ ដើម្បីទាក់ទាញឱ្យអ្នកវិនិយោគនានាបង្កើតគ្រឹះស្ថាន រោងចក្រ សហគ្រាស ឬសេវាកម្មផ្សេងៗនៅក្នុងទីក្រុងដើម្បីឱ្យប្រជាពលរដ្ឋមានការងារធ្វើ ហើយបានជួយប្រជាជនដែលរស់នៅទីជនបទកំពុងជួបនូវភាពក្រីក្រខ្វះខាតការងារធ្វើផងដែរ។ ដូច្នេះភាពក្រីក្រនេះក៏ជាមូលហេតុមួយដែលនាំឱ្យមានការរៀបចំក្រុងផងដែរ។

### ១.២.៤. ស្ថានភាពនៃការរស់នៅ

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធ គឺជាវិស័យបរិស្ថាន កង្វះដីសម្រាប់បង្កបង្កើនផលដើម្បីធ្វើកសិកម្ម ករណីនេះកើតមានច្រើនក្នុងករណីដែលដីរបស់ពួកគេទទួលបានពីដូនតាឪពុកម្ដាយរបស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូចដែលមិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈជាខ្សៃ និងគ្មានជីជាតិទៀត ប្រសិនបើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ។ ករណីនេះច្រើនកើតមានឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់មេគង្គក្រោមបញ្ហាខាងលើនេះបណ្ដាលឱ្យបានការធ្វើចំណាកស្រុកទៅកាន់ទីក្រុង។[១៩]

### ១.២.៥. សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

បញ្ហាសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ គឺជាបញ្ហាមួយដ៏សំខាន់ដែលអាចកើតមានឡើងតាមរយៈភាពអសន្តិសុខ និងសំណង់អនាធិបតេយ្យនៅក្នុងសង្គមក៏ជាកត្តាមួយដែលជំរុញឱ្យមានការអភិវឌ្ឍ និងរៀបចំក្នុងក្រុង។ ដោយសារតែភាពអនាធិបតេយ្យនេះបានធ្វើឱ្យមានផលប៉ះពាល់ទៅដល់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងទីក្រុង។ ដើម្បីធានាដល់ការរស់នៅឱ្យមានការការពារសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋអាជ្ញាធរគ្រប់ជាន់ថ្នាក់នៅក្នុងខេត្ត ក្រុងត្រូវយកចិត្តទុកដាក់ជាខ្លាំងនូវការថែរក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈជូនដល់ប្រជាពលរដ្ឋដែលអនុវត្តក្រោមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផែនការណែនាំស្ដីពីការចាត់តាំងនូវការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដែលមានលក្ខណៈសម្បត្តិរហូតដល់ទៅ

[១៩] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣, ទំព័រទី១៨

៥យ៉ាង។ បច្ចុប្បន្នរាជរដ្ឋាភិបាលបានធ្វើការរៀបចំនូវការកែលម្អលក្ខណៈសម្បត្តិគោលនយោបាយភូមិ ឃុំ សង្កាត់ដែលមានសុវត្ថិភាពបន្ថែមរហូតដល់ប្រាំមួយចំណុចមានដូចជា៖

- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី កុមារ គ្មានអំពើហឹង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
- មានសណ្តាប់ធ្នាប់ល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
- ដោះស្រាយវិធានការនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព ប្រសិទ្ធភាពរួមទាំងអនាម័យ
- មានសោភ័ណភាពល្អ និងមានបរិស្ថានល្អឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។[២០]

ជាក់ស្តែងក្រុងបាត់ដំបងជាទីក្រុងមួយមានលក្ខណៈភូមិសាស្ត្រទីប្រជុំជន ប្រមូលផ្តុំនៅមជ្ឈមណ្ឌលរដ្ឋបាល ពាណិជ្ជកម្ម សេវាកម្ម វប្បធម៌ សំណង់បុរាណ ដែលប្រមូលផ្តុំគ្រប់សមាសភាពគ្រប់មធ្យោបាយចេញចូលច្រើនយ៉ាងដែលជាហេតុប្រឈមទៅនឹងភាពស្មុគស្មាញលើផ្នែកសណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន ដោយស្មារតីការចូលរួម ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិតផងនោះ។ ហេតុដូចនេះរដ្ឋបាលក្រុងបានខិតខំប្រឹងប្រែងយ៉ាងឱ្យសកម្មដោយបានបង្កើតគណៈកម្មការមួយមានលោកអភិបាលរងចំនួន ០១រូបទទួលបន្ទុក និងមានការិយាល័យសាធារណៈការដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈជាសេនាធិការរួមទាំងកម្លាំងសមត្ថកិច្ច នគរបាល អាវុធហត្ថ ព្រមទាំងដាក់ចេញនូវវិធានការគោលការណ៍អនុវត្តជាបន្តបន្ទាប់ដូចជា ការប្រជុំផ្សព្វផ្សាយវេទិកាផ្សព្វផ្សាយតាមឃោសនស័ព្ទដោយមធ្យោបាយចល័ត ខិតប័ណ្ណ និងស្លាកសញ្ញាផ្សេងៗដល់ប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមលើកកម្ពស់លើការថែរក្សាសណ្តាប់ធ្នាប់ អនាម័យ បរិស្ថានឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ អនាម័យ បរិស្ថានល្អ សមស្របជាទីក្រុងទទួលបានជ័យលាភីផ្កាវំដួលបីទងទីក្រុងស្អាតវ៉ៃ អាស៊ាន ព្រមទាំងលើកកម្ពស់កិត្តិនាមខេត្តបាត់ដំបង។ ជាប្រចាំកម្លាំងអធិការដ្ឋាននគរបាលក្រុងបានចុះរៀបចំនៅសណ្តាប់ធ្នាប់លើអ្នកលក់ដូរលើមធ្យោបាយឈប់ចតល្មើសច្បាប់គ្រប់ប្រភេទនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងជាលទ្ធផល រៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរនៅតាមសួន តាមទីផ្សារ

[២០] គេហទំព័រ http://www.interior.gov.kh/new/detail/2225 ដកស្រង់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

តាមចំណតរថយន្ត រៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរតាមផ្លូវជាតិ ផ្លូវក្នុងក្រុងនានាឱ្យមានរបៀបរៀបរយរួមទាំងសណ្តាប់ធ្នាប់ល្អ និងរៀបចំសណ្តាប់ធ្នាប់លើមធ្យោបាយគ្រប់ប្រភេទដែលឈប់ចតល្មើសសណ្តាប់ធ្នាប់។[២១]

## ១.៣. រចនាសម្ព័ន្ធគ្រប់គ្រងក្រុងបាត់ដំបង

រចនាសម្ព័ន្ធរបស់ក្រុងបាត់ដំបង ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខនស/រកម/០៥០៨/០១៧ ឆ្នាំ២០០៨ ក្រុងបាត់ដំបងមានរចនាសម្ព័ន្ធរដ្ឋបាលដូចជា ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សាគណៈអភិបាល នាយករដ្ឋបាល ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង និងការិយាល័យជំនាញផ្សេងៗទៀត។

### ១.៣.១. សមាសភាព

#### ១.៣.១.១. ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាក្រុងនីមួយៗដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងជាអ្នកសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាក្រុងនីមួយៗត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។[២២]

#### ១.៣.១.២. គណៈអភិបាលក្រុង

ជាទូទៅក្រុងនីមួយៗ ត្រូវតែមានគណៈអភិបាលក្រុងមួយដែលរួមមាន អភិបាលក្រុង អភិបាលរងក្រុង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[២៣] គួរបញ្ជាក់ផងដែរថា អភិបាលក្រុង អភិបាលរងក្រុងមិនមែនជាសមាជិកក្រុមប្រឹក្សាក្រុងឡើយ។[២៤]

សាលាក្រុងបាត់ដំបង គឺត្រូវបានដឹកនាំដោយអភិបាលក្រុងចំនួន ០១រូប និងអមដោយអភិបាលរងចំនួន ០៤រូបជាជំនួយការ។ អភិបាល និងអភិបាលរងក្រុងត្រូវរួមគ្នាដឹកនាំគ្រប់គ្រងកិច្ចការរដ្ឋបាលដែនដី ការពារ

[២១] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី៤២

[២២] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦១-៦២

[២៣] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨២

[២៤] អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, លេខ១៨២អនក្រ.បក, ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩, មាត្រា៩

សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម វប្បធម៌នៅក្នុងក្របខ័ណ្ឌនៃភូមិសាស្ត្រក្នុងក្រុងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានតម្លៃជាធរមាន។

អភិបាលក្រុង គឺត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌ មន្ត្រីរដ្ឋបាលជាន់ខ្ពស់របស់ក្រសួងមហាផ្ទៃ មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើងទៅ និងមានអាយុយ៉ាងតិច ៣០ឆ្នាំ និងមានបទពិសោធន៍ការងាររដ្ឋបាលសាធារណៈយ៉ាងតិច ៥ឆ្នាំ។រីឯអភិបាលរងក្រុងវិញ គឺត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរបស់ក្រសួងមហាផ្ទៃ និងមានឋានន្តរសក្តិចាប់ពីនាយកក្រមការហើយមានអាយុយ៉ាងតិច ២៥ឆ្នាំ និងមានបទពិសោធន៍ការងាររដ្ឋបាលសាធារណៈយ៉ាងតិច ៣ឆ្នាំ។[២៥]

### ១.៣.២. តួនាទី និងភារកិច្ច

#### ១.៣.២.១. ក្រុមប្រឹក្សាក្រុង

➢ **ក្រុមប្រឹក្សាក្រុង គឺមានតួនាទី និងភារកិច្ចសំខាន់ដូចជា៖**

យោងតាមអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក លេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៦៣ បានចែងថាក្រុមប្រឹក្សាក្រុងមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានាដើម្បីសម្រេចគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ក្រុមប្រឹក្សាក្រុងនីមួយៗត្រូវសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសង្កាត់ និងសហគមន៍ប្រជាពលរដ្ឋក្នុងក្រុងរបស់ខ្លួន ដើម្បីកំណត់អំពីតម្រូវការជាអាទិភាពក្នុងការផ្តល់សេវានិងការអភិវឌ្ឍ និងសំណើ ឬសំណូមពរនានារបស់ប្រជាពលរដ្ឋក្នុងក្រុងរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុង។[២៦]

យោងតាមអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក លេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៦៥ បានចែងក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាក្រុងត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយ

[២៥] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨, មាត្រា១៤៤-១៤៥

[២៦] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦៤

និងពិគ្រោះយោបល់នៅតាមសង្កាត់នានាក្នុងក្រុងរបស់ខ្លួន។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះត្រូវចូលរួមសមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាសង្កាត់ទាំងអស់នៅក្នុងក្រុងតំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាក្រុង។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះមានគោលបំណង ដើម្បីឱ្យក្រុមប្រឹក្សាក្រុងជម្រាបជូនក្រុមប្រឹក្សាសង្កាត់សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានាអំពីសកម្មភាពរបស់ក្រុមប្រឹក្សាក្រុងក្នុងចន្លោះពេលពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់មួយទៅវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់មួយការឆ្លើយតបចំពោះសំណើសំណូមពរនានារបស់ក្រុមប្រឹក្សាសង្កាត់សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងការពិភាក្សាស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួមដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាក្រុងនីមួយៗជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់។

គណៈអភិបាលក្រុង ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធ្វើការបូកសរុបវាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះត្រូវលើកឡើងនូវគោលការណ៍វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋានក្នុងក្របខ័ណ្ឌតួនាទីសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ចំពោះកិច្ចការទាំងឡាយណាដែលមានពាក់ព័ន្ធតួនាទីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលក្រុងត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះដើម្បីតែលើកឡើងអំពីគោលការណ៍វិធានការដោះស្រាយតាមសមត្ថកិច្ចរៀងៗខ្លួន។ គណៈអភិបាលក្រុងត្រូវបញ្ជូនរបាយការណ៍ខាងលើនេះមួយច្បាប់មករដ្ឋបាលខេត្ត ដើម្បីពិនិត្យ និងដោះស្រាយកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទីសមត្ថកិច្ចរដ្ឋបាលខេត្តក្នុងកិច្ចការ ដែលមានពាក់ព័ន្ធនឹងសមត្ថកិច្ចដោះស្រាយរបស់ថ្នាក់ជាតិ គណៈអភិបាលខេត្ត ត្រូវធ្វើការប្រមូលផ្តុំពីគ្រប់ក្រុង ដើម្បីធ្វើសេចក្តីរាយការណ៍មកក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សារបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយ និងការពិគ្រោះយោបល់តាមការចាំបាច់។

ក្រុមប្រឹក្សាក្រុងត្រូវបំពេញមុខងារ ភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាបានថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។[២៧]

[២៧] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦៦

ក្រុមប្រឹក្សាក្រុងអាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាង សេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះគណៈអភិបាលក្រុងត្រូវដឹកនាំនាយករដ្ឋបាលសាលាក្រុង និងការិយាល័យពាក់ព័ន្ធនៃសាលាក្រុងដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។ គណៈអភិបាលក្រុងដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការត្រូវធ្វើការសម្របសម្រួល ណែនាំដល់ការិយាល័យនានានៃសាលាក្រុងរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចដាក់ជូនក្រុមប្រឹក្សាពិនិត្យពិភាក្សា និងអនុម័ត។ គណៈអភិបាលក្រុងត្រូវណែនាំនាយករដ្ឋបាលសាលាក្រុងឱ្យរៀបចំដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួចឱ្យស្របតាមទម្រង់ដែលកំណត់ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលក្រុង។ ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណា ដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួចលើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។[២៨]

ប្រធានក្រុមប្រឹក្សាក្រុងក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនមានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលក្រុងលើ៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាក្រុង
- សំណើដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុងតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងរយៈពេលដប់ពីរ (១២) ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង

[២៨] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦៨

- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ គណៈអភិបាលក្រុងត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះលើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។[២៩]

រាល់កិច្ចប្រជុំរបស់ខ្លួនក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលក្រុង និងវិធានការ បែបបទនីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹងៈ

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នាប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នាដែលរួមមាន ក្រសួងស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធានរួមទាំងការរៀបចំគណៈកម្មាធិការការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុងដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង

[២៩] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦៩

- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត នានា។[៣០]

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុង ត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែងក្នុងមាត្រា៧០ នៃអនុក្រឹត្យនេះក្រុមប្រឹក្សាក្រុងអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ការកោះអញ្ជើញអភិបាលក្រុង ឬអភិបាលរងក្រុង ឬគណៈអភិបាលក្រុងទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេច របស់ក្រុមប្រឹក្សាក្រុងដែលហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងការសម្រេចឱ្យធ្វើការ។ ផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះព្រមទាំងណែនាំដល់គណៈអភិបាលក្រុងអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនោះ
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីដែលមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុងតាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[៣០] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៧០

- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដែលរៀបចំដោយមានគណៈអភិបាលក្រុង
- បញ្ហាផ្សេងៗទៀត ដែលតម្រូវដោយច្បាប់លិខិតបទដ្ឋានគតិយុត្តព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់។[៣១]

យោងតាមអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក លេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៧២ បានចែងថាក្រុមប្រឹក្សាក្រុងត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួនហើយដែលកិច្ចការនោះច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត មិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវរៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាពគណនេយ្យភាព និងប្រសិទ្ធភាពដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័តដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទនីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦ នៃអនុក្រឹត្យនេះ។

យោងតាមអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក លេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៧៤ បានចែងថាដីកា ឬសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសង្កាត់ ត្រូវស្ថិតក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សាក្រុង។ ក្រុមប្រឹក្សាក្រុង ត្រូវធ្វើប្រតិភូកម្មដល់គណៈអភិបាលក្រុងដើម្បីពិនិត្យនីត្យានុកូលភាពនេះ។ ក្នុងករណីពិនិត្យឃើញថាដីកា ឬសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាសង្កាត់មិនស្របតាមច្បាប់ លិខិត បទដ្ឋានគតិយុត្តនានា និងគោលការណ៍ដែលសម្រេចដោយក្រុមប្រឹក្សាក្រុង

[៣១] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៧១

ឬការសម្រេច ឬការងារណាមួយដែល ក្រុមប្រឹក្សាសង្កាត់បានធ្វើការសម្រេចហួសពីដែនសមត្ថកិច្ចដែលក្រុមប្រឹក្សាក្រុងបានធ្វើប្រតិភូកម្ម គណៈអភិបាលក្រុង ត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរជូនដល់ក្រុមប្រឹក្សាសង្កាត់ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសេចក្តីសម្រេច ជាក់លាក់ និងកិច្ចការជាក់លាក់ណាមួយ ឬមួយចំនួនដែលក្រុមប្រឹក្សាសង្កាត់ធ្វើការសម្រេច ឬធ្វើសកម្មភាពមិនសមស្រប។ ផ្អែកទៅតាមការណែនាំនេះក្រុមប្រឹក្សាសង្កាត់ត្រូវកែតម្រូវសេចក្តីសម្រេច ឬសកម្មភាពរបស់ខ្លួនឱ្យបានសមស្របឡើងវិញក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃបន្ទាប់ពីបានទទួលការណែនាំជាលាយលក្ខណ៍អក្សរពីគណៈអភិបាលក្រុង។ ក្នុងករណីក្រុមប្រឹក្សាសង្កាត់មិនអនុវត្តតាមការណែនាំខាងលើនេះ ក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត ដើម្បីសម្របសម្រួលអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា១៩៦ នៃអនុក្រឹត្យនេះ។

**១.៣.២.២. គណៈអភិបាលក្រុង**

- **គណៈអភិបាលក្រុង គឺមានតួនាទី និងភារកិច្ចសំខាន់ដូចជា៖**

គណៈអភិបាលក្រុង ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។[៣២]

គណៈអភិបាលក្រុងមានភារកិច្ចផ្តល់យោបល់រាយការណ៍ជូនក្រុមប្រឹក្សាក្រុង និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុងទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។[៣៣]

គណៈអភិបាលក្រុង ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុងអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុងដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

- ការពិនិត្យមុខងារភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងអំពីរបៀបរបបបែបបទ នីតិវិធីនៃការអនុវត្តមុខងារភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[៣២] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨៤

[៣៣] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨៥

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុង
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង៖
    - ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និងសកម្មភាពលទ្ធផលនៃការអនុវត្ត
    - របាយការណ៍ហិរញ្ញវត្ថុ
    - ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិក
    - វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
    - កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មានការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការដោះស្រាយសំណើសំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់
- ការធ្វើប្រតិភូកម្មមុខងារភារកិច្ច និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់

- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន។[៣៤]

គណៈអភិបាលក្រុងត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាក្រុង និងធ្វើសេចក្តីរាយការណ៍ជូនដល់រដ្ឋបាលខេត្តដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[៣៥]

យោងតាមអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក លេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៨៨ បានចែងថាក្នុងការអនុវត្តតួនាទីភារកិច្ចដូចមានចែងក្នុងមាត្រា៨៦ និងមាត្រា៨៧ នៃអនុក្រឹត្យ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់អភិបាលក្រុង ត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលក្រុងរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។ អភិបាលក្រុងត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាក្រុងអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន អភិបាលរងក្រុងត្រូវទទួលខុសត្រូវចំពោះមុខអភិបាលក្រុង លើភារកិច្ចនានាដែលបានប្រគល់ជូនហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលក្រុងត្រូវជួបប្រជុំគ្នាប្រចាំ ឆមាស ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ ក្រៅពីការប្រជុំប្រចាំឆមាស និងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលក្រុង អាចកោះប្រជុំតាមការចាំបាច់រៀងរាល់កិច្ចប្រជុំខាងលើនេះត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

យោងតាមអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក លេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៩០ បានចែងថាគណៈអភិបាលក្រុងត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុង

[៣៤] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨៦

[៣៥] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨៧

និងអភិបាលរងក្រុងហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលក្រុង និងរបៀបរបបអនុវត្តភារកិច្ចដែលបានចែងនោះ។

➢ **ចំណែកឯអភិបាលរងក្រុងត្រូវទទួលបន្ទុកការងារមួយចំនួនមានដូចខាងក្រោម**

**អភិបាលរងក្រុង ០១រូបទទួលបន្ទុកជួយអភិបាលក្រុងលើការងារដូចជា៖**

- ការងាររដ្ឋបាល
- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស
- ការងារផ្ដល់សេវារដ្ឋបាល
- ការងារអាត្រានុកូលដ្ឋាន
- ការងារលេខាធិការក្រុមប្រឹក្សា និងការងារទំនាក់ទំនងសាធារណៈ។

**អភិបាលរងក្រុង ០១រូបទទួលបន្ទុកជួយអភិបាលក្រុងលើការងារដូចជា៖**

- ការងារហិរញ្ញវត្ថុ
- ការងារថវិកា
- ការងារលទ្ធកម្មសាធារណៈ
- ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ការងារផែនការ និងគាំទ្រសង្កាត់
- ការងារស្ថិតិប្រជាជន។

**អភិបាលរងក្រុង ០១រូបទទួលបន្ទុកជួយអភិបាលក្រុងលើការងារដូចជា៖**

- ការងារពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម ការងាររ៉ែ និងថាមពល
- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារសង្គមកិច្ច អតីតយុទ្ធជននីតិសម្បទា
- ការងារសុខាភិបាល កិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ។

**អភិបាលរងក្រុង ០១រូបទទួលបន្ទុកជួយអភិបាលក្រុងលើការងារដូចជា៖**

- ការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ការងារអភិវឌ្ឍន៍សហគមន៍។

**អភិបាលរងក្រុង ០១រូបទទួលបន្ទុកជួយអភិបាលក្រុងលើការងារដូចជា៖**

- ការងារសាធារណការ និងដឹកជញ្ជូន
- ការងារទេសចរណ៍
- ការងារគ្រប់គ្រងសំរាម សំណល់រឹងរាវទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ
- ការងារដាំដើមឈើ និងសួនច្បារសាធារណៈ។

**អភិបាលរងក្រុង ០១រូបទទួលបន្ទុកជួយអភិបាលក្រុងលើការងារដូចជា៖**

- ការងារអប់រំ យុវជន និងកីឡា
- ការងារត្រួតពិនិត្យផ្ទៃក្នុង និងការងារវេទិកាសាធារណៈ
- ការងារនីតិកម្ម និងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន។[៣៦]

[៣៦] សេចក្ដីណែនាំស្ដីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបបបធ្វើការងារជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក, លេខ០៤៧សណក, ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២

# រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង




➢ **រដ្ឋបាលក្រុងនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖**

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រសង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍

- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។[៣៧]

➢ **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ៖**

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលក្រុង
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលក្រុង ផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **អង្គភាពលទ្ធកម្ម៖**

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារ ដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

---

[៣៧] អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, លេខ១៨២អនក្រ.បក, ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩, មាត្រា៩

➢ **ការិយាល័យគ្រប់គ្រងធនធានមនុស្ស៖**

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលក្រុង
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យផែនការ និងគាំទ្រសង្កាត់៖**

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ (៥) ឆ្នាំ កម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិល ផែនការសកម្មភាពនឹងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលក្រុង
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ (៥) ឆ្នាំ កម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិល ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលក្រុង
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលសង្កាត់ក្នុងក្រុងលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ (៥) ឆ្នាំ កម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិល គម្រោងនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុង
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុងតាមការកំណត់ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាសង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលសង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលសង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង៖**

- ការត្រួតពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវានានាដែលបានកំណត់ជាធរមាន
- ការត្រួតពិនិត្យលើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ការត្រួតពិនិត្យការអនុវត្តវិន័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់ បុគ្គលិករដ្ឋបាលក្រុង

- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យលេខាធិការក្រុមប្រឹក្សា៖**

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង។

➢ **ការិយាល័យអប់រំ យុវជន និងកីឡា៖**

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់លើភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល៖**

- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅដ្ឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន៖**

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលក្រុង
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង

- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលសង្កាត់ក្នុងក្រុង
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុងស្របតាមច្បាប់កំណត់
- ការពិនិត្យនីត្យានុកូលភាពលើដី និងសេចក្តីសម្រេចនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុងនៃតាមគោលការណ៍កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ៖**

- ការងារសាធារណការ និងដឹកជញ្ជូន
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ការគ្រប់គ្រងផ្សែង សម្លេង ក្លិន និងការបំពុលបរិយាកាស ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ការដាំ ការគ្រប់គ្រង និងការថែទាំដើមឈើ និងសួនច្បារសាធារណៈ
- ការគ្រប់គ្រងភ្លើងបំភ្លឺទីសាធារណៈ
- ការគ្រប់គ្រងចំណតយានយន្តសាធារណៈ
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍៖**

- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារធនធានទឹក
- ការងារអភិវឌ្ឍន៍ជនបទ
- ការងារពាណិជ្ជកម្ម
- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍

- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម៖**

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

➢ **ការិយាល័យច្រកចេញចូលតែមួយ៖**

- ការទទួល និងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[៣៨]

[៣៨] អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, លេខ១៨២អនក្រ.បក, ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩, មាត្រា១៥-២៧

# ជំពូកទី២

# ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង

# ឆ្នាំ២០២០-២០៣០

# ជំពូកទី២
# ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០

## ២.១. ផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង

តាមភាពជាក់ស្តែងក្រុងបាត់ដំបងកំពុងតែរៀបចំយុទ្ធសាស្ត្រក៏ដូចជាចក្ខុវិស័យគួរឱ្យកត់សម្គាល់ ដែលដើរតាមផែនការនៃការរៀបចំដែនដីដែលជាការកែសម្រួលរយៈពេលប្រាំ (៥) ឆ្នាំម្តងក្នុងករណីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីនៃការអភិវឌ្ឍនេះជាតម្រូវការចាំបាច់សម្រាប់បម្រើដល់ប្រយោជន៍សាធារណៈ ជាយុទ្ធសាស្ត្រមួយដែលស្របទៅតាមប្លង់គោលតាមការដាក់ចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងការអភិវឌ្ឍនេះផ្ទាល់មានគោលបំណងក្នុងការរៀបចំឱ្យក្រុងបាត់ដំបងនៅតាមសង្កាត់នីមួយៗឱ្យមានសោភ័ណភាព និងមានរបៀបរៀបរយក្នុងការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពក្នុងការជួយលើកកម្ពស់សេដ្ឋកិច្ច ការចូលរួមការពារនៃការប្រែប្រួលអាកាសធាតុក្នុងដំណើរការអភិវឌ្ឍ កំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងពង្រឹងបរិយាបទសង្គម។

ជាការពិតណាស់ការអនុវត្តគម្រោងទាំងនោះរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធឯកទេស នៅតាមទីក្រុងជាការអភិវឌ្ឍរចនាសម្ព័ន្ធក្នុងក្រុង និងតាមបណ្តាសង្កាត់នីមួយៗក្នុងក្រុងបាត់ដំបង។ ការអភិវឌ្ឍតំបន់ពាណិជ្ជកម្មតាមសង្កាត់នីមួយៗ ការគ្រប់គ្រងកាកសំណល់ ការគ្រប់គ្រងចរាចរណ៍យានយន្ត ការគ្រប់គ្រងប្រព័ន្ធទឹក ប្រព័ន្ធលូ និងការអនុវត្តតាមផែនការទីក្រុងឱ្យមានភាពរីកចម្រើន។ ដើម្បីឱ្យផែនការអភិវឌ្ឍន៍ទីក្រុងមាននិរន្តរភាពសម្រាប់ក្រុងបាត់ដំបងចេញជារូបរាងត្រូវមានការគាំទ្រដល់ផែនការក្នុងការអនុវត្តចក្ខុវិស័យនៅក្នុងឆ្នាំ២០៣០ និងតាមរយៈការអនុវត្តសកម្មភាពរបស់គម្រោងវិនិយោគអភិវឌ្ឍន៍ជាក់លាក់មួយចំនួនឆ្លើយតបទៅនឹងយុទ្ធសាស្ត្រអាទិភាពកំណត់នៅក្នុងផែនការ។[៣៩] លើសពីនេះទៅទៀត ផែនការអភិវឌ្ឍន៍ទីក្រុងបាត់ដំបងមានការគាំទ្រដល់ការសម្រេចបាននៃគោលដៅជាយុទ្ធសាស្ត្រក្នុងផែនការរៀបចំប្រព័ន្ធរចនាសម្ព័ន្ធក្រុង ឧស្សាហកម្ម សេដ្ឋកិច្ចពាណិជ្ជកម្ម ផ្លូវដឹកជញ្ជូនក្នុងទីក្រុង និងវិស័យទេសចរណ៍។

ដូច្នេះផែនការនេះមានសារៈប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់រាជធានីវិស័យឯកជនដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិក្សាស្រាវជ្រាវក្នុងការអភិវឌ្ឍដែលភ្ជាប់មកជាមួយនូវវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ការសហការគ្នាយ៉ាងមុតមាំ និងការអនុវត្តតាម

[៣៩] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី១-២

ការដាក់ចេញក្រោយពីពិភាក្សាគ្នាក្នុងដំណាក់កាលរៀបចំអនុវត្តន៍នៃដំណើរការអភិវឌ្ឍទីក្រុងបាត់ដំបងរបស់ខ្លួនសំដៅឆ្ពោះទៅរកភាពជឿនលឿនប្រកបដោយចីរភាព។[៤០]

**២.១.១. គោលបំណងក្នុងការអភិវឌ្ឍក្រុងបាត់ដំបង**

ក្រុងបាត់ដំបងមានគោលបំណងក្នុងការអភិវឌ្ឍក៏ដូចជា ការលើកស្ទួយវិស័យនៅក្នុងក្រុងឱ្យមានភាពល្អប្រសើរដែលមានរចនាសម្ព័ន្ធក្រុង កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សេដ្ឋកិច្ច សាធារណការ សណ្តាប់ធ្នាប់ក្រុងដែលសុទ្ធសឹងតែជាគោលបំណងក្នុងការអភិវឌ្ឍបន្ថែមទៀត។ ជាពិសេសការកសាងនៅផ្លូវក្រៅ និងក្នុងក្រុងបាត់ដំបងឱ្យមានភាពល្អប្រសើរតាមស្តង់ដារ ក៏ដូចជាសមស្របតាមផែនការគោលទាំងពីរដែលបានដាក់ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ដើម្បីរៀបចំរចនាសម្ព័ន្ធក្រុងឱ្យបានល្អត្រូវមានផ្នែកសំខាន់ក្នុងការអភិវឌ្ឍនេះជាការផ្តល់នៅសក្តានុពលសម្រាប់ក្រុមហ៊ុនវិនិយោគ ដើម្បីជាគោលដៅសេដ្ឋកិច្ចសំខាន់សម្រាប់ក្រុងបាត់ដំបង និងតាមបណ្តាសង្កាត់នាពេលបច្ចុប្បន្ន។ ការអភិវឌ្ឍបែបនេះអាចជាការពន្លឿនភាពជោគជ័យបន្ថែមទៀតនៃក្រុងបាត់ដំបងផ្ទាល់ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការកែលម្អទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឱ្យបានសមស្រប។ ជាពិសេសតំបន់សេដ្ឋកិច្ចក្រុងតាមសង្កាត់នីមួយៗកំពុងតែមានការកសាងជាបន្តបន្ទាប់ ដើម្បីជាការអភិវឌ្ឍក្នុងគម្រោងតំបន់សេដ្ឋកិច្ចតាមសង្កាត់ឱ្យមានការកើនឡើងដោយជំរុញក្នុងការអភិវឌ្ឍតាមតំបន់ និងតាមបណ្តាសង្កាត់នានាក្នុងក្រុងបាត់ដំបងឱ្យមានភាពរីកចម្រើន ចំណែកឯការជំរុញសេដ្ឋកិច្ចវិញមានការវិនិយោគជាច្រើនពីក្រុមហ៊ុនឯកជននានាដែលជាដើមទុនយ៉ាងធំក្នុងការអភិវឌ្ឍក្រុងបាត់ដំបង។ កន្លងមកតាមវិស័យឧស្សាហកម្មមួយចំនួនជាផលិតផលដែលផលិតក្នុងក្រុងតាមបណ្តាសង្កាត់និងតាមបណ្តាស្រុកក្នុងខេត្តបាត់ដំបងមានការប្រកួតប្រជែងជាមួយផលិតផលនាំចូលនៃការបង្កើនសេដ្ឋកិច្ចគ្រួសារតាមរយៈប្រកបរបរអាជីវកម្មខ្នាតតូច អាជីវកម្មខ្នាតធំដែលជាប្រភេទតាមគ្រួសារ និងតាមបណ្តាក្រុមហ៊ុនវិនិយោគការនាំចូលពីបណ្តាប្រទេសជិតខាងក៏ជាការចូលរួមមួយចំណែកនៃការអភិវឌ្ឍដែរ។ លើសពីនេះទេសចរណ៍ក៏ជាកត្តាសំខាន់ដែលនាំឱ្យមានសក្តានុពលខ្លាំងអាចអូសទាញភ្ញៀវទេសចរមកទស្សនានៅក្នុងតំបន់ធម្មជាតិតាមរមណីយដ្ឋានជាច្រើន នៅក្នុងតំបន់នោះដែលជាសរសៃសេដ្ឋកិច្ចមួយដែលគួរតែមានការអភិវឌ្ឍយ៉ាងខ្លាំងក្លា និងមានភាពច្នៃប្រឌិតខ្ពស់ឱ្យទៅជាកន្លែងដែលមានភាពទាក់ទាញ។ សម្រាប់ការអភិវឌ្ឍនេះដែលរដ្ឋបាលខាងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈកាន់តែមានភាពសំខាន់សម្រាប់ក្រុង និងតាមបណ្តាសង្កាត់នៃក្រុងបាត់ដំបងទាំងមូលក្នុងការពង្រឹងការអនុវត្តគោលការណ៍អភិបាលកិច្ចល្អរបស់រដ្ឋបាលនឹងពង្រឹងនៅការអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ការបន្តថែរក្សាពង្រឹងបន្ថែមលើការងារសន្តិសុខសង្គម សុខសុវត្ថិភាព

[៤០] សេចក្តីណែនាំពីបច្ចេកទេសស្តីពីការរៀបចំក្រុង និងកសាងផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបង, លេខ០២៦/២៣អអរ, ទំព័រទី១

សណ្ដាប់ធ្នាប់សាធារណៈជូនដល់ប្រជាពលរដ្ឋក្នុងការរៀបចំសោភ័ណភាពទីក្រុងតាមរយៈការអនុវត្តនូវផែនការទីក្រុងឆ្លាតវៃ។[៤១]

## ២.១.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុងបាត់ដំបង

ដើម្បីអនុវត្តតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្រុងបាត់ដំបងបានយកចិត្តទុកដាក់ក្នុងការស្ដារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសក្នុងការលើកស្ទួយតំបន់ពាណិជ្ជកម្ម សេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ ប្រព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធក្រុង និងសណ្ដាប់ធ្នាប់ក្រុង។ល។ ផ្ដោតលើការសាងសង់នៃការអភិវឌ្ឍនៅផ្លូវថ្នល់សំខាន់ៗ ព្រមទាំងប្រព័ន្ធផ្លូវក្នុងក្រុងទាមទារឱ្យមានការអភិវឌ្ឍឱ្យបានឆាប់រហ័សសម្រាប់តម្រូវការរបស់ប្រជាជន។ ការសាងសង់ផ្លូវសាធារណៈ ជាកត្តាដ៏សំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការអភិវឌ្ឍនៅក្នុងផែនការដែលដាក់សម្រាប់ប្រជាជនប្រើប្រាស់ក្នុងការធ្វើដំណើរឱ្យមានភាពងាយស្រួល និងជាការចូលរួមសហការការអភិវឌ្ឍនៅពេលខាងមុខក្នុងផែនការការងាររបស់ក្រុងបាត់ដំបងផ្ទាល់ ការស្ដារនៅប្រព័ន្ធទឹកបន្ថែម ការដាក់ប្រព័ន្ធលូតាមបណ្ដាផ្លូវក្នុងក្រុង ជាការជៀសវាងនៅបញ្ហាការកកស្ទះដែលធ្វើឱ្យមានការលិចទឹកក្នុងក្រុងដែលបណ្ដាលឱ្យបាត់បង់សោភ័ណភាព។ ម៉្យាងវិញទៀតកសិកម្មជាផ្នែកសេដ្ឋកិច្ចសំខាន់សម្រាប់ប្រជាជនក្នុងក្រុងបាត់ដំបង និងតាមបណ្ដាសង្កាត់ដោយទាមទារក្នុងការជួយអភិវឌ្ឍន៍បន្ថែមឱ្យមានសក្ដានុពលនៅតាមសង្កាត់ក្នុងក្រុងមួយចំនួនក្នុងការដាំដុះ វិធីសាស្ត្រក្នុងការផលិត ការជ្រើសរើសពូជដាំដុះ ការថែទាំយ៉ាងណាឱ្យទទួលបានទិន្នផលខ្ពស់សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងប្រទេស និងមានការវិនិយោគធំៗច្រើនពីប្រជាជនក្នុង និងខាងក្រៅប្រទេស។[៤២]

ប្រព័ន្ធរដ្ឋបាលក្នុងការគ្រប់គ្រងឱ្យមានភាពច្បាស់លាស់សមស្របទៅតាមគម្រោងនៃការអនុវត្តឱ្យមានភាពជាក់លាក់ និងស្ដង់ជាការរចនាសម្ព័ន្ធក្រុងក៏រួមចំណែកក្នុងការអភិវឌ្ឍរដ្ឋបាលដែលនាំឱ្យប្រព័ន្ធដំណើរការការងារបានយ៉ាងល្អ និងមានភាពជាក់លាក់ដោយការដាក់នៅផែនការដែលមានប្រសិទ្ធភាពការអនុវត្តជាក់ស្ដែងក្នុងគម្រោង។ តំបន់ពាណិជ្ជកម្មជាផ្នែកសេដ្ឋកិច្ចនៃការអភិវឌ្ឍថ្មីក្នុងក្រុងដែលជាការចូលរួមវិនិយោគពីសំណាក់ក្រុមហ៊ុនឯកជន និងការសហការពីរដ្ឋ ដែលក្នុងដំណើរការការងារធ្វើយ៉ាងណាឱ្យក្រុងបាត់ដំបងមានភាពរីកចម្រើនមានសក្ដានុពលតាមរយៈការមើលឃើញពីភាពល្អ និងផលប្រយោជន៍នៃក្រុងបាត់ដំបងនេះ។ តំបន់ទេសចរណ៍ជាសេដ្ឋកិច្ចដែលទាក់ទាញនៅប្រាក់ចំណូលច្រើន ការចូលរួមផ្សព្វផ្សាយនៅតំបន់ធម្មជាតិ និងការចូលរួមថែរក្សានៅតំបន់រមណីយដ្ឋានទាំងការចូលរួមអភិវឌ្ឍន៍ទៅជាតំបន់ទាក់ទាញនឹងមានការច្នៃប្រឌិតថ្មីៗក្នុងការចូលរួមអនុវត្តវិធានការការពារធនធានព្រៃឈើធម្មជាតិដទៃទៀត ជំរុញការដាំដុះព្រៃឈើឡើងវិញទប់ស្កាត់សកម្មភាព

[៤១] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

[៤២] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៣-៤

ដែលនាំឱ្យមានការបំពុលបរិស្ថាន និងសេវាកម្មដើម្បីទាក់ទាញអ្នកវិនិយោគឯកជនដែលជាដៃគូរអភិវឌ្ឍន៍ដ៏សំខាន់ ឱ្យមកវិនិយោគនៅក្នុងក្រុងបាត់ដំបង។ ជាមួយគ្នានេះការលើកកម្ពស់ជំរុញនៅសេវាសុខាភិបាល ការអប់រំ ចំណេះដឹងទូទៅ ការកែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈឱ្យកាន់តែមានភាពងាយស្រួល លើកកម្ពស់ការយកចិត្តទុកដាក់ពីសុវត្ថិភាព ផាសុខភាព និងមានវិធានការច្បាស់លាស់ក្នុងការទប់ស្កាត់ក៏ដូចជាការបង្ក្រាបរាល់បទល្មើសនានាដែលកើតមានឡើងក្នុង ខេត្ត ក្រុងបាត់ដំបងឱ្យទាន់ពេលវេលាស្មើភាព និងតម្លាភាព។[៤៣]

## ២.២. ទិសដៅនៃការអភិវឌ្ឍក្រុងបាត់ដំបង

ជាការពិតណាស់ស្របតាមការដាក់ផែនការនេះជាគម្រោងការអភិវឌ្ឍក្នុងក្រុងបាត់ដំបងមានទាំងការអភិវឌ្ឍរបស់ក្រុង និងខេត្តទាំងមូលដំណាលគ្នាតែម្តងដោយការអភិវឌ្ឍរបស់ក្រុងបាត់ដំបងជា Smart City នៅក្នុងឆ្នាំ២០២៣ ដោយសារតែក្រុងបាត់ដំបងដែលត្រូវបានជ្រើសរើសជាបណ្តាញទីក្រុងវៃឆ្លាតអាស៊ានដើម្បីប្រែក្លាយទៅជាក្រុងដែលបច្ចេកវិទ្យាទំនើបមានទាំងផាសុខភាព សោភ័ណភាព សណ្តាប់ធ្នាប់ល្អ និងបរិស្ថានល្អក្នុងការរស់នៅ។[៤៤] ផែនការមួយទៀតសម្រាប់ខេត្តទាំងមូលចាប់ផ្តើមមានការអនុវត្តបណ្តើរៗដែលស្តីពីគម្រោងផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០ ទៅលើគ្រប់វិស័យនានាក្នុងការអភិវឌ្ឍបូករួមទាំងការរស់នៅ ការរៀបចំតាមប្រព័ន្ធផ្លូវសាធារណៈ ការដាក់នៅប្រព័ន្ធលូ សំយាបផ្ទះ ការលាបពណ៌សំណង់ថ្មី យីហោ លំនៅដ្ឋានរចនាសម្ព័ន្ធ ពាណិជ្ជកម្ម សេដ្ឋកិច្ច ទេសចរណ៍ និងគ្រប់ផ្នែកមួយចំនួនសំខាន់ដែលមានក្នុងក្រុងបាត់ដំបងនាពេលអនាគត។ ដោយយោងតាមសមិទ្ធផលក៏ដូចជាវឌ្ឍនភាពកន្លងមកក្រុងបាត់ដំបងទទួលបាននៅភាពជោគជ័យច្រើន តាមរយៈរបាយការណ៍របស់រដ្ឋបាលក្រុងផ្ទាល់មើលទៅលើគ្រប់វិស័យមានការរីកចម្រើនក៏ទាមទារឱ្យមាននៅការកែច្នៃ ក៏ដូចជាការអនុវត្តបន្ថែមទៀតដែលធ្វើយ៉ាងណាឱ្យក្រុងបាត់ដំបងនេះទទួលបាននៅសក្តានុពលខ្លាំងក្លាក្នុងន័យកែប្រែទៅជាបរិបទថ្មីកន្លែងថ្មីសម្រាប់ទាក់ទាញភ្ញៀវទេសចរ បូករួមការអភិវឌ្ឍតំបន់ធម្មជាតិ ការចូលរួមសហការរបស់គណៈគ្រប់គ្រងមន្ត្រីរដ្ឋបាល ក៏ដូចជាមន្ត្រីគ្រប់ជាន់ថ្នាក់ដែលដើម្បីជាជំនួយឱ្យមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ និងដើម្បីទាក់ទាញផលប្រយោជន៍ជាច្រើនសម្រាប់វិស័យដែលជាសេដ្ឋកិច្ចមូលដ្ឋានក្នុងការជួយឱ្យមានភាពល្អប្រសើរជាងមុន។[៤៥]

### ២.២.១. ចក្ខុវិស័យក្នុងការអភិវឌ្ឍក្រុងបាត់ដំបង

ដោយយោងតាមផែនការចក្ខុវិស័យដែលជាគម្រោងនៃការអភិវឌ្ឍធំ ទាមទារក្នុងការគិតគូរទៅលើគ្រប់ផ្នែកនីមួយៗក្នុងផែនការជាមុនសិន។ ដើម្បីឱ្យស្របតាមផែនការអនុវត្តតាមប្លង់គោលដែលបានរៀបចំទុកជាមុន

[៤៣] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

[៤៤] សេចក្តីប្រកាសព័ត៌មាន ស្តីពីភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តបាត់ដំបង, លេខ០២៦/២៣អអរ

[៤៥] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣

សម្រាប់ការអនុវត្តផែនការ។ ជាក់ស្តែងនេះក្រុងបាត់ដំបងកំពុងតែមានការអភិវឌ្ឍទៅលើគម្រោងផែនការរៀបចំដែនដីក្រុងបាត់ដំបងទៅជា Smart City ឆ្នាំ២០២៣បណ្តាញទីក្រុងវៃឆ្លាតអាស៊ានត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ ២០១៨មានក្របខ័ណ្ឌទីក្រុងវៃឆ្លាតអាស៊ានដែលចង្អុលបង្ហាញអំពីយុទ្ធសាស្ត្រប្រព័ន្ធគ្រប់គ្រងទីក្រុងអភិវឌ្ឍន៍ដែលត្រូវផ្តោតលើកត្តាជំរុញការងារទីក្រុងវៃឆ្លាត។ រដ្ឋបាលក្រុងបាត់ដំបងបានលើកគម្រោងអភិវឌ្ឍន៍ជំបន្ថែមចំនួន ០២ គឺការគ្រប់គ្រងលំហសាធារណៈចំណីផ្លូវ និងការគ្រប់គ្រងសំណល់រឹងរាវ។ លើសពីនេះផែនការនៃការរៀបចំដែនដីខេត្តបាត់ដំបង គឺសំដៅដល់ការរៀបចំនៃការអភិវឌ្ឍខេត្តទាំងមូលឱ្យមានរបៀបរៀបរយតាមស្តង់ដានៃការដាក់ចេញរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ ដើម្បីកំណត់តាមចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តបាត់ដំបងដល់ឆ្នាំ២០៣០ ក្របខ័ណ្ឌសេដ្ឋកិច្ចសង្គមត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ។[៤៦] ក្រុងបាត់ដំបងកំពុងតែកែប្រែក៏ដូចជាអភិវឌ្ឍន៍ខ្លួនឱ្យទទួលបានសក្តានុពល និងសហការក្នុងការវិនិយោគធំៗពីដៃគូរជាច្រើនតាមរយៈផែនការដែលផ្តោតទៅលើចក្ខុវិស័យនេះផ្ទាល់ជាតំបន់ស្នូរសេដ្ឋកិច្ចភាគពាយ័ព្យនៃប្រទេសកម្ពុជា តាមរយៈការជំរុញទៅលើការរៀបចំនៃការអភិវឌ្ឍតំបន់ស្នូរនគរូបនីយកម្មរួមមានអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សកាន់តែប្រសើរឡើង។ ចំណែកឯផ្នែកខាងក្នុងនៃក្រុងបាត់ដំបងតាមរយៈតំបន់ផលិតនៅផលកសិកម្មប្រកបដោយគុណភាពខ្ពស់មាន មជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម ការកែច្នៃមានការប្រកួតប្រជែងទាក់ទងនឹងការអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ និងតំបន់ដែលមានសមាហរណកម្មចម្រុះរវាងវិស័យសេដ្ឋកិច្ចសង្គម វប្បធម៌ និងធនធានធម្មជាតិ។

**២.២.១.១. យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍក្រុងបាត់ដំបង**

ផែនការគោលជាការអនុវត្តយុទ្ធសាស្ត្រឱ្យស្របតាមការអនុវត្តនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦។ កន្លងមកគ្រប់ផែនការនៃគម្រោងបានអនុវត្តតាមនីតិកាលទាំងបីដំណាក់កាលទទួលបាននៅលទ្ធផលគួរឱ្យគាប់ប្រសើរដោយជារួមយុទ្ធសាស្ត្រចតុកោណទាំងបីដំណាក់កាលបានបំពេញតួនាទីយ៉ាងល្អប្រសើរជារបៀបវារៈអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចកម្ពុជា ការផ្លាស់ប្តូរស៊ីជម្រៅនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច ការលើកកម្ពស់ជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើងទាំងខាងសម្ភារៈ ស្មារតី និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពការបង្កើតការងារជូនប្រជាជន ការពង្រឹងប្រសិទ្ធភាពនៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ។ នៅក្នុងនីតិកាលទី៦ សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋ សំដៅដល់ការកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយឆ្ពោះទៅគោលដៅនៃចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ដល់២០៥០ផងដែរ។[៤៧]

---

[៤៦] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៣-៤

[៤៧] យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ខែកញ្ញា ឆ្នាំ២០១៨

តាមរយៈព្រឹត្តិការណ៍ទីក្រុងវៃឆ្លាតតំណាងរដ្ឋបាលខេត្តបានបង្ហាញគម្រោងធំៗដែលកំពុងដំណើរការជាទីក្រុងវៃឆ្លាតក្រុងបាត់ដំបងដែលរួមមានតំណាងរដ្ឋាភិបាល ធនាគារខ្នាតធំ ស្ថាប័នស្រាវជ្រាវ និងក្រុមហ៊ុនធំៗជាដៃគូសហការ។ ក្រុងបាត់ដំបងមានទិសដៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព សមភាព សមធម៌លើគ្រប់វិស័យសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ល្អធានាបាននូវការទាក់ទាញការវិនិយោគគិន ភ្ញៀវទេសចរមកលេងក្នុងក្រុងបាត់ដំបងកាន់តែច្រើនឡើងទាក់ទងនឹងផែនការនេះដែលមានការប្រៀបធៀបគ្នារវាងផែនការរៀបចំដែនដីក្រុងបាត់ដំបងត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលវិភាគទិន្នន័យ រូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិសមស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុងទីប្រជុំជនគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយដីធ្លី។ ចំពោះការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ក្រុង និងខេត្តបាត់ដំបងហើយនៅឆ្នាំ២០៣០ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងមានការកើនឡើងរហូតដល់ចំនួន ៨០៦,២៦៣នាក់ (៦០%) ក្នុងវិស័យឧស្សាហកម្មកើនឡើងដល់ចំនួន ៨០៦,២៦នាក់ (៦%) និងវិស័យសេវាកម្មកើនដល់ចំនួន ៤៥៦,៨៨៣នាក់ (៣៤%)។

### ២.២.១.២. ទិសដៅផែនការក្នុងការអនុវត្តក្រុងបាត់ដំបង

ជាការពិតណាស់ការអនុវត្តពីរាជរដ្ឋាភិបាលក្នុងការដាក់ផែនការរៀបចំដែនដីក្រុងបាត់ដំបងក្នុងការអភិវឌ្ឍចក្ខុវិស័យឆ្នាំ២០៣០រួមមាន ការរៀបចំគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ការគ្រប់គ្រងដែនការពារអភិរក្ស និងធនធានធម្មជាតិ ការរៀបចំក្រុងបាត់ដំបងក្នុងការចូលរួមជាគម្រោងទីក្រុងជា Smart City និងការងារវឌ្ឍនភាពនៃការរៀបចំសោភ័ណភាពសណ្តាប់ធ្នាប់សាធារណៈតាមទីប្រជុំជនក្រុងតាមសង្កាត់នីមួយៗ និងតាមបណ្តាស្រុកនៃខេត្តបាត់ដំបង។ តាមរយៈព្រឹត្តិការណ៍របស់បណ្តាទីក្រុងឆ្លាតអាស៊ានបានធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនរួមមាន ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទេសចរណ៍ (MLIT) ប្រទេសជប៉ុនអង្គការ UNESCAP ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមហ៊ុនជប៉ុន។ ដើម្បីឱ្យផែនការក្នុងការរៀបចំក្រុងបាត់ដំបងក្លាយជាទីក្រុងវៃឆ្លាតដោយផ្តោតលើគុណភាពប្រព័ន្ធគមនាគមន៍ ការកសាងរចនាសម្ព័ន្ធថ្មី បរិស្ថានប្រព័ន្ធរំដោះទឹក ប្រព័ន្ធលូ។ ការលើកកម្ពស់ការយល់ដឹងពីសាធារណៈអំពីការគ្រប់គ្រងសំណង់ក៏ដូចជាការអនុវត្តរចនាសម្ព័ន្ធការសាងសង់ផ្សាររាត្រី ការកំណត់ទីតាំងសម្រាប់អ្នកលក់ដូរតាមចញ្ចើមផ្លូវ ការកែលម្អផ្លូវ ការអភិវឌ្ឍផ្នែកសង្គម ការសាងសង់បណ្តុះបណ្តាលការលក់ដូរនៅតាមផ្លូវ ការគ្រប់គ្រងតម្រង់ទិសការអភិវឌ្ឍ ការអភិរក្សលើតំបន់អគារចាស់ៗដែលជាកន្លែងប្រវត្តិសាស្ត្រ និងការកែប្រែក្នុងការលាបព័ណ៌ជាថ្មីសម្រាប់ការអភិវឌ្ឍតែប៉ុណ្ណោះ។ ជាពិសេសការផលិត កសិកម្ម ឧស្សាហកម្មកែច្នៃ កសិផលទាំងបរិមាណគុណភាពសម្រាប់បំពេញ

តម្រូវការក្នុងប្រទេស ការនាំចេញនាំចូលក្នុងការពង្រឹងលើសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទំនាក់ទំនងវប្បធម៌ក្នុងតំបន់ស្នូរជាយុទ្ធសាស្ត្រជួរមុខ។

លើសពីនេះការអភិវឌ្ឍផែនការរៀបចំដែនដីចក្ខុវិស័យឆ្នាំ២០៣០នៃការរៀបចំក្រុងបាត់ដំបងក្នុងការចូលរួមជាគម្រោងទីក្រុង Smart City ដែលជាការដាក់ផែនការរបស់រដ្ឋាភិបាលដែលមានគោលដៅសំខាន់ជាស្នូរក្នុងការអភិវឌ្ឍក្នុងក្រុង និងខេត្តបាត់ដំបងផ្ទាល់ តំបន់នៃការសាងសង់ជាផ្នែកមួយក្នុងការទាក់ទងនគរូបនីយកម្មដែលការបែងចែកតាមកម្រិតខ្ពស់ កម្រិតមធ្យម និងកម្រិតទាបដែលអាស្រ័យតាមទីតាំង។ ម្យ៉ាងវិញទៀតអាចធ្វើឱ្យការរស់នៅមានភាពល្អប្រសើរឡើងក្នុងឱកាសការងារ ការធ្វើពាណិជ្ជកម្ម ការចូលរួមការអភិវឌ្ឍ ការអនុវត្តគម្រោងនេះរដ្ឋបាលក៏បានខិតខំតម្រង់ទិសការងារអភិវឌ្ឍន៍ឱ្យស្របតាមគោលគំនិតទីក្រុងវៃឆ្លាតដោយមានការចូលរួមពីរដ្ឋាភិបាល ទទួលបានសមិទ្ធផលដូចជាការលើកកម្ពស់សោភ័ណភាពសណ្តាប់ធ្នាប់តាមដងផ្លូវមួយចំនួនក្នុងក្រុងបាត់ដំបង ការរៀបចំផែនទីបង្ហាញផ្លូវ និងការតម្រង់ទិសអភិវឌ្ឍន៍ស្របតាមផែនការនៃការប្រើប្រាស់ដីក្រុងបាត់ដំបងប្រកបដោយចីរភាព និងភាពវៃឆ្លាតហើយមានការចុះអនុស្សារណៈយោគយល់ក្នុងការសហការគ្នាជាមួយដៃគូក្រុមហ៊ុននានា។[៤៨] ដើម្បីសិក្សាជំរុញនៃការអនុវត្តគម្រោងទីក្រុងវៃឆ្លាតរបស់ក្រុងបាត់ដំបងដែលមានការផ្តោតលើចំណុចសំខាន់ក្នុងការអភិវឌ្ឍរួមមាន ពាណិជ្ជកម្មសម្រាប់ក្នុងក្រុងផ្ទាល់ដើម្បីកែប្រែមុខមាត់ថ្មីឱ្យក្រុងបាត់ដំបងទទួលបានភាពល្អប្រសើរជាងមុនទៀត។ តាមការវិនិយោគពីសហគ្រាសធំៗមួយចំនួនគោលដៅឃើញពី ផលប្រយោជន៍តទិ្ធពលធនធានក្នុងក្រុងបាត់ដំបងដែលអាចជាផលចំណេញ។ ចំណែកឯកសិកម្មជាពិសេសដំណាំស្រូវ ផ្លែឈើហូបផ្លែ បន្លែ និងដំណាំចម្ការដែលជាដំណាំនាំមុខគេក្នុងក្រុងក៏ដូចជាខេត្តទាំងមូលផ្ទាល់ជាគ្រឹះសម្រាប់សេដ្ឋកិច្ច ដោយមានការបូករួមដំណាំមួយចំនួនទៀត និងការចិញ្ចឹមសត្វផ្សេងៗ។ ម៉្យាងវិញទៀតផ្នែកឧស្សាហកម្មជាការអនុវត្តនៅការកែច្នៃកសិផលដោយមានការចុះបញ្ជីផ្លាកសម្គាល់ភូមិសាស្ត្រទំនិញត្រឹមត្រូវដែលជាការទទួលស្គាល់នៅគុណភាពរបស់ផលិតផលក្នុងក្រុងបាត់ដំបង ប្រកបដោយគុណភាពក៏ដូចមាននៅការប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារជាតិ និងអន្តរជាតិផងដែរ។ តំបន់ទេសចរណ៍ធម្មជាតិក្នុងក្រុងបាត់ដំបងផ្ទាល់មានសុទ្ធតែជា តំបន់ប្រវត្តិសាស្ត្រ តំបន់ធម្មជាតិ វប្បធម៌ ធនធានធម្មជាតិប្រកបដោយចីរភាពមានចំនួន ៣៩ទីតាំង។[៤៩]

### ២.២.២. ការតម្រង់ទិសក្នុងការអភិវឌ្ឍក្រុងបាត់ដំបង

តាមភាពជាក់ស្តែងក្នុងការតម្រង់ទិសនៃការអភិវឌ្ឍយុទ្ធសាស្ត្រដែលបានអនុវត្តមួយរយៈនេះទទួលបានដោយរលូនមានភាពឆាប់រហ័សក្នុងការងារ ដែលអាចធ្វើឱ្យមានភាពល្អប្រសើរជាងមុនក្នុងការរំពឹងថាទទួលបាន

[៤៨] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣

[៤៩] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៤

នៅសមិទ្ធផលល្អក្នុងកិច្ចការបន្ទាប់ដែលក្រោយពីមានការដាក់ ផែនការ ប្លង់គោល ក៏ដូចជាការពិភាក្សារួមភាពជាដៃគូ និងថវិកាហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ ដោយមានការកំណត់ទិសដៅគោលបំណងក្នុងការជួចផ្តើមជំរុញរបស់រដ្ឋាភិបាល រដ្ឋបាលខេត្ត និងក្រុង ការចូលរួមសហការរបស់មន្ទីរអង្គភាព និងការសហការជាដៃគូអភិវឌ្ឍន៍នានា និងប្រជាជន ស្របតាមការរៀបចំក្នុងការតម្រង់ទិសជាការចាប់ផ្តើមនៃយុទ្ធសាស្ត្រការអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ក្នុងក្រុងបាត់ដំបង និងទទួលបានការយកចិត្តទុកដែលជាកត្តាជំរុញនៃការអភិវឌ្ឍរបស់ក្រុងទាំងមូល។[៥០]

**២.២.២.១. យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នគរូបនីយកម្មក្រុងបាត់ដំបង**

ការអភិវឌ្ឍស្របតាមគោលគំនិតទីក្រុងវៃឆ្លាតដែលជាផែនការគោលថ្មីនៃលទ្ធផលការខិតខំ និងការចូលរួមសហការពីរដ្ឋាភិបាលក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ រដ្ឋបាលក្រុងជាគោលដៅលើកកម្ពស់សោភ័ណភាពសណ្តាប់ធ្នាប់តាមដងផ្លូវ ការរៀបចំស្របតាមផែនការ និងការអនុវត្តឱ្យល្អប្រសើរជាងមុនតាមរយៈការរៀបចំសំយាបថ្នះ ស្លាកយីហោ ការផ្សព្វផ្សាយពាណិជ្ជកម្មតាមដងផ្លូវសំខាន់ៗមួយចំនួនក្នុងក្រុងបាត់ដំបង។ ផែនទីបង្ហាញផ្លូវតាមប្លង់គោលអភិវឌ្ឍន៍ក្រុងបាត់ដំបងប្រកបដោយចីរភាព និងការអនុវត្តទៅក្រុងវៃឆ្លាត ការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រុមហ៊ុនជប៉ុនចំនួន ០៣ក្រុមហ៊ុន។ ដើម្បីជាជំនួយសិក្សាជំរុញការអនុវត្តគម្រោងទីក្រុងវៃឆ្លាតក្រុងបាត់ដំបងបានលើកឡើងក្នុងការពិភាក្សាជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើគម្រោងគ្រប់គ្រងហិរញ្ញវត្ថុឆ្លាតលើសេវាប្រមូលសំរាម ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្របង្កើតឱ្យមានការបង់សេវាប្រមូលសំរាមតាមអនឡាញ និងគម្រោងផែនការធំៗមួយចំនួនដែលរដ្ឋបាលកំពុងសិក្សាក្នុងទិសដៅដើម្បីប្រែក្លាយក្រុងបាត់ដំបងក្លាយជា Smart City។ ដោយការអនុវត្តបន្តសហការជាមួយដៃគូលើគម្រោងការគ្រប់គ្រងក្នុងថវិកាសំណង់រឹង សួនឧស្សាហកម្មបៃតងបានរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធផ្លូវដើរជាប្រព័ន្ធឱ្យស្របតាមបច្ចេកទេសវិទ្យា បច្ចេកទេសក្នុងការជំរុញស្ទឹងសង្កែវៃឆ្លាតបង្កើតភាពទាក់ទាញតាមដងស្ទឹងសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ក្នុងនោះរួមមានគម្រោងកែប្រែព្រលានយន្តហោះថ្មីវាលបែកចាន គម្រោងផ្លូវអាកាស គម្រោងអភិវឌ្ឍន៍ផ្លូវដែកល្បឿនលឿន គម្រោងកសាងទីលានចាក់សំរាមថ្មីដើម្បីដោះស្រាយសំរាមពីទីក្រុង គម្រោងស្តារប្រព័ន្ធលូក្រោមដី ជាពិសេសការសាងសង់នៅគម្រោងផ្លូវមួយចំនួនក្នុងការផ្សារភ្ជាប់ក្នុងការធ្វើដំណើរដែលជាផែនការអភិវឌ្ឍដែរ។[៥១] ផែនការក្រុងនៃការសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម ការវិនិយោគផលិតផលកែច្នៃ តំបន់ទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតក្នុងក្រុងដែលជាផ្នែកយ៉ាងសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍឱ្យក្រុងកាន់តែមានសក្តានុពលបន្ថែមទៀតក្នុងការនាំឱ្យមានភាពល្អប្រសើរ។

[៥០] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣

[៥១] សេចក្តីប្រកាសព័ត៌មានស្តីពីភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តបាត់ដំបង, លេខ០២៦/២៣អអរ

អាស្រ័យហេតុនេះក្រុងបាត់ដំបងមានការបែងចែកជាពីរក្នុងការអភិវឌ្ឍក្នុងតំបន់អភិវឌ្ឍន៍ និងក្រៅតំបន់អភិវឌ្ឍន៍។ តាមរយៈផែនការក្នុងតំបន់អភិវឌ្ឍន៍ជាទិសដៅបន្តរួមមានការចូលរួម ការត្រួតពិនិត្យប្រព័ន្ធផ្លូវដែលមានការដាក់ចេញក្នុងការអនុវត្តដូចជា ផ្លូវតាមដងស្ទឹងមុខសាមន្ទីរ ការកែប្រែផ្លូវធ្វើដំណើរជាថ្មី ការដំឡើងស្លាកយីហោ និងសំយាប ការបើកច្រើរជើងផ្លូវលេខ២ (ចន្លោះផ្សារណាត់) ការតាំងលក់ទំនិញនៅលើដីចំណីផ្លូវ ការតាមដានត្រួតពិនិត្យជាប្រចាំ ការរៀបចំសណ្តាប់ធ្នាប់ជុំវិញផ្សារណាត់ដែលជាគម្រោងក្នុងការអភិវឌ្ឍខាងក្នុងនៃផែនការតាមតំបន់នីមួយៗក្នុងក្រុងបាត់ដំបង។ សម្រាប់ក្រៅតំបន់វិញទាក់ទងនឹងផ្សារក្នុងក្រុង ផ្សារបឹងឈូក ផ្សារលើ ផ្សារ១៣មករា សួនច្បារត្រើយខាងកើត ស្ពាន១៣មករា ដល់ស្ពានថ្មី ដោយផ្លូវជាតិលេខ៥ រង្វង់មូលលោកតាដំបងក្រញូងដល់រង្វង់មូលព្រាបស រង្វង់មូលលោកតាដំបងក្រញូងដល់ស្ពានថ្មថ្មីដល់រង្វង់មូលយាយទេពមានការធ្វើបន្តការរៀបចំកាត់ខ្សែកាប្លិ៍អុបទិប និងទម្លាក់ចូលបំពង់ក្រោមដីរួមទាំងការអនុវត្តសណ្តាប់ធ្នាប់តាមបណ្តាស្រុកដោយបន្តរៀបចំសណ្តាប់ធ្នាប់ ដោយផ្តោតសំខាន់បីយ៉ាងទីប្រជុំជនចំណតរួមមានរមណីយដ្ឋានទេសចរណ៍ច្រកទ្វារព្រំដែន។ ក្រុងបាត់ដំបងជាមជ្ឈមណ្ឌលក្នុងការអភិវឌ្ឍនគរូបនីយកម្មរួមមានការអភិវឌ្ឍតាមលំនៅដ្ឋានជាការសាងសង់ក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍត្រូវធ្វើឡើងក្នុងតំបន់មួយចំនួនដោយជាតម្រូវការលំនៅដ្ឋានរបស់ប្រជាជនក្នុងក្រុងទីប្រជុំ និងតំបន់សេដ្ឋកិច្ច ជាពិសេសដែលត្រូវជាតំបន់អភិវឌ្ឍន៍សមាហរណកម្មចម្រុះដែលជាការអភិវឌ្ឍបែបលក្ខណៈជាផ្ទះបុរីសម្រាប់ការរស់នៅដែលផែនការគម្រោងលំនៅដ្ឋានតំបន់ស្នូរយុទ្ធសាស្ត្រមុនឈានដល់ការអភិវឌ្ឍនគររូបនីយកម្ម និងសំណង់រដ្ឋបាលខេត្តក្រុងត្រូវមានយុទ្ធសាស្ត្រមួយចំនួនក្នុងការអនុវត្តការងារ ដើម្បីជួយឱ្យប្រជាជនមានការយល់ដឹងលើគម្រោងតាមការផ្សព្វផ្សាយដែលជាផ្នែកមួយក្នុងការនាំឱ្យលំនៅដ្ឋានប្រជាជនក្នុងក្រុងប្រកបដោយស្តង់ដា។[៥២] ចំណែកការសាងសង់ គឺជាផ្នែកមួយក្នុងការបង្ហាញរចនាសម្ព័ន្ធសំណង់នីមួយៗតាមកម្រិតរួមមានប្រភេទខ្ពស់ មធ្យម និងទាបលើគ្រឹះសំណង់ កម្ពស់ជម្រៅក្នុងមូលដ្ឋាននៃការសាងសង់តាមតំបន់មួយៗលំនៅដ្ឋានក្នុងក្រុងមានការអភិវឌ្ឍច្រើនពីសំណាក់ខាងរដ្ឋបាលក្រុង ដោយសំណង់អគារនៅក្នុងក្រុងមានកម្ពស់ខ្ពស់ត្រឹមតែ ០៨ជាន់ប៉ុណ្ណោះតាមភាពជាក់ស្តែងក្នុងក្រុងបាត់ដំបង។ ដោយគោលបំណងជួយអភិវឌ្ឍន៍សំណង់ខូចខាត និងមានភាពចាស់ទ្រុតទ្រោមដើម្បីកែប្រែជាថ្មីក្នុងការជួយដោះស្រាយជៀសវាងនៅគ្រោះថ្នាក់មួយចំនួន ការរៀបចំតាមចិញ្ចើមផ្លូវមុខលំនៅដ្ឋានតាមសំយាបផ្ទះរបស់ប្រជាពលរដ្ឋឱ្យមានរបៀបរៀបរយស្របទៅតាមស្តង់ដារបស់រដ្ឋបាលក្រុងបាត់ដំបង។

[៥២] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៤-៦

### ២.២.២.២. ការគ្រប់គ្រងប្រព័ន្ធនៃការដឹកជញ្ជូន និងអភិវឌ្ឍន៍រចនាសម្ព័ន្ធក្រុង

តាមភាពជាក់ស្តែងក្នុងក្រុងបាត់ដំបងកំពុងតែមានការអភិវឌ្ឍ និងការអនុវត្តការគ្រប់គ្រងប្រព័ន្ធជាច្រើនជាពិសេសទាក់ទងលើវិស័យដឹកជញ្ជូន និងរចនាសម្ព័ន្ធក្នុងក្រុង ប្រព័ន្ធនៃការដឹកជញ្ជូនត្រូវធ្វើការអភិវឌ្ឍថ្មីជួសជុលនឹងកែលម្អដើម្បីបង្កើននៅសមត្ថភាពការអភិវឌ្ឍសំខាន់ៗដូចជា បណ្តាផ្លូវថ្នល់ រថភ្លើង និងអាកាសយានដ្ឋានដែលជាការអភិវឌ្ឍមួយផ្នែកក្នុងប្រព័ន្ធដឹកជញ្ជូនតាមរយៈបណ្តោយផ្លូវថ្នល់រួមមាន ផ្លូវថ្នល់សម្រាប់ភ្ជាប់ពីស្ពានអភិវឌ្ឍន៍មួយទៅស្ពានអភិវឌ្ឍន៍មួយទៀត គឺជាការអភិវឌ្ឍផ្លូវថ្នល់នៅផ្នែកខាងជើងបណ្តោយផ្លូវនៃផ្នែកខាងត្បូងដើម្បីធានាក្នុងការដឹកជញ្ជូន។ បណ្តាញផ្លូវដែលមានស្ថានីយរថភ្លើងក្នុងក្រុងបាត់ដំបងដែលជាការអភិវឌ្ឍថ្មីនឹងជាសមិទ្ធផលមួយក្នុងក្រុងដែលអាចជួយដល់ការធ្វើដំណើរអាជីវកម្មរបស់ប្រជាជនក្នុងក្រុង និងតាមបណ្តាស្រុកនានាក្នុងក្រុងបាត់ដំបងទាំងស្រុងដែលជាស្ថានីយរថយន្តក្រុងបាត់ដំបងដែលត្រូវបង្កើតក្នុងផែនការអភិវឌ្ឍន៍ឆ្នាំ២០៣០។ ចំណែកឯផ្លូវអាកាសវិញ ក៏មានការជួសជុលឡើងវិញនៅអាកាសយានដ្ឋានក្រុងបាត់ដំបងនៅតាមបណ្តោយផ្លូវជាតិលេខ៥ ដែលមិនអាចបង្កឱ្យមានការរំខាន ឬហានិភ័យផ្សេងៗដល់តំបន់ពាណិជ្ជកម្មលំនៅដ្ឋានសម្រាប់ជាទីតាំងទាមទារឱ្យមានការគិតគូច្រើនរួមទាំងផលវិជ្ជមាន និងអវិជ្ជមានដើម្បីធ្វើយ៉ាងណាឱ្យទីតាំងថ្មីសម្រាប់សាងសង់ព្រលានយន្តហោះដែលបានកំណត់អាចដំណើរការក្នុងការសាងសង់ប្រកបដោយភាពរលូននិងជោគជ័យក្នុងការងារដើម្បីត្រៀមលក្ខណៈសម្រាប់ការអភិវឌ្ឍលើវិស័យដឹកជញ្ជូនតាមផ្លូវអាកាស និងវិស័យទេសចរណ៍នាពេលអនាគត។[៥៣]

ហេដ្ឋារចនាសម្ព័ន្ធដែលមានការអភិវឌ្ឍបន្ថែមទៀតរួមមាន ប្រព័ន្ធប្រឡាយទឹកដែលមានសក្តានុពលគ្របដណ្តប់ដល់តំបន់ផលិតកម្មស្រូវទូទាំងក្រុងមានការជួយជំរុញក្នុងការអភិវឌ្ឍកសាងអាងទឹកសំខាន់ៗដែលមានបីកន្លែងបន្ថែមទៀតក្នុងការជួយផ្គត់ផ្គង់នៅប្រព័ន្ធធារាសាស្ត្រក្នុងក្រុង។ ម៉្យាងវិញទៀតក្នុងការផ្គត់ផ្គង់នៅតាមតំបន់ខ្ពង់រាបមួយចំនួនក៏មានសក្តានុពលសម្រាប់ដំណាំកសិកម្មដែលជាការអភិវឌ្ឍក្នុងរយៈពេលវែងមួយក្នុងការការពារប្រព័ន្ធជីវចម្រុះ ការកែលម្អគុណភាពធនធានដីឡើងវិញទាំងផ្នែកគីមីសាស្ត្រ និងរូបសាស្ត្រ។ ការអនុវត្តក្នុងការប្រើប្រាស់បច្ចេកទេសវិស្វកម្មទំនើបដើម្បីគ្រប់គ្រងសណ្ឋានដី និងចរន្តនៃលំហូរទឹកសម្រាប់ផ្គត់ផ្គង់កសិកម្មឧស្សាហកម្មទាំងគុណភាព ការលើកកម្ពស់ជួយក្នុងការផ្សព្វផ្សាយទីផ្សារសម្រាប់ផលិតផលក្នុងស្រុក។ ដោយមានការចុះបញ្ជីផ្លាកសម្គាល់ភូមិសាស្ត្រទំនិញដែលផលិតផលក្នុងក្រុងបាត់ដំបងមានការជួយបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការចិញ្ចឹមសត្វ។[៥៤]

[៥៣] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣

[៥៤] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៥

ទឹកជាកត្តាសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធទឹកស្អាត អនាម័យ រួមទាំងប្រព័ន្ធបណ្ដាញចែកចាយទឹកស្អាតរួមមាន ស្ដានីយ និងរោងចក្រផលិតទឹកស្អាតនៅតាមបណ្ដាញក្នុងទីប្រជុំជនដើម្បីចែកចាយទឹកស្អាតដទៃទៀតនៅតាម ភូមិ ឃុំ ទាំងអស់។ ចំណែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសឧស្សាហកម្មសំខាន់ៗដែលត្រូវធ្វើការអភិវឌ្ឍកែលម្អ និងពង្រីកបន្ថែម គឺប្រភពថាមពល និងបណ្ដាចែកចាយអគ្គិសនីសម្រាប់ផ្គត់ផ្គង់ក្នុងក្រុងបាត់ដំបងទាំងមូលក្នុងការតភ្ជាប់ខ្សែបញ្ជូនអគ្គិសនីចាប់ពីទិសខាងជើង និងខ្សែបញ្ជូនអគ្គិសនីភ្លោះមកពីទិសខាងត្បូង ការបង្កើតនៅទំនប់អគ្គិសនីវារីបាត់ដំបង១ ដែលមានកម្លាំងទំហំ ២៤មេហ្គាវ៉ាត់ការបង្កើតនៅទំនប់អគ្គិសនីវារីបាត់ដំបង២ (ដែលទំនប់ពីរនេះកំពុងសិក្សា) និងការសិក្សាមានកម្លាំងទំហំ ៣៦មេហ្គាវ៉ាត់ការបង្កើតនៅទំនប់អគ្គិសនីវារីបាត់ដំបង៣ ដែលមានកម្លាំងទំហំ ១៣មេហ្គាវ៉ាត់ (កំពុងដាក់ដំណើរការ)។[៥៥] រីឯតាមបណ្ដាញទូរគមនាគមន៍ដែលជាបណ្ដាញក្នុងការចែកចាយតាមស្ថានីយទូរគមនាគមន៍តាមក្រុងទីប្រជុំជន ដើម្បីការគ្រប់គ្រងសំណល់រឹងរាវដែលបានកំណត់យន្តការគ្រប់គ្រងសំណល់រឹងរាវតាមការកំណត់មធ្យោបាយសម្រាប់ការប្រមូលសំណល់រឹង និងរាវរួមមានទីលានបច្ចេកទេសគ្រប់គ្រង បូកបញ្ចូលនៅការអនុវត្តគោលការណ៍នៃការកាត់បន្ថយការប្រើប្រាស់ឡើងវិញនៃការកែច្នៃក្នុងការជំរុញវិស័យឯកជនឱ្យចូលរួមក្នុងផែនការក្នុងការវិនិយោគលើការគ្រប់គ្រងសំណល់ ការកែលម្អពង្រឹងបន្ថែមបណ្ដាញបង្ហូរលូ និងតាមបទដ្ឋានបច្ចេកទេសមុនពេលបង្ហូរចូលបណ្ដាញលូសាធារណៈ និងការគ្រប់គ្រងព្រមទាំងការកែច្នៃនៅសំណល់រាវដោយបានកំណត់នៅក្នុងការអភិវឌ្ឍឧស្សាហកម្មក្នុងក្រុងបាត់ដំបងរួមមានអាងប្រព្រឹត្តិកម្មទឹកកង្វក់ឱ្យមានសមត្ថភាពតាមបទដ្ឋានបច្ចេកទេសដែលបានកំណត់ជាគោលការណ៍ក្នុងការជំរុញម្ចាស់រោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម អាជីវកម្ម សណ្ឋាគារ សេវាកម្មផ្សេង និងលំនៅដ្ឋានទាំងអស់ត្រូវរៀបចំអាងប្រព្រឹត្តកម្មទឹកកង្វក់ឱ្យបានសមស្រប។[៥៦]

### ២.២.៣. ការអនុវត្តសកម្មភាពតាមវិស័យ

ជាការពិតណាស់ក្នុងការអនុវត្តនេះដើរតាមផែនការការងារជាគោលដែលក្នុងសកម្មភាពជាក់ស្ដែងតាមវិស័យនីមួយៗរួមចំណែកលើការរីកចម្រើនទាំងការកែលម្អដោយរាជរដ្ឋាភិបាល និងរដ្ឋបាលក្រុងកំពុងតែមានភាពស្វះស្វែងក្នុងការពន្លឿនការងារឱ្យទាន់ពេលវេលាស្របតាមការដាក់ចេញនៃផែនការ។ ជាពិសេសការកសាងប្រព័ន្ធផ្លូវធ្វើដំណើរក្នុងក្រុងបាត់ដំបង និងផ្លូវទៅតាមបណ្ដាសង្កាត់នីមួយៗក៏ដូចជាតាមបណ្ដាស្រុកក្នុងនៃខេត្តបាត់ដំបងទាំងមូល រីឯការស្ដារប្រព័ន្ធទឹកកំពុងតែដំណើរការក្នុងការរៀបចំប្រព័ន្ធលូឱ្យបានត្រឹមត្រូវមានស្តង់ដាដើម្បីផ្ដល់ភាពងាយស្រួលសម្រាប់ប្រជាជន ការចូលរួមផ្សព្វផ្សាយលើការកែលម្អសោភ័ណភាពនិងហេដ្ឋារចនាសម្ព័ន្ធក្រុងលើផ្នែកសំខាន់ៗក្នុងវិស័យដូចជា ការកែលម្អសួនច្បារស្ទឹងសង្កែ ការរៀបចំក្នុង

[៥៥] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៥-៨

[៥៦] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣

ការលក់ដូររបស់ប្រជាជនឱ្យមានសណ្តាប់ធ្នាប់ជាងមុន ការបែងចែងផ្លូវតាមគំនូសសម្រាប់ធ្វើដំណើរអ្នកថ្មើរជើង ជិះកង់ ម៉ូតូ ឡានឱ្យបានត្រឹមត្រូវ ការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្មតាមការវិនិយោគធំៗបែបលំនៅដ្ឋាន បុរី ការអនុវត្តផែនការលើសំណង់ទៅតាមសណ្ឋានដីមានទាប មធ្យម និងខ្ពស់ដែលត្រូវការប្រើប្រាស់រយៈពេលមួយចំនួនធំសម្រាប់ដំណើរការងារតាមស្ថានភាពជាក់ស្តែងតាមទិសដៅយុទ្ធសាស្ត្រក្នុងការតម្រង់ទិសអភិវឌ្ឍន៍ក្រុងដែលបានកំណត់តាមផែនការអភិវឌ្ឍន៍នគរូបនីយកម្ម និងសំណង់។ រដ្ឋបាលក្រុងមានតួនាទីក្នុងការអភិវឌ្ឍក្រុងបាត់ដំបង និងតាមបណ្តាសង្កាត់ឱ្យមានភាពលេចធ្លោ ជាពិសេសសិប្បកម្មកែច្នៃអាហារមួយចំនួនកំពុងតែមានការរីកវឌ្ឍយ៉ាងខ្លាំងក្លានៅសមិទ្ធផលថ្មីៗដែលអាចជួយសេដ្ឋកិច្ចក្រុងបាត់ដំបងមានការកើនឡើង និងមានប្រាក់ចំណូលខ្ពស់ជាងមុនដែលស្របតាមទិសដៅយុទ្ធសាស្ត្រក្នុងការតម្រង់ទិស ការអភិវឌ្ឍរចនាសម្ព័ន្ធក្រុងបាត់ដំបង ដែលជាការជួយឱ្យប្រជាជនក្នុងក្រុងតាមសង្កាត់នានាមានជីវភាពល្អជាងមុនក្នុងការរស់នៅ និងអាចប្រកបអាជីវកម្មរបស់ខ្លួនបាន។[៥៧]

### ២.២.៣.១. គម្រោងអាទិភាពក្នុងការអភិវឌ្ឍនគរូបនីយកម្មក្របខ័ណ្ឌតំបន់ជាតិ

យោងតាមគម្រោងនៃផែនការសម្រាប់យកទៅអនុវត្តក្នុងការអភិវឌ្ឍនគរូបនីយកម្មមានការបែងចែកជាក្របខ័ណ្ឌតំបន់ជាតិ ជាការជំរុញគម្រោងតាមផែនការនៃកិច្ចប្រតិបត្តិការសេដ្ឋកិច្ចស្របតាមអ័ក្សខ្សែតាមបណ្តាផ្លូវជាតិលេខ៥ ដើម្បីជាការចូលរួមជំរុញការអភិវឌ្ឍឱ្យស្របតាមបណ្តាផ្លូវនៃការធ្វើដំណើរពីក្រុងបាត់ដំបងទៅតាមបណ្តាស្រុកសម្រាប់គម្រោងនៃការអនុវត្តចំពោះផែនការនៃកិច្ចប្រតិបត្តិការសេដ្ឋកិច្ចផ្តោតលើវិស័យពាណិជ្ជកម្ម ការវិនិយោគ ផលិតផលកែច្នៃ ទេសចរណ៍ និងសេវាកម្មផ្សេងដែលមានតាមបណ្តាសង្កាត់ក្នុងក្រុងបាត់ដំបង និងខេត្តទាំងមូល។ ការជំរុញតាមគម្រោងជាយុទ្ធសាស្ត្រមួយដែលជាការអភិវឌ្ឍដែនដីក្រុងបាត់ដំបងបានសហការគ្នាក្នុងការអនុវត្ត ដើម្បីជាការរួមចំណែកអនុវត្តតួនាទីឱ្យមានប្រសិទ្ធភាពក្នុងការងារ និងជាការអភិវឌ្ឍសេដ្ឋកិច្ចស្នូលក្នុងតំបន់។[៥៨]

ក្នុងកំឡុងពេលនៃការអភិវឌ្ឍ រដ្ឋបាលក្រុងក៏បានចូលរួមក្នុងការអនុវត្តលើការងារអភិវឌ្ឍន៍នគរូបនីយកម្ម និងលំនៅដ្ឋានរបស់ប្រជាជន ការត្រួតពិនិត្យចាត់ចែងក្នុងការជំរុញតាមព្រំប្រទល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ តាមគោលការណ៍ណែនាំរបស់ក្រសួងបូករួម និងការជំរុញការកសាងប្លង់គោលប្រើប្រាស់ដី ផែនការ ប្រើប្រាស់ដីនៅគ្រប់កម្រិត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងការសាងសង់តាមប្លង់លម្អិតរបស់នគរូបនីយកម្ម។ តំបន់នគរូបនីយកម្មទាំងបីកម្រិតរួមមាន តំបន់នគរូបនីយកម្មកម្រិតខ្ពស់ក្រុងបាត់ដំបង តំបន់នគរូបនីយកម្មកម្រិតមធ្យមទីប្រជុំជន និងតំបន់នគរូបនីយកម្មកម្រិតទាបទីប្រជុំជន ចំពោះទីក្រុងដែលជាមជ្ឈមណ្ឌលរដ្ឋបាល

[៥៧] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣

[៥៨] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី៩-១០

ការស្នាក់នៅមជ្ឈមណ្ឌលពាណិជ្ជកម្ម ការផលិត ការកែច្នៃ និងសេវាកម្មត្រូវយកចិត្តទុកដាក់ចំពោះកំណើនប្រជាជន តម្រូវការលំនៅឋាន ការកកស្ទះចរាចរណ៍ តម្រូវការផ្សេងៗទៀតនៅក្នុងទីក្រុង ចំពោះតំបន់ជនបទត្រូវរក្សាលំនឹងការអភិវឌ្ឍសក្តានុពលរបស់ខ្លួន។ ដើម្បីពង្រឹងឱ្យមានឯករាជ្យភាពជាតំបន់ស្នាក់នៅ តំបន់សម្បទានដីសង្គមកិច្ច តំបន់សម្បទានដី សេដ្ឋកិច្ច រៀបចំ និងពង្រីកលទ្ធភាពការអភិវឌ្ឍទីក្រុងចាំបាច់ត្រូវមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សាភ្ជាប់គ្នាជំរុញការអនុវត្តបទប្បញ្ញត្តិនីយកម្មក្នុងក្រុងទីប្រជុំជនតាមមុខងារនៃតំបន់នគរូបនីយកម្មកម្រិតខ្ពស់ មធ្យម និងទាបតាមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រូបវន្តក្នុងក្រុងទីប្រជុំជនការធ្វើសមាហរណកម្មទំនាក់ទំនងតភ្ជាប់រវាងតំបន់នីមួយៗរៀបចំអភិវឌ្ឍន៍ក្នុងការអភិរក្សតំបន់លំហសាធារណៈ រួមទាំងតំបន់ខ្សែក្រវ៉ាត់បៃតងក្រុងបាត់ដំបងដើម្បីធានាបាននូវការរស់នៅប្រកបដោយគុណភាព សុវត្ថិភាព សោភ័ណភាព។ សម្រាប់ការអភិវឌ្ឍលំនៅឋានក៏ជាការជំរុញនៅការរៀបចំតំបន់លំនៅឋានទៅតាមអ័ក្សនៃផែនការអភិវឌ្ឍន៍ក្រុងដែលភ្ជាប់ពីតំបន់នគរូបនីយកម្មពីមួយទៅមួយក្នុងការជំរុញការអភិវឌ្ឍលំនៅឋានសមស្របតាមតម្រូវការ តាមលទ្ធភាពអាចទទួលបានសម្រាប់អ្នកមានប្រាក់ចំណូលទាបគ្រួសារមានភាពក្រីក្រ រួមទាំងទីប្រជុំជនការជំរុញលើកទឹកចិត្តឱ្យមានការវិនិយោគអភិវឌ្ឍន៍ការសាងសង់លំនៅឋានថ្មីក្នុងទីក្រុងបាត់ដំបង និងតំបន់ជាយក្រុងដើម្បីផ្សាភ្ជាប់ទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចក្រុងបាត់ដំបង ក្នុងការកាត់បន្ថយការចំណាយលើការធ្វើដំណើររួមទាំងការកាត់បន្ថយចំណាកស្រុកព្រមទាំងកាត់បន្ថយគម្លាតពីតំបន់មួយទៅតំបន់មួយទៀត។ រីឯការជំរុញលើកទឹកចិត្តដល់ការវិនិយោគលើការសាងសង់លំនៅឋានថ្មីសម្រាប់បំពេញតម្រូវការនៃតំបន់សេដ្ឋកិច្ច ជាពិសេសក្នុងក្រុងបាត់ដំបង និងតំបន់អភិវឌ្ឍន៍តាមបណ្តាសង្កាត់ដែលជំរុញការអនុវត្តលើគម្រោងអភិវឌ្ឍន៍លំនៅឋានថ្មីនៅក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ជំរុញការដោះស្រាយ និងគ្រប់គ្រងសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់។[៥៩]

**២.២.៣.២. ការអនុវត្តប្រព័ន្ធដឹកជញ្ជូន និងអភិវឌ្ឍន៍វិស័យក្រុងបាត់ដំបង**

តាមរយៈការសង្កេតក្នុងការគ្រប់គ្រងប្រព័ន្ធដឹកជញ្ជូននៃផែនការអនុវត្តក្រុងបាត់ដំបងក៏ដូចជាខេត្តទាំងមូលកំពុងតែមានការអភិវឌ្ឍយ៉ាងសកម្ម ជាពិសេសទាក់ទងលើវិស័យដឹកជញ្ជូនរចនាសម្ព័ន្ធក្នុងក្រុងបាត់ដំបងបន្ថែមទៀតការចាត់ចែងការងារដែលជាកត្តាក្នុងការជំរុញនៅភាពទាក់ទាញសម្រាប់ការដឹកជញ្ជូនអភិឌ្ឍន៍តាមបណ្តាផ្លូវថ្នល់ ផ្លូវដែករថភ្លើង និងផ្លូវអាកាស។ ការស្តារអភិវឌ្ឍន៍ជាអាទិភាពដែលភ្ជាប់ទៅកាន់តំបន់នគរូបនីយកម្មក្រុងទីប្រជុំជន និងតំបន់លំនៅដ្ឋានជនបទរួមមានការស្តារ និងការកែលម្អលើគម្រោងស្នើសុំសាងសង់ជាថ្មីដែលជាអ័ក្សតភ្ជាប់រវាងស្នូលអភិវឌ្ឍន៍ទាំងអស់ក្នុងការកែលម្អបណ្តាញដែលមានស្រាប់លើគម្រោងស្នើសាងសង់ថ្មី

---

[៥៩] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣

ដែលតភ្ជាប់រវាងស្នូលអភិវឌ្ឍន៍តាមតំបន់ កសិកម្ម ឧស្សាហកម្ម តាមបណ្តាសង្កាត់ជុំវិញការអភិឌ្ឍបណ្តាញផ្លូវនានា និងស្ថានីយរថភ្លើងក្រុងបាត់ដំបង។[៦០]

តាមបណ្តាផ្លូវទឹកដែលមានការជំរុញ និងការបង្កើតសកម្មភាពដឹកជញ្ជូនតាមផ្លូវទឹកនៃស្ទឹងសង្កែ ដែលជាបណ្តាញផ្លូវទឹកសំខាន់ៗដែលតភ្ជាប់ទៅបឹងទន្លេសាប និងការស្តារកែលម្អស្ថិតនៅក្នុងក្រុងបាត់ដំបង។ ចំណែកឯផ្លូវអាកាសកំពុងតែស្តារ និងកែលម្អអាកាសយានដ្ឋានបច្ចុប្បន្នជាថ្មីដែលកំណត់ទីតាំងថ្មីសមស្របសម្រាប់ការសាងសង់ក្នុងការជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ការកែប្រែនេះដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាជនក៏ដូចជាជនបរទេសឱ្យមកកម្សាន្តក្រុងបាត់ដំបងកាន់តែច្រើនឡើង។ ប្រព័ន្ធនគរូបនីយកម្មក៏មានទំនាក់ទំនងជាមួយប្រព័ន្ធធារាសាស្ត្រ កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ជាផ្នែកសំខាន់ក្នុងការជួយបង្កើននៅសមត្ថភាពការងារ ការស្តារប្រព័ន្ធធារាសាស្ត្រសម្រាប់ប្រពលវប្បកម្មដំណាំស្រូវជំរុញការស្តារ និងពង្រីកបន្ថែមប្រព័ន្ធប្រឡាយទឹក រួមទាំងអាងស្តុកទឹកធំៗចំនួន ០៦កន្លែងដែលមានសក្តានុពលគ្របដណ្តប់លើតំបន់ផលិតកម្មស្រូវតាមរយៈបច្ចេកទេសទំនើបដើម្បីបង្កើនទិន្នផលស្រូវខ្ពស់។ ការថែរក្សាសក្តានុពលដីកសិកម្មសម្រាប់ការអភិវឌ្ឍរយៈពេលវែងបានជំរុញថែរក្សាការពារសក្តានុពលនៃប្រព័ន្ធជីវៈចម្រុះរបស់ដី និងការកែលម្អគុណភាពដីឡើងវិញទាំងផ្នែកគីមីសាស្ត្រ ព្រមទាំងរូបសាស្ត្រ ជំរុញការគ្រប់គ្រងលើសណ្ឋានដី និងចរន្តទឹកហូរតាមរយៈបច្ចេកទេសវិស្វកម្ម។ រីឯការលើកស្ទួយផលិតផលកសិកម្មតាមតំបន់ក្នុងការជំរុញ ការកែច្នៃនៃផលិតផលកសិកម្មចម្រុះប្រចាំតំបន់ ការកែលម្អចង្វាក់ផលិតកម្មកសិកម្មមូលដ្ឋាន ដើម្បីបង្កើនបរិមាណគុណភាពលើកកម្ពស់ផលិតផលលើផ្លាកសម្គាល់ភូមិសាស្ត្រទំនិញ ផលិតផលក្រុងបាត់ដំបងតាមរយៈការផ្សព្វផ្សាយ និងការធ្វើទីផ្សារលក់។[៦១] ចំណែកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងឧស្សាហកម្មមាន បួនចំណុចសំខាន់ៗការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ជំរុញការសាងសង់ទំនប់វារីអគ្គិសនីបាត់ដំបង១ ទំនប់វារីអគ្គិសនីបារាំង២៨ដែលបានកំណត់រួចក្នុងការជំរុញ ការកសាងរួមទាំងការស្តារបណ្តាញផ្គត់ផ្គង់ចរន្តអគ្គិសនីទឹកស្អាតទូរគមនាគមន៍ ព័ត៌មានទំនាក់ទំនង សេវាកម្មសុខភាពសាធារណៈក្នុងតំបន់ក្រុង និងជនបទ។ ការអភិវឌ្ឍបណ្តាញចែកចាយថាមពលអគ្គិសនីមានស្រាប់ក្នុងការអភិវឌ្ឍថាមពលអគ្គិសនីនៅគ្រប់ទីកន្លែង។ ចំណែកឯ ការអភិវឌ្ឍតំបន់ឧស្សាហកម្មជំរុញនៃការបង្កើតឧស្សាហកម្មចម្រុះនៅក្រុងបាត់ដំបង ថែមទាំងបង្កើតតំបន់ឧស្សាហកម្មកែច្នៃដំណាំចម្ការ ជំរុញបង្កើតតំបន់ឧស្សាហកម្មកែច្នៃស្រូវ ដំណាំចម្ការ និងវេចខ្ចប់។ សម្រាប់ការធ្វើអាជីវកម្មលើសំណល់រឹងរាវជំរុញភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងការធ្វើអាជីវកម្មលើសំណល់រឹងរាវនៃការអនុវត្តគោលការណ៍កាត់បន្ថយការប្រើប្រាស់ឡើងវិញ បូករួមការកែច្នៃជំរុញអប់រំ និងផ្សព្វផ្សាយឱ្យបាន

---

[៦០] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣២

[៦១] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី១១-១៤

ទូលំទូលាយដល់សាធារណជនដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថលើការទុកដាក់ និងសម្អាតសំរាម។ ការអភិរក្សតំបន់ប្រវត្តិសាស្ត្រ វប្បធម៌ តំបន់ធនធានធម្មជាតិ ពង្រឹងការកសាងបទដ្ឋានគតិយុត្តតាមវិស័យពាក់ព័ន្ធនៃពង្រឹងការគ្រប់គ្រង និងការពារតាមរយៈវិធានការដាក់លាក់ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធក្នុងសហគមន៍មូលដ្ឋាន បង្កើនសកម្មភាពការងារអភិរក្សនៅតំបន់ទាំងនេះដោយមានការចូលរួមពីអង្គការជាតិ និងអន្តរជាតិដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញគ្រប់ប្រភេទ។ ចំពោះតំបន់ការពារដែលមានប្រព័ន្ធជីវៈចម្រុះក៏ដូចជាការលើកស្ទួយវិស័យប្រព័ន្ធអេកូទេសចរណ៍កំណត់តំបន់ការពារប្រព័ន្ធជីវៈចម្រុះ បូករួមទាំងវាលទំនាបលិចទឹកជាប់បឹងទន្លេសាបបានជំរុញឱ្យមានលើកស្ទួយវិស័យអេកូទេសចរណ៍នៅក្នុងតំបន់ រួចពង្រឹងការគ្រប់គ្រងតាមរយៈការចូលរួមរបស់សហគមន៍មូលដ្ឋាន។ នៅក្នុងការផ្សព្វផ្សាយរដ្ឋបាលក្រុងបាត់ដំបងត្រូវធ្វើការផ្សព្វផ្សាយផែនការរៀបចំដែនដីគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធ ក្រុមអ្នកជំនាញវិនិយោគិនរបស់ប្រជាពលរដ្ឋទូទៅឱ្យទទួលបាននូវព័ត៌មានស្តីពីផែនការដើម្បីសហការក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព។[៦២]

### ២.២.៣.៣. ដំណើរការនីតិវិធីក្នុងការអនុវត្តសកម្មភាព

ជាការពិតណាស់ក្រោយពីមានការរៀបចំគម្រោងលើយុទ្ធសាស្ត្រទិសដៅនៃការគ្រប់គ្រងក្នុងការអភិវឌ្ឍដំណើរការនៃនីតិវិធីអនុវត្តតាមសកម្មភាពផ្តោតទៅលើការត្រួតពិនិត្យនៃការវាយតម្លៃ និងយន្តការនៃផែនការ។ ការត្រួតពិនិត្យនៃការវាយតម្លៃជាចំនុចសំខាន់ក្នុងដំណើរការអនុវត្តការងារដែលរួមមាននៅការគ្រប់គ្រងសកម្មភាពស្ថេរភាពការងារហិរញ្ញវត្ថុរបស់សកម្មភាពតាមផ្នែកនីមួយៗឱ្យស្របតាមគោលការណ៍ ការដាក់ផែនការអនុវត្តប្រកបដោយគុណភាពការងារដំណើរការប្រព្រឹត្តទៅរបស់ក្រុមការងារបានមកពី ថវិកាជាតិ ថវិកាឯកជន ថវិកាភាពជាដៃគូរវាងរដ្ឋ និងឯកជន ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការជាមួយជាតិ និងអន្តរជាតិ ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋសហគមន៍ និងសប្បុរសជន។ ការទទួលបាននៅថវិកាទាំងអស់នេះដោយមានការយកចិត្តទុកដាក់វាយតម្លៃ ការចូលរួមត្រួតពិនិត្យក្នុងនោះមាននៅយន្តការថ្នាក់ជាតិសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីរបស់ក្រុងបាត់ដំបងដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់មានការចូលរួមពីគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មថ្នាក់ជាតិ និងមានការចូលរួមរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។

យន្តការនៅថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តត្រួតពិនិត្យ និងការវាយតម្លៃផែនការរៀបចំដែនដីនៃក្រុងបាត់ដំបងរួមមានការទាក់ទងរដ្ឋបាលខេត្ត ក្រុងបាត់ដំបងមានគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មមន្ទីរអង្គភាពពាក់ព័ន្ធរបស់ខេត្ត ក្រុង អាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ ជាសមាជិក។[៦៣] ក្រោយពីមានការចុះនៅក្នុង

[៦២] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី១៥

[៦៣] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

ការត្រួតពិនិត្យការវាយតម្លៃ ក៏ដូចជាមានការចូលរួមនៅថវិកាមួយចំនួនបន្ថែមទៀតសម្រាប់ក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការតាមដានត្រួតពិនិត្យនៃការវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីខេត្ត ក្រុងបាត់ដំបងឱ្យត្រឹមត្រូវ។ ផ្អែកលើក្របខ័ណ្ឌច្បាប់គោលនយោបាយមួយចំនួនដែលទាមទារក្នុងការធ្វើឱ្យស្របតាមលិខិតច្បាប់មួយចំនួនដែលពាក់ព័ន្ធក្នុងការអនុវត្តការងាររបស់មន្ត្រីដែលរួមមាន លិខិតបទដ្ឋានគតិយុត្ត មានជាអាទិ៍ច្បាប់ភូមិបាលដែលក្នុងនោះមាន ច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលនយោបាយដីធ្លី គោលនយោបាយជាតិស្តីពី ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋានគោលនយោបាយអភិវឌ្ឍន៍។ វិស័យឧស្សាហកម្មកម្ពុជាក្នុងអនុក្រឹត្យស្តីពីការបង្កើតនៃគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេច ស្តីពីការរៀបចំប្លង់គោលផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។[៦៤]

បន្ទាប់ពីការវាយតម្លៃរួចរាល់ក៏ដូចជាការដាក់ស្នើនៅលិខិតបទដ្ឋានគតិយុត្តមួយចំនួនរួចមកដែលស្របតាមការអនុវត្តការងារបូករួមជាមួយគោលការណ៍នីតិវិធីភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មក្រុងបាត់ដំបងដែលមានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដោយមានការចូលរួមពីខាងសុរិយោដីខេត្តក្រុងជាសមាជិកអចិន្ត្រៃយ៍ត្រូវអនុវត្តតាមគោលការណ៍នីតិវិធីភារកិច្ចដូចជា ការកំណត់នៃហេតុប៉ះពាល់សង្គម និងបរិស្ថានសម្រាប់ធ្វើការតាមដានត្រួតពិនិត្យ ការវាយតម្លៃការងារប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តផែនការរៀបចំដែនដីនេះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងសង្គមប្រកបដោយចីរភាព។ ការទទួលខុសត្រូវរៀបចំផែនការសកម្មភាពលម្អិតនៃគម្រោងអភិវឌ្ឍន៍នានាសម្រាប់ការអនុវត្តផែនការរៀបចំដែនដីនេះមានការចូលរួមពីក្រសួងស្ថាប័ន មន្ទីរអង្គភាព វិស័យឯកជនអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។

ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាពពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវសូចនាករសំខាន់ៗសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំកម្មវិធីវិនិយោគសាធារណៈបី (៣) ឆ្នាំរំកិលសម្រាប់ប្លង់គោលប្រើប្រាស់ដីផែនការប្រើប្រាស់ដីប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ត្រូវធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដីខេត្តបាត់ដំបងក្នុងរយៈពេលប្រាំ (៥) ឆ្នាំស្របតាមគោលការណ៍ និងនីតិវិធីជាធរមានដើម្បីស្នើសុំ

[៦៤] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី១៥-១៦

ការសម្រេចនៃការដាក់ឱ្យប្រើប្រាស់ជាផ្លូវការពីរាជរដ្ឋាភិបាល ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆ្នាំ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការរៀបចំដែនដីនេះជូនក្រសួងមហាផ្ទៃ។[៦៥]

## ២.៣. សមិទ្ធផលនៅក្នុងក្រុងបាត់ដំបង

ក្រុងបាត់ដំបងទទួលបាននៅសមិទ្ធផលល្អ ក៏ដូចជាទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ទៅលើវិស័យនានាដែលជាសេដ្ឋកិច្ចចម្បងក្នុងក្រុងបាត់ដំបងផ្ទាល់ និងជាការជំរុញវិស័យមួយចំនួនបន្ថែមទៀតនៅក្នុងក្រុងបាត់ដំបងទាំងនេះជាចំណែកមួយក្នុងការអភិវឌ្ឍក្រុងផងដែរ។

### ២.៣.១. វិស័យចម្បងនៅក្នុងក្រុងបាត់ដំបង

យោងតាមវឌ្ឍនភាពកន្លងមកក្រុងបាត់ដំបងមានវិស័យគោលសម្រាប់សេដ្ឋកិច្ចក្នុងការចូលរួមជាច្រើនផ្នែកដែលសំខាន់រួមមានកសិកម្មផលិតផលអង្គរប្រចាំក្រុងបាត់ដំបងបូករួមទាំងបន្លែផ្លែឈើទាក់ទងនឹងការដាំដុះបង្កបង្កើនផល។ល។ ការងារវឌ្ឍនភាពកន្លងមកដោយទទួលបានតាមរយៈការបូកសរុបការងាររបស់ក្រសួង និងរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ដែលសម្រេចបានរយៈពេលប្រាំ (៥) ឆ្នាំ ក៏ដូចជារបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុងបាត់ដំបងតាមរយៈការស្រាវជ្រាវទៅលើទិន្នន័យរបស់រដ្ឋបាលក្រុងបាត់ដំបងលើសមិទ្ធផលកន្លងក្នុងឆ្នាំ២០២១ និង២០២២ មានចំនួន ១៥២,០៧៦នាក់ក្នុងនោះប្រជាជនដែលប្រកបរបរកសិកម្មចំនួន ៦៨,៥% សេវាកម្ម ៣១% ផ្នែកសិប្បកម្ម ០,៥% ដោយសេដ្ឋកិច្ចក្រុងបាត់ដំបងទាំងមូលមានចំនួនស្មើនឹង ៨,៨% ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ។ ដំណាំស្រូវ ឧស្សាហកម្ម ការចិញ្ចឹមសត្វវិស័យពាណិជ្ជកម្ម វិស័យអប់រំ វិស័យសុខាភិបាល និងវិស័យទេសចរណ៍។[៦៦]

#### ២.៣.១.១. វិស័យកសិកម្ម ឧស្សាហកម្ម

ក្រុងបាត់ដំបងមានកត្តាភូមិសាស្ត្រអំណោយផលដែលផ្ទៃដីមានជីវជាតិល្អ សម្រាប់ផលកសិកម្មបានជាប់ឈ្មោះជាក្រុងនៃជង្រុកស្រូវក្នុងព្រះរាជាណាចក្រកម្ពុជាដោយប្រជាពលរដ្ឋប្រកបរបរកសិកម្មប្រមាណជាង ៦៨% ក្នុងការរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍលើកកម្ពស់សេដ្ឋកិច្ចកម្ពុជាដោយមានផ្ទៃដីដាំដុះស្រូវសរុបចំនួន ៤១៤,៧៦១ហិកតាទទួលបានបរិមាណចន្លោះពី ១,១លានតោន ទៅ១,៤លានតោន។ ក្នុងមួយឆ្នាំៗដែលមានប្រភពទឹកផ្គត់ផ្គង់ចំនួន ០៤ប្រព័ន្ធធំៗ ដោយប្រជាជនក្នុងក្រុងតាមបណ្ដាសង្កាត់នីមួយៗអាស្រ័យលើការប្រើប្រាស់ទឹកតាមរយៈប្រព័ន្ធធារាសាស្ត្របីសំខាន់ៗដែលរួមមាន ប្រព័ន្ធធារាសាស្ត្រស្ទឹងសង្កែនៅក្នុង

[៦៥] ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០, លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨, ទំព័រទី១៩

[៦៦] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុងបាត់ដំបងឆ្នាំ២០២២, ទំព័រទី២២-២៤

ក្រុងបាត់ដំបងឆ្លងកាត់ប្រព័ន្ធធារាសាស្ត្រស្ទឹងមោងឬស្សី ប្រព័ន្ធធារាសាស្ត្រស្ទឹងមង្គលបុរី និងប្រព័ន្ធធារាសាស្ត្រអាងកំពីងពួយ។[៦៧]

តាមរយៈរបាយការណ៍ការអនុវត្តការងាររដ្ឋបាលកន្លងមកវិស័យការងារកសិកម្មរុក្ខាប្រមាញ់ និងនេសាទ លទ្ធផលបង្កបង្កើនផលស្រូវរដូវវស្សា ផែនការ ៥,៨៥០ហិកតា ភ្ជួររាស់ និងដាំដុះបានចំនួន ៥,៨៥៥ហិកតា ស្មើនឹង ១០៣%នៃផែនការ ក្នុងនោះស្រូវស្រាល ៣,៩៤៧ហិកតា ស្រូវកណ្តាល ១,២៩៣ហិកតា ស្រូវធ្ងន់ ៦១៥ហិកតា។ ការងារច្រូតកាត់ប្រមូលផលស្រូវវស្សាបានសម្រេចទៅតាមផែនការ ១០០% ក្នុងនោះទិន្នផលស្រូវស្រាលគិតជាមធ្យម ៣,៥តោនក្នុង ១ហិកតា ស្រូវកណ្តាល ៣,១តោនក្នុង ១ហិកតា ស្រូវធ្ងន់ ២,៩តោនក្នុង ១ហិកតា។ ការងារបង្កើនផលស្រូវរដូវប្រាំងផែនការ ១,០០០ហិកតា ដាំដុះបានចំនួន ១០២៤ហិកតា ស្មើនឹង ១០៣%នៃផែនការ (លើ៧សង្កាត់) ក្នុងនៅច្រូតកាត់ប្រមូលផលបាន ១១៥ហិកតា ទិន្នផលជាមធ្យម ៣,៨តោនក្នុង ១ហិកតាដំណាំរួមផ្សំផែនការ ៥០ហិកតា ដាំដុះបាន ៧៦ហិកតា ស្មើ ១៥២%នៃផែនការ។ ដោយក្នុងការងារផ្សព្វផ្សាយអប់រំធ្វើបានតាមរយៈរដ្ឋបាលចុះទៅក្នុងគោលបំណងផ្សព្វផ្សាយណែនាំដល់កសិករពាក់ព័ន្ធបច្ចេកទេសលើដំណាំ រួមផ្សំ ដំណាំស្រូវ ការធ្វើជីកំប៉ុស្តិ៍រឹង និងវាវិធានការការពារជំងឺឆ្លងផ្សេងដល់សត្វពាហនៈនៅលើ ១០ សង្កាត់ចំនួន ៥៤៤គ្រួសារ។ ផ្សព្វផ្សាយណែនាំកសិករដាំឈើហូបផ្លែតាមលក្ខណៈបច្ចេកទេសផ្សព្វផ្សាយឱ្យកសិករបានយល់ដឹងបង្កើន៣ គឺទិន្នផល គុណភាព និងប្រាក់ចំណូល។[៦៨]

ក្នុងរបាយការណ៍ការអនុវត្តការងាររដ្ឋបាលឆ្នាំ២០២២ នៅក្នុងស្ថានភាពបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០២២ លើផែនការ ៥,៩០០ហិកតាដែលការអនុវត្តនៃការដាំដុះបានចំនួន ៥,៩០០ហិកតាហើយដោយសារតែទទួលរងនៅគ្រោះទឹកជំនន់ដែលនាំឱ្យខូចខាតចំនួនសរុប ១,៩៥៧ហិកតាទិន្នផលស្រូវស្រាល ៣តោនគិតជាមធ្យមក្នុង ១ហិកតា ទិន្នផលស្រូវកណ្តាល ២,៩០តោនគិតមធ្យម និងស្រូវធ្ងន់ ២,៨០តោនគិតមធ្យមក្នុងក្រុងបាត់ដំបងនៅតាមបណ្តាស្រុកក្នុងក្រុងក៏ទទួលនៅផលវិបាកដូចជា ដោយសារទឹកជំនន់ដែលក្នុងការស្តារឡើងវិញនៅដំណាំស្រូវពីគ្រោះទឹកជំនន់មានចំនួន ១,៧៨៧ហិកតាលើ ៧សង្កាត់ និងដំណាំផ្សេងទៀតដាំដុះបាន ៥០ហិកតាស្មើ ១០៦%។ ក្នុងនោះក៏មានការបូករួម ការចិញ្ចឹមសត្វ និងព្យាបាលសត្វ គោ ក្របី មាន់ ជ្រូក សម្រាប់ការផ្សព្វផ្សាយក៏ត្រូវតែមានផងដែរ ដោយរួមមានការណែនាំបច្ចេកទេសលើការចិញ្ចឹមសត្វ ការចុះណែនាំយល់ដឹងលើការភ្ជួររាស់ដាំដុះ ការប្រើប្រាស់ជីបំប៉នលើដំណាំ និងការផ្សព្វផ្សាយនៅបច្ចេកទេសដាំដុះដំណាំបន្លែបច្ចេកទេសការជ្រើសរើសពូជឱ្យល្អ។[៦៩]

---

[៦៧] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

[៦៨] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២១, ទំព័រទី២៤

[៦៩] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី២២-២៤

ឧស្សាហកម្មមាន ២០ហិកតា ការដាំដុះបាន ២៨ហិកតា ស្មើ ១៤០%នៃផែនការគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុងបានចែកគ្រាប់ពូជបន្លែចំនួន ១២មុខចែកជូនកសិករលើ៤សង្កាត់ (វត្តគរ អូរម៉ាល់ ក្តុលដូនទាវ និងចំការសំរោង) សរុប ៧១១គ្រួសារ។ សហការចូលរួមជាមួយប្រធានមន្ទីរកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទបានផ្តល់ឧបករណ៍ដាំស្រូវជាជួរ ០១គ្រឿងដល់សហគមន៍ពន្លឺស្ត្រីនៅសង្កាត់អូរម៉ាល់។

| ល.រ | ឈ្មោះសង្កាត់ | លទ្ធផលសម្រាចបានគិត (ហិកតា) ត្រឹមថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ | | | | | | ផ្សេងៗ ខូចទឹកជំនន់ |
|---|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង | ផែនការ | ភាគរយ | ស្ថានភាពភ្លៀង | |
| ១ | ទួលតាឯក | ០ | ០៣ | ០៣ | ០៣ | ១០០% | | |
| ២ | ព្រែកព្រះស្តេច | ០ | ០ | ០ | ០ | | | |
| ៣ | រតនៈ | ០ | ១៦០ | ១៦០ | ១៦០ | ១០០% | | |
| ៤ | ចំការសំរោង | ០ | ៣៦០ | ៣៦០ | ៣៦០ | ៨០% | | ៩០ហិកតា |
| ៥ | ស្លាកែត | ០ | ១៥១ | ១៥១ | ២១០ | ៧១% | | ៥៩ហិកតា |
| ៦ | ក្តុលដូនទាវ | ០ | ៤៥៩ | ៤៥៩ | ៤៥៩ | ១០០% | | |
| ៧ | អូរមាល់ | ០ | ១,២៨២ | ១,២៨២ | ៣,០៩០ | ៤១% | | ១,៨០៨ |
| ៨ | វត្តគរ | ០ | ១,០៦០ | ១,០៦០ | ១,០៦០ | ១០០% | | |
| ៩ | អូរចារ | ០ | ៤៣២ | ៤៣២ | ៤៣២ | ១០០% | | |
| ១០ | ស្វាយប៉ោ | ០ | ០ | ០ | ០ | ០% | | |
| សរុបទូទាំងក្រុង | | ០ | ៣,៩៤៣ | ៣,៩៤៣ | ៥,៩០០ | ៦៧% | | ១,៩៥៧ |

សហគ្រាសផលិតកម្មឯកជន និងក្រុមហ៊ុនធំៗដែលកំពុងវិនិយោគមានទីតាំងច្បាស់លាស់ចំនួនខ្នាតតូចទុនចន្លោះពីខ្នាតមធ្យមទុនចន្លោះរោងម៉ាស៊ីនកិនស្រូវក្នុងនោះខ្នាតតូចទុនវិនិយោគខ្នាតមធ្យម និងខ្នាតធំមានរោងម៉ាស៊ីនកិនស្រូវមួយចំនួនកំពុងតំឡើងម៉ាស៊ីនឧបករណ៍ និងឃ្លាំងបន្ថែមដើម្បីបង្កើននូវសមត្ថភាពកិនកែច្នៃអង្ករសំដៅទៅលើការបម្រើឱ្យទីផ្សារនាំចេញក្រៅប្រទេសឧបករណ៍ និងម៉ាស៊ីន (បច្ចុប្បន្នមានសមត្ថភាពផលិតធំ និងបច្ចេកវិទ្យាខ្ពស់) ម៉ាស៊ីនសម្ងួត ឃ្លាំងស្តុក ម៉ាស៊ីនកិន ម៉ាស៊ីនកែច្នៃ។ ការនាំចេញស្រូវដែលប្រមូលបានស្មើនឹង ៩១,៧៦៣,៣៣៤តោនអង្ករសម្រាប់នាំចេញ (ផ្ទាល់ និងប្រយោល)ស្មើ ៥០,៤៩២,៥៨៩តោន អង្ករក្រអូប (ផ្កាម្លិះ និងសែនក្រអូប) ស្មើ ៤៧,២២៦,៥៨៩តោន អង្ករធម្មតា (អង្ករនាងខុន អង្ករស និងIR) ស្មើ ៣,២៦៦

តោន។ រីឯខាងរដ្ឋាករទឹកមានសមត្ថភាពផលិតទឹកស្អាតពេលបច្ចុប្បន្ន ៣៣,៥២០ម៉ែត្រគីបក្នុងមួយថ្ងៃ បូមទឹកឆៅប្រចាំឆ្នាំសម្រាប់យកមកធ្វើផលិតកម្ម ៦,៨០៦,០៥៨ម៉ែត្រគីបដោយនៅក្នុងមួយឆ្នាំផលិតទឹកស្អាតបាន ៦,៥២៧,៧៦៩ម៉ែត្រគីបក្នុងមួយឆ្នាំការផ្គត់ផ្គង់ទឹកស្អាតជាមធ្យម ១៧,៨៨៤ម៉ែត្រគីបក្នុងមួយថ្ងៃ តម្លៃទឹកស្អាតក្នុង១ម៉ែត្រគូប ១,៥០០រៀល។[៧០]

**២.៣.១.២. ពាណិជ្ជកម្ម និងសិប្បកម្ម**

ពាណិជ្ជកម្មក្នុងក្រុងបាត់ដំបងតាមការសង្កេតប៉ុន្មានឆ្នាំចុងក្រោយទទួលបានការវិនិយោគជាច្រើន ដោយសភាពាណិជ្ជកម្មកម្ពុជាបាត់ដំបងបានរៀបចំនៅពិព័រណ៍ពាណិជ្ជកម្មកម្ពុជា ២០២៣សហការជាមួយរដ្ឋបាលខេត្តបានសម្រេចឱ្យសភាពាណិជ្ជកម្មធ្វើការជំរុញលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ក្នុងតំបន់នៅមូលដ្ឋានផ្ទាល់ និងជួយសម្រួលចរន្តទីផ្សារជូនសមាជិកសមាជិកាសភាពាណិជ្ជកម្មផង ដោយតាមបណ្តាតំបន់មួយចំនួនមានការបង្កើតនៅមជ្ឈមណ្ឌលពាណិជ្ជកម្មទីផ្សារលក់រាយ និងបោះដុំ (ទំនិញក្នុងតំបន់ ឬនាំចូល) សម្រាប់ចែកចាយបន្តជាមជ្ឈមណ្ឌលពាណិជ្ជកម្មធំ និងមានប្រជាពលរដ្ឋច្រើនផ្តោតលើការពង្រឹងរចនាសម្ព័ន្ធទីផ្សារតាមរយៈការប្រមូលកៀគរផលិតផល និងសេវាដែលសមាជិកសភាពាណិជ្ជកម្មរាជធានី ខេត្ត ក្រុងផលិតបាននាំមកដាក់បង្ហាញចូលទីផ្សារ។[៧១]

ក្រុងបាត់ដំបងក៏មានការបង្កើតនៅតំបន់ពាណិជ្ជកម្មជាសហគ្រាសឯកជនមួយចំនួនដែលជា ក្រុមហ៊ុនអភិវឌ្ឍន៍រួមមាន សិប្បកម្មផលិតមី សិប្បកម្មកែច្នៃត្រី (ណែម) សិប្បកម្មផលិតគ្រឿងបរិភោគផ្សេងៗ សិប្បកម្មសត្វ សិប្បកម្មកែច្នៃឈើ សម្ភារៈសំណង់ រោងកិនស្រូវ រោងចក្រផលិតឥដ្ឋ រោងចក្រខ្នាតតូចផលិតទឹកសុទ្ធ សិប្បកម្មផលិតស្រាទំពាំងបាយជូ រោងចក្រខ្នាតតូចផលិតទឹកកក រោងចក្រកែច្នៃកប្បាស ហាងលក់ដូរនានាដែរ។ ក្រុងបាត់ដំបងក៏មានការបង្កើតនៅតំបន់ពាណិជ្ជកម្មបន្ថែមទៀតនោះ គឺអចលនទ្រព្យដែលជាកត្តាជំរុញឱ្យមានការបោះទុនវិនិយោគចូលក្នុងតំបន់នេះមានអំណោយផលលើគ្រប់វិស័យរាប់ចាប់តាំងពី វិស័យពាណិជ្ជកម្ម កសិកម្មឧស្សាហកម្ម និងទេសចរណ៍។ ជាក់ស្តែងដីនៅកណ្តាលក្រុងតំបន់មានសក្តានុពលដូចជាសង្កាត់ស្វាយប៉ោតាមតំបន់មួយចំនួនទៀត គឺមានតម្លៃចន្លោះពី ២,៤០០ដុល្លារ ទៅដល់៤,០០០ដុល្លារក្នុងមួយម៉ែត្រ ការ៉េមានផ្ទះវីឡាភាគច្រើនស្ថិតនៅតាមជាយក្រុងលើសពីកន្លែងស្នាក់នៅធម្មតា។ ជាទូទៅផ្ទះវីឡាទាំងនេះត្រូវបានគេប្រើជាការិយាល័យការងារ និងមួយចំនួនទៀតជាផ្ទះលំហែ។ ការអភិវឌ្ឍដីធ្លីក្នុងក្រុងមានការរីកចម្រើនដែលមានគម្រោងបុរីជាច្រើនចាប់ផ្តើមធ្វើការវិនិយោគដែលគេសង្កេតឃើញពីភាពជឿនលឿននៅតំបន់នោះ។

---

[៧០] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី២៣

[៧១] គេហទំព័រ https://www.battambang.gov.kh/detail/organization/ ដកស្រង់នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

ផ្សារណាត់ជាតំបន់ពាណិជ្ជកម្មមួយកន្លែងក្នុងបច្ចុប្បន្នដីធ្លីក្នុងក្រុងបាត់ដំបងម្តុំផ្សារណាត់ និងផ្សារថ្មីមួយម៉ែត្រការ៉េមានតម្លៃចន្លោះពី ១,០០០ ទៅ១,៥០០ដុល្លារ រីឯនៅតំបន់ក្រៅក្រុងអាចមានតម្លៃក្នុងរង្វង់ពី ២៥០ ទៅ៦០០ដុល្លារ តម្លៃដីធ្លីនៅក្រុងបាត់ដំបងអាចរក្សាបានភាពរឹងមាំនោះ គឺដោយសារតែមានកត្តាធំៗចំនួន ០២ គឺទី១ កត្តាប្រជាជន និងអ្នករកស៊ីក្នុងវិស័យនេះនៅតែមានជំនឿលើស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ចកម្ពុជា ទី២ ក្រុងបាត់ដំបងជាកន្លែងដែលសម្បូរទៅដោយតំបន់កម្សាន្ត និងប្រាសាទបុរាណជាច្រើនសម្រាប់ភ្ញៀវទេសចរ។ ក្រុងបាត់ដំបងមានប្រជាជនរស់នៅច្រើន ក៏ដូចជាមានសកម្មភាពតំបន់ពាណិជ្ជកម្មល្អប្រសើរក្នុងតំបន់តាមសង្កាត់នីមួយៗ មានតំបន់ទេសចរណ៍ប្រាសាទជាវត្តបុរាណព្រមទាំងការអភិវឌ្ឍសម្រាប់ការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។[៧២]

- តាមរយៈរបាយការណ៍រដ្ឋបាលក្រុងបាត់ដំបងឆ្នាំ២០២១បានបូកសរុបការផ្តល់សេវាកម្មក្នុងការទទួលពាក្យអាជីវកម្មរួមមាន៖
  - លិខិតអនុញ្ញាតច្បាប់ប្រកបអាជីវកម្មបានចំនួន (៦៥០ច្បាប់)
  - ប្រភេទពាណិជ្ជកម្មចំនួន ៣៣៩ច្បាប់ (ថ្មី៨៤ បន្ត២៥៥ច្បាប់)
  - ប្រភេទសេវាកម្មចំនួន ២៥៥ច្បាប់ (ថ្មី៧៩ បន្ត១៧៦ច្បាប់)
  - ប្រភេទសិប្បកម្មចំនួន ២១ច្បាប់ (ថ្មី៨ បន្ត១៣ច្បាប់)
  - ប្រភេទប្រេងឥន្ធនៈចំនួន ៩ច្បាប់ (ថ្មី២ បន្ត៧ច្បាប់)
  - លោហៈធាតុត្បូងថ្មមានតម្លៃចំនួន ២៦ច្បាប់ (ថ្មី៨ បន្ត១៨ច្បាប់) ក្នុងការលំបាករបស់អាជីវករដោយមានការរអ៊ូនៅការបង់ថ្លៃសេវាច្រើនមានភាពយឺតយ៉ាវក្នុងការបន្តទៀត។[៧៣]
- របាយការណ៍ក្រុងបាត់ដំបងឆ្នាំ២០២២បានផ្តល់នៅសេវាក្នុងការទទួលពាក្យអាជីវកម្មរួមមាន៖
  - លិខិតអនុញ្ញាតច្បាប់ប្រកបអាជីវកម្មបានចំនួន (១,២៨២ច្បាប់)
  - ប្រភេទពាណិជ្ជកម្មចំនួន ៨០៤ច្បាប់ (ថ្មី៥៣០ បន្ត២៧៤ច្បាប់)
  - ប្រភេទសេវាកម្មចំនួន ៤០៤ច្បាប់ (ថ្មី១៨៨ បន្ត២១៦ច្បាប់)
  - ប្រភេទសិប្បកម្មចំនួន ៣១ច្បាប់ (ថ្មី១១ បន្ត៩ច្បាប់)
  - ប្រភេទប្រេងឧស្ម័នចំនួន ១៣ច្បាប់ (ថ្មី៤ បន្ត៩ច្បាប់)
  - លោហៈធាតុត្បូងថ្មមានតម្លៃចំនួន ៣០ច្បាប់ (ថ្មី៧ បន្ត២៣ច្បាប់)។

[៧២] គេហទំព័រ https://www.battambang.gov.kh ដកស្រង់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

[៧៣] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២១, ទំព័រទី២៣-២៥

### ២.៣.១.៣. វិស័យទេសចរណ៍

ក្រុងបាត់ដំបងមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រជាច្រើនក្នុងការលើកកម្ពស់សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការបង្កើតការងារជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល។ ក្រុងបាត់ដំបងមានសំណង់បុរាណជាច្រើនដូចជា សំណង់ស្ថាបត្យកម្មសម័យបារាំង សំណង់វប្បធម៌ និងសារមន្ទីរប្រវត្តិសាស្ត្រខេត្ត សារមន្ទីរខេត្ត ស្ពានថ្មចាស់ និងសំណង់អគារអភិរក្សក្នុងខេត្ត។[៧៤] ផ្ទះបុរាណស្ថិតនៅភូមិវត្តគរ សង្កាត់វត្តគរក្រុងបាត់ដំបងស្ថិតនៅស្របតាមបណ្ដោយស្ទឹងសង្កែជាតំបន់ទេសចរណ៍មួយទាក់ទាញឱ្យចង់មកទស្សនាច្រើន និងចង់ដឹងពីរឿងរ៉ាវប្រវត្តិសាស្ត្រក្នុងក្រុងបាត់ដំបងផងរួមមានសំណង់បារាំង សារមន្ទីរ ផ្សារនានា ស្ទឹង ទន្លេ ភ្នំ កសិ-ទេសចរណ៍ អេកូទេសចរណ៍ ប្រពៃណីវប្បធម៌ អគារ វត្តបុរាណ ម្ហូបប្រចាំតំបន់រមណីយដ្ឋានធម្មជាតិ និងរមណីយដ្ឋានកែច្នៃច្រើនកន្លែង គឺជាភាពទាក់ទាញភ្ញៀវទេសចរ។ ក្នុងរយៈពេលប្រាំ (៥) ឆ្នាំកន្លងមកនេះភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាក្រុងបាត់ដំបងសរុបបានឱ្យដឹងថាកំណើនទេសចណ៍កាលពីកន្លងមានការកើនឡើងក្នុងនោះចំនួនភ្ញៀវ ៥៥៥,២៧៤នាក់ហើយមានការកើនឡើង ២៤៣ភាគរយ និងទេសចរណ៍អន្តរជាតិមានចំនួន ១៨៤,៦០០នាក់កើនចំនួន ២១៨ភាគរយ គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។ កត្តាជាច្រើនដែលធ្វើឱ្យមានការទាក់ទាញភ្ញៀវទេសចរក្នុងក្រុងបាត់ដំបងដូចជា ការផ្សាភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងបាត់ដំបងតាមរយៈសង្កាត់នីមួយៗ និងតាមបណ្ដារមណីយដ្ឋាននានាដែលមានការចូលរួមជ្រោមជ្រែងពីមន្ទីរអភិវឌ្ឍន៍ជនបទការរៀបចំព្រឹត្តការណ៍ទេសចរណ៍នានា។

ក្រុងបាត់ដំបងមានតំបន់កសិ-ទេសចរណ៍ តំបន់អេកូទេសចរណ៍ តំបន់ទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ តំបន់កែច្នៃ វត្តគំរូ ដែលជាការរួមចំណែកពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យទេសចរណ៍។ ប្រជាជនមកទេសចរណ៍នៅក្នុងក្រុងបាត់ដំបងពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងទាំងភ្ញៀវជាតិ និងអន្តរជាតិដោយសណ្ឋាគារ ផ្ទះសំណាក់មាន ៥៦៣កន្លែង ភោជនីយដ្ឋានចំនួន ១៦៦៥ ព្រមទាំងសេវាបម្រើឱ្យវិស័យទេសចរណ៍ជាច្រើនទៀតដូចជា មណ្ឌលកម្សាន្ត ខារ៉ាអូខេ និងសេវាទស្សនាកម្សាន្តនៅតាមតំបន់រមណីយដ្ឋានផ្សេងៗរដ្ឋបាលក្រុងបានជំរុញឱ្យមន្ទីរទេសចរណ៍ធ្វើការជំរុញ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈវិស័យទេសចរណ៍។ មន្ទីរទេសចរណ៍ទទួលក្នុងការអនុវត្តបណ្ដុះបណ្ដាលឱ្យមានជំនាញទេសចរណ៍ ៦៥៧នាក់ សម្រាប់ធ្វើការនៅក្នុងមូលដ្ឋានសេវាកម្ម អាជីវកម្មទេសចរណ៍ព្រមទាំងផ្ដល់ការងារដល់ប្រជាជនរាប់ពាន់នាក់។[៧៥]

[៧៤] គេហទំព័រ https://hunnghivietnamcampuchia.thoidai.com.vn/dtail-article-11917.html ដកស្រង់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

[៧៥] សេចក្ដីប្រកាសព័ត៌មានលិទ្ធផលនៃសន្និសិទ្ធសារព័ត៌មានស្ដីពីភាពជោគជ័យរយៈពេល ៥ឆ្នាំ, លេខ០២៦/២៣អអរ, ទំព័រទី២-៣

សាធារណការ និងទូរគមនាគមន៍តាមរបាយការណ៍របស់អភិបាលក្រុងបាត់ដំបងបានបញ្ជាក់ថា ចំពោះដំណើរការជួសជុលផ្លូវក្នុងក្រុងបាត់ដំបង។ រដ្ឋបាលខេត្តក្នុងក្រុងបានរៀបចំធ្វើការជួសជុលកំណាត់ក្នុងក្រុងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងបាត់ដំបង និងផ្លូវជាគជ័យកន្លងមកមានដូចជា៖

- **សង្កាត់ស្វាយប៉ោ**
  - ស្ថាបនាផ្លូវបេតុង ០១ខ្សែ ប្រវែង ២៧៧ម៉ែត្រ នៅភូមិព្រែកមហាទេព (មូលនិធិក្រុង)
  - ស្ថាបនាផ្លូវបេតុង (ផ្លូវលេខ១១១) ប្រវែង ២៤០ម៉ែត្រ នៅភូមិព្រែកមហាទេព (មូលនិធិខេត្ត)
  - ស្ថាបនាផ្លូវបេតុង ០១ខ្សែ ប្រវែង ២៦២ម៉ែត្រនៅភូមិកម្មករ (ADB) ដាក់លូមុខកាត់ ១០០ និងចាក់ថ្មបំពេញផ្លូវ ០៣ខ្សែ ប្រវែង ៥៥០ម៉ែត្រ (មូលនិធិសង្កាត់)
  - ការងារជួសជុលផ្លូវក្រាលកៅស៊ូប្រភេទ DBST ផ្លូវលេខ ១១១ ពីផ្លូវលេខ៥២៤ ដល់ផ្លូវលេខ១១៥ (ផ្លូវខាងជើងអតីតសណ្ឋាគារ ហូលីដេ) ដែលមានប្រវែង ២៥០ម៉ែត្រគុណ៦ម៉ែត្រក្នុងសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង និងមានការងារជួសជុលផ្លូវសំបុកមាន់ក្នុងក្រុងបាត់ដំបង។
- **សង្កាត់ចំការសំរោង**
  - ស្ថាបនាផ្លូវបេតុង ០១ខ្សែ ប្រវែង ២៨២ម៉ែត្រ នៅភូមិវត្តលៀប (មូលនិធិក្រុង)
  - ដាក់លូរំដោះទឹក ០១ខ្សែ ប្រវែង ៩៥៨ម៉ែត្រ នៅភូមិចំការសំរោង១ និង២ (មូលនិធិសង្កាត់)
  - ស្ថាបនាផ្លូវកៅស៊ូ (លេខ៥០៧ ដល់ផ្លូវលេខ១,៦១៩) ប្រវែង ៣,០០០ម៉ែត្រ នៅភូមិចំការសំរោង២និងស្ថាបនាផ្លូវក្រាលមិច ០៣ខ្សែ ប្រវែង ១០,៤០០ម៉ែត្រ នៅភូមិចំការសំរោង២
  - ស្ថាបនាផ្លូវចាប់ពីអង្គការហ្វាពន្លឺសិល្បៈមកដល់អង្គការហ្វាយវាម ០១ខ្សែ ប្រវែង ១,៨០០ម៉ែត្រ ភូមិចំការសំរោង២
  - ស្ថាបនាផ្លូវបេតុង ០៤ខ្សែ ប្រវែង ១៦,០០០ម៉ែត្រ នៅភូមិចំការសំរោង២ និងស្ថាបនាប្រព័ន្ធលូរំដោះទឹកមុខកាត់ ១០០ចំនួន ៤០០កង់ ស្មើ ៤០០ម៉ែត្រ នៅភូមិចំការសំរោង២
  - ការងារជួសជុលផ្លូវក្រាលកៅស៊ូប្រភេទផ្លូវលេខ៥៣០ ចាប់ពីផ្លូវជាតិលេខ៥ (ខាងជើងព្រះនាយណ៍) ដល់ផ្លូវលេខ៥១៥ ដែលមានប្រវែង ១,១៦៥ម៉ែត្រគុណ៨ម៉ែត្រ ដែលស្ថិតក្នុងសង្កាត់ចំការសំរោង ក្រុងបាត់ដំបង។

- ការងារជួសជុលផ្លូវក្រាលកៅស៊ូប្រភេទផ្លូវលេខ៥២៦ ចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវលេខ៥១៥ (ផ្លូវទៅវត្តពោធិ៍ ពីមុខស្នាក់ការ ស.ស.យ.ក ខេត្ត) ដែលមានប្រវែង ១,១៦៥ម៉ែត្រគុណ១០ម៉ែត្រស្ថិតក្នុងសង្កាត់ចំការសំរោងក្រុងបាត់ដំបង។[៧៦]

➢ **សង្កាត់ក្តុលដូនទាវ**

- ស្ថាបនាផ្លូវបេតុង ០២ខ្សែ ប្រវែង ៥៨០ម៉ែត្រ នៅភូមិក្តុល និងតាកុយ ( មូលនិធិសង្កាត់)
- ដាក់លូ ០១ខ្សែ ប្រវែង ៨០ម៉ែត្រ នៅភូមិតាកុយ (មូលនិធិសង្កាត់)
- ស្ថាបនាផ្លូវកៅស៊ូ ០១ខ្សែ ប្រវែង ៧២០ម៉ែត្រ នៅភូមិចុងព្រែក (មូលនិធិខេត្ត)
- ស្ថាបនាផ្លូវក្រាលក្រួសក្រហម ០២ខ្សែ ប្រវែង ១,៥០០ម៉ែត្រ នៅភូមិតាកុយនឹងតាព្រួច (សប្បុរសជន)
- កន្ឋតស្ថាបនាផ្លូវក្រាលក្រួសក្រហម ០១ខ្សែ និងដាក់លូ ១កន្លែង ប្រវែង ២៣៧ម៉ែត្រ នៅភូមិក្តុល (គណបក្សប្រជាជន, សប្បុរសជន)។

➢ **សង្កាត់ស្លាកែត**

- ស្ថាបនាផ្លូវបេតុង ០១ខ្សែ ប្រវែង ៤៧៤ម៉ែត្រ ដាក់លូរំដោះទឹកចេញពីភូមិប្រវែង ១៦៨ម៉ែត្រ និងប្រវែង ១៦៨ម៉ែត្រនៅភូមិ (មូលនិធិសង្កាត់)។

➢ **សង្កាត់អូរចារ**

- ដាក់លូរំដោះទឹក ០២ខ្សែ ប្រវែង ២៣២ម៉ែត្រ នៅភូមិអូរចារ កាប់គោថ្មី (ខេត្ត)
- ដាក់លូរំដោះទឹកមុខកាត់ ០,៨០ម៉ែត្រចំនួន ៣ខ្សែ ប្រវែង ១,០៤១ម៉ែត្រ នៅភូមិអូរចារ អញ្ចាញ អណ្តូងចេញ និងកាប់គោថ្មី (មូលនិធិសង្កាត់)
- ស្ថាបនាផ្លូវបេតុងលេខ (៥៥០) ប្រវែង ២០០ម៉ែត្រ នៅភូមិអញ្ចាញ (មូលនិធិសង្កាត់)។

➢ **សង្កាត់ទួលតាឯក**

- ស្ថាបនាផ្លូវបេតុង ០២ខ្សែ ប្រវែងសរុប ៥៦៦ម៉ែត្រ នៅភូមិទួលតាឯក (មូលនិធិសង្កាត់)
- ស្ថាបនាលូរំដោះទឹក ០២ខ្សែ ប្រវែង ២១១ម៉ែត្រ និងដាក់ចំនួន ០៨កន្លែង ភូមិទួលតាឯក អូរតាគាំ២ (មូលនិធិសង្កាត់)។

➢ **សង្កាត់រតនៈ**

- ផ្លូវក្រាលបេតុង ០១ខ្សែ ប្រវែង ៣៧០ម៉ែត្រ និងដាក់លូមុខកាត់ ០,៨០ម៉ែត្រ ប្រវែង ៣៧០ម៉ែត្រ នៅភូមិរំចេក៥ (មូលនិធិសង្កាត់)។

---

[៧៦] គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang ដកស្រង់នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣

➢ **សង្កាត់ព្រែកព្រះស្តេច**

- ស្ថាបនាផ្លូវបេតុង ០១ខ្សែ ប្រវែង ១៧៩ម៉ែត្រ និងដាក់លូមុខកាត់ ០,៨០ម៉ែត្រ ប្រវែង ៤៨៧ម៉ែត្រ ភូមិព្រែកតាតន់ ចំការឬស្សី (មូលនិធិសង្កាត់) ចាក់ដីបរិវេណសាលាសង្កាត់ចំនួន ៨០រថយន្ត (សង្កាត់)
- ការងារជួសជុលផ្លូវក្រាលកៅស៊ូប្រភេទផ្លូវលេខ៦១៤ ចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវលេខ១៥៣ (ផ្លូវមុខស្នងការនគរបាលខេត្ត ពីស្តុបរំចេក ដល់ផ្លូវមាត់ស្ទឹង) ដែលមានប្រវែង ១,៥២០ម៉ែត្រគុណ៨ម៉ែត្រ ស្ថិតក្នុងសង្កាត់រតនៈក្រុងបាត់ដំបង
- ការងារជួសជុលផ្លូវក្រាលកៅស៊ូប្រភេទផ្លូវលេខ៧១៦ ចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវលេខ៧០០ (មុខយោធាភូមិភាគទី៥ ផ្លូវចំការដូង) មានទំហំ ១,០៥០ម៉ែត្រគុណ៨ម៉ែត្រ ស្ថិតនៅក្នុងសង្កាត់ព្រែកព្រះស្តេចក្រុងបាត់ដំបង។

➢ **សង្កាត់វត្តគរ**

- ស្ថាបនាជួសជុលផ្លូវក្រាលក្រួសធម្មជាតិចំនួន ០៦ខ្សែ ប្រវែង ១០,៥១២ម៉ែត្រ នៅភូមិ(ប្រាបក្រសាំង២ខ្សែ ប្រវែង ៤,៤៥៧ម៉ែត្រ បល្ល័ង្ក ០២ខ្សែ ប្រវែង ២,៥៥០ម៉ែត្រ ខ្សាច់ពោយ ០១ខ្សែ ប្រវែង ២,៣០៥ម៉ែត្រ កំពង់សីមា ០១ខ្សែ ប្រវែង ១,២០០ម៉ែត្រ) មូលនិធិសង្កាត់
- ជួសជុលផ្លូវក្រាលមិច ០១ខ្សែ ប្រវែង ៥០៥ម៉ែត្រ នៅភូមិវត្តគរ (សប្បុរសជន)។

➢ **សង្កាត់អូរម៉ាល់**

- ស្ថាបនាផ្លូវបេតុង ០១ខ្សែ ប្រវែង ៤៧១ម៉ែត្រ និងដាក់លូភ្លោះ ០១កន្លែង លូទោល ៣កន្លែង នៅភូមិវត្តរកា (មូលនិធិសង្កាត់)
- ការងារជួសជុលផ្លូវក្រាលកៅស៊ូប្រភេទ DBST ផ្លូវលេខ១៣៩ ពីផ្លូវលេខ៣ ដល់ផ្លូវលេខ១០៦ (ផ្លូវក្រោយបុរី កាណាឌីយ៉ា) ដែលមានប្រវែង ៥០៥ម៉ែត្រគុណ៦ម៉ែត្រ ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ោក្រុងបាត់ដំបង
- ការជួសជុលផ្លូវលេខ៤ ផ្លូវលេខ១៥៣ ក្នុងក្រុងបាត់ដំបងដែលតភ្ជាប់ពីផ្លូវជាតិលេខ៥ ពីរង្វង់ព្រះនារាយណ៍មកដល់ផ្លូវ៥៧ ប្រវែង ២,៦០០ម៉ែត្រក្នុងសង្កាត់ទួលតាឯក សង្កាត់អូចា និងសង្កាត់ស្វាយប៉ោក្រុងបាត់ដំបង
- កំណត់ផ្លូវ៥៣ អតីតផ្លូវជាតិលេខ១០ រង្វង់ពេទ្យពីរ ដល់រង្វង់មូលនាងរំសាយសក់ មានប្រវែង ១,៦៧៨ម៉ែត្រ។
- ការដាក់ប្រព័ន្ធលូរំដោះទឹកក្នុងសង្កាត់ទួលតាឯក និងសង្កាត់វត្តគកក្រុងបាត់ដំបង។

- ណែនាំដល់រដ្ឋបាលក្រុង ឱ្យរៀបចំសណ្តាប់ធ្នាប់ឱ្យហើយជាស្រេច ទាំងចំណីផ្លូវ សំណង់អនាធិបតេយ្យ និងការលក់ដូរ គ្មានរបៀបរៀបរយនៅតាមសាធារណៈ ព្រោះបើមិនធ្វើការរៀបចំពីឥឡូវទេថ្ងៃទៅមុខនឹងធ្វើឱ្យសណ្តាប់ធ្នាប់ក្នុងក្រុងកាន់តែគ្មានរបៀបរៀបរយ ហើយពេលដែលមានគម្រោងចង់ពង្រីកផ្លូវបង្កការលំបាកក្រុមការងារក្នុងការដោះស្រាយ។[៧៧]
- ត្រូវចេះរៀបចំសំរាមកាកសំណល់ផ្សេងៗឱ្យមានរបៀប និងចូលរួមថែរក្សាផ្លូវថ្នល់ទាំងអស់ ដើម្បីយើងអាចប្រើប្រាស់ផ្លូវថ្នល់បានយូរអង្វែង ដើម្បីសោភ័ណភាពក្នុងក្រុងបាត់ដំបងឱ្យសាកសមនឹងក្រុងដែលទើបទទួលពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ាន។
- ក្រុងបាត់ដំបងបានស្ថាបនានៅផ្លូវកៅស៊ូ បង្កើតសោភ័ណភាពក្នុងក្រុងសម្រួលដល់ការធ្វើដំណើរជូនប្រជាពលរដ្ឋនៅក្នុងក្រុង រដ្ឋបាលខេត្តបាត់ដំបង និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបានជួសជុលកែលម្អផ្លូវក្រាលកៅស៊ូបង្កើនសោភ័ណភាពក្នុងក្រុងបាត់ដំបង ក៏ដូចជាសម្រួលចរាចរណ៍ជូនពលរដ្ឋឱ្យស្រួលធ្វើដំណើរ។
- ផ្លូវក្រាលកៅស៊ូចាប់ពីខាងមុខរូបសំណាកលោកតាដំបងក្រញូង រហូតដល់រង្វង់មូលព្រាបស (ផ្លូវជាតិលេខ៥) ដើម្បីបង្កើនសោភ័ណភាពក្នុងក្រុងបាត់ដំបង និងកាន់តែធ្វើឱ្យការធ្វើដំណើររបស់ប្រជាពលរដ្ឋបានស្រួលជាងមុនហើយផ្លូវនេះមានប្រវែងសរុបប្រមាណ ២,០០០ម៉ែត្រ ហើយក៏បានចាក់កៅស៊ូប្រភេទនេះជិតរួចហើយ ពីរង្វង់មូលព្រាបសទៅដល់ជិតចំណុចបំបែកផ្លូវល្បឿនលឿន។[៧៨]

យោងតាមរបាយការណ៍រដ្ឋបាលក្រុងបាត់ដំបងសាធារណការនេះជាសមិទ្ធផលកន្លងមកបានផ្តោតសំខាន់លើការងារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍បានបន្តកសាងជួសជុលថែទាំ ផ្លូវជាតិ ផ្លូវតាមសង្កាត់ និងតាមខេត្តបន្តកសាងផ្លូវជនបទឱ្យមានគុណភាពខ្ពស់។

### ២.៣.២. វិស័យអប់រំ សុខាភិបាល និង សង្គមកិច្ច

#### ២.៣.២.១. វិស័យអប់រំ យេនឌ័រ វប្បធម៌

វិស័យអប់រំដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ជួយធនធានមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈរបាយការណ៍ការអនុវត្តការងាររដ្ឋបាលឆ្នាំ២០២១ របាយការណ៍ការអនុវត្តការងាររដ្ឋបាលឆ្នាំ២០២២ ការងារអប់រំយុវជន និងកីឡាក្នុងឆ្នាំសិក្សា២០២១ និង២០២២។ ដើម្បីឈានទៅសម្រេចទិសដៅនៃកំណែទម្រង់ផែនការយុទ្ធសាស្ត្រលើវិស័យអប់រំផ្តោតសំខាន់លើដំណើរការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធលើការអនុវត្តកម្មវិធីស្តង់ដាការសិក្សាដើម្បីធានាបាននូវការអប់រំមួយប្រកបដោយសមធម៌ និងគុណភាពឈានទៅ

[៧៧] គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang ដកស្រង់នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣

[៧៨] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២១, ទំព័រទី២៦-២៩

សម្រេចជោគជ័យនូវផែនការនៃយុទ្ធសាស្ត្រវិស័យអប់រំ។ សកម្មភាពសិក្សាចំណេះទូទៅអប់រំក្រៅប្រព័ន្ធនៅគ្រប់កម្រិតសិក្សាក្នុងក្របខ័ណ្ឌសិទ្ធអំណាចទទួលខុសត្រូវរបស់រដ្ឋបាលក្រុងបាត់ដំបង ដំណើរការតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡាបានកំណត់ សម្រាប់ក្នុងក្រុងបាត់ដំបងមានការបែងចែកតាមផ្នែកអប់រំពីចំណេះទូទៅរហូតដល់ឧត្តមសិក្សាដែលរួមមានផ្នែក មត្តេយ្យសិក្សា បឋមភូមិ អនុវិទ្យាល័យ វិទ្យាល័យ។

ផ្នែកចំណេះទូទៅក្នុងក្រុងបាត់ដំបងរួមមាន ផ្នែកមត្តេយ្យសិក្សា(អប់រំកុមារតូច) មាន ៣២សាលា មាន ១៤អគារ មាន ៧៣បន្ទប់ មាន ៧៧ថ្នាក់មានសិស្សសរុប ២,៥៥២នាក់ សិស្សស្រី ១,២៧៤នាក់ មានគ្រូ ៩០ នាក់ ស្រី ៨៩នាក់ (មត្តេយ្យដាច់ ២០នាក់ ស្រី ១៩នាក់) ចំណុចខ្វះខាតខ្វះគ្រូមត្តេយ្យដែលមានបទពិសោធន៍ពីសាលាមត្តេយ្យមជ្ឈឹមគ្រូមត្តេយ្យខ្លះខ្ចីពីបឋមសិក្សា។ ផ្នែកបឋមសិក្សា មានចែកចេញជា ១០កម្រង មាន ៣៤ សាលា មាន ១២១អគារ មាន ៥២៨បន្ទប់ មាន ៤៦៥ថ្នាក់ (ថ្នាក់ទី១មាន ៩៣ថ្នាក់ ទី២មាន ៨៥ថ្នាក់ ទី៣មាន ៨០ ថ្នាក់ទី៤មាន ៧៤ថ្នាក់ ទី៥មាន ៦៨ថ្នាក់ និងទី៦មាន ៦៥ថ្នាក់) មានសិស្សសរុប ១៦,៦៨៣នាក់សិស្ស ស្រី ៨,០១៣នាក់ មានគ្រូ ៦៦២នាក់ ស្រី ៤៨៣នាក់។ ផ្នែកអនុវិទ្យាល័យមាន ០៥សាលា មាន ១៩អគារ មាន ១០៥ បន្ទប់ មាន ៦១ថ្នាក់ មានសិស្ស ២,៣៧៦នាក់ សិស្សស្រី ១,២១៩នាក់ មានគ្រូ ២១៦នាក់ ស្រី ១២១នាក់។ សង្កាត់ដែលមិនទាន់មានអនុវិទ្យាល័យមាន ០១សង្កាត់ស្លាកែតស្មើ ៩០%។ សិស្សដែលបានឆ្លងមធ្យមសិក្សាទុតិយភូមិសរុប ៨០០នាក់ ស្រី ៤៣៨នាក់។ ការសាងសង់សាលារៀនអគារសិក្សាមានចំនួន ០៩ខ្នង មាន ៥៥ បន្ទប់ ក្នុងនោះការសាងសង់អគារសិក្សាសាលាបឋមសិក្សា ០២ខ្នង មាន ០៧បន្ទប់ (សហគមន៍ ០១ខ្នង ០៣ បន្ទប់ជប៉ុន ០១ខ្នង ០៤បន្ទប់) នៅសាលាបឋមសិក្សាវត្តគរសាងសង់អគារសិក្សា ០១ខ្នង មាន ០៣បន្ទប់ នៅសាលាបឋមសិក្សាអូរតាគាំ១សង្កាត់ទួលតាឯក (ជប៉ុន) សាងសង់អគារសិក្សា ០១ខ្នង មាន ០២បន្ទប់ នៅសាលាបឋមសិក្សាអង់សង្កាត់អូរចារ(ជប៉ុន) សាងសង់អគារសិក្សា ០២ខ្នង មាន ០៥បន្ទប់ (សហគមន៍ ០១ ខ្នង ០២បន្ទប់ ជប៉ុន ០១ខ្នង ០៣បន្ទប់) នៅសាលាបឋមសិក្សាតាព្រួច។ សាងសង់អគារសិក្សា ០១ខ្នង មាន ០៥បន្ទប់នៅសាលាបឋមសិក្សាវត្តកំផែងសង្កាត់ស្វាយប៉ោ។[៧៩]

ការអប់រំ និងផ្សព្វផ្សាយទាក់ទងយេនឌ័រដែលជាកិច្ចការរបស់មន្ទីរក្រសួងកិច្ចការនារីជាការផ្តល់នៅតម្លៃស្ត្រី និងបុរសស្មើគ្នា ក៏ជាការបំពេញឱ្យគ្នាទៅវិញទៅមកនៅភាពខ្វះខាត និងភាពខ្វះចន្លោះ។ បច្ចុប្បន្នស្ត្រីមានការងារក៏ដូចជាអាចធ្វើអ្វីដូចជាបុរសដែរហើយការផ្តល់យេនឌ័រដល់ស្ត្រីមានអត្រាខ្ពស់ ដោយសារមានការយល់ដឹងពីយេនឌ័រច្រើន កិច្ចការស្ត្រីអាចទទួលបានប្រាក់ខែស្មើនឹងបុរសដោយមើលលើសមត្ថភាពបុគ្គលវិញ បូករួមទាំងមានការបណ្តុះបណ្តាលសមត្ថភាពរបស់ស្ត្រីក្នុងការងារលើកម្ពស់សមភាពយេនឌ័រក្នុងការបង្កើតឱ្យស្ត្រីមាន

[៧៩] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២១, ទំព័រទី៣៥-៣៦

ភាពអង់អាចក្នុងការបំពេញការងារប្រកបដោយ ប្រសិទ្ធភាព និងគុណភាព។ សម្រាប់ការរីកចម្រើនរបស់ស្ត្រីកម្ពុជា ជាពិសេសការងារពាក់ព័ន្ធនឹងសមភាពយេនឌ័រក៏ដូចការបង្កើនភាពអង់អាចដល់ស្ត្រីក្រោមក្របខ័ណ្ឌការងាររបស់ក្រសួងកិច្ចការនារីក្នុងជំនួបពិភាក្សាក្រុមការងារបានធ្វើការចែករំលែកអំពីវឌ្ឍនភាព និងការរីកចម្រើនរបស់ស្ត្រីមានប្រាំមួយដូចជា ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ការអប់រំស្ត្រី សុខភាពភាពជាអ្នកដឹកនាំរបស់ស្ត្រីការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងការប្រែប្រួលអាកាសធាតុព្រមទាំងបានបញ្ជាក់អំពីក្របខ័ណ្ឌការងារយុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយនៃកម្មវិធីតាមវិស័យក្នុងក្រសួងស្ថាប័នមួយចំនួនដែលក្នុងសាធារណៈឯកជន។ សង្គមស៊ីវិល និងអង្គការដៃគូទាំងថ្នាក់ជាតិ ក្រោមជាតិស្របតាមយន្តការនានារបស់រាជរដ្ឋាភិបាលកម្ពុជាវប្បធម៌ក្នុងក្រុងបាត់ដំបងវិញ ក៏មានការចុះត្រួតពិនិត្យនៅតាមក្រុងតំបន់នីមួយៗផ្សព្វផ្សាយសហការជាមួយដៃគូក្នុងកិច្ចសហប្រតិបត្តិការ រួមជាមួយអង្គការនានាក្នុងទិសដៅនៃគោលបំណងផ្សព្វផ្សាយដែលជាការសហការចូលរួមរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្រុងបាត់ដំបងបូករួមទាំងផែនការដែលជាទិសដៅការងារដែលទទួលបានរបស់ការផ្សព្វផ្សាយតាមបណ្តាសង្គម ការសហការរវាងដៃគូកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីលើកស្ទួយវិស័យវប្បធម៌នានាឱ្យមានភាពរីកចម្រើន។[៩០]

**២.៣.២.២. សុខាភិបាល និងសង្គមកិច្ច**

នៅក្នុងរបាយការណ៍ឆ្នាំកន្លងមកកំឡុងពេលកំពុងមានការផ្ទុះនៅជំងឺកូវី-១៩ ដែលជាមេរោគឆ្លងបានធ្វើឱ្យមានការលំបាកជាខ្លាំង ប្រជាជនទាំងអស់គ្រប់គ្នាត្រូវតែធ្វើចត្តាឡីស័កគ្រប់គ្នាមិនថាក្មេងចាស់។ រដ្ឋបាលក្រុងបាត់ដំបងបានបង្កើតក្រុមការងារសម្រាប់ប្រយុទ្ធប្រឆាំង និងជំងឺនេះដោយមានការរៀបចំមេរៀនទៅតាមមណ្ឌលនីមួយៗក្នុងក្រុងបាត់ដំបង និងការចូលរួមផ្សព្វផ្សាយនៅវិធានការការពារឱ្យមានប្រសិទ្ធភាពខ្ពស់សមស្របក្នុង បញ្ហារដ្ឋបាលក្រុងបានជួយជាជំនួយទៅប្រជាជនដែលបានឆ្លងការពារមិនឱ្យមានការរាលដាលជាបន្តទៀតកាន់តែខ្លាំងឡើង និងមានការចាក់នៅវ៉ាក់សាំងការពារពីការឆ្លងនៅជំងឺនេះដែល។ ដោយយោងតាមទិន្នន័យរបាយការណ៍ការអនុវត្តការងាររដ្ឋបាលឆ្នាំកន្លងមកដោយវិស័យសុខាភិបាលបានផ្តល់សកម្មភាពសេវាសុខាភិបាលតាមមណ្ឌលសុខភាពបានពិនិត្យពិគ្រោះជំងឺក្រៅបានចំនួន ៦៦,៥៣១នាក់ ស្រី ៣៧,៧៧៤នាក់ កុមារក្រោមអាយុ ១៤ឆ្នាំ ចំនួន ១៩,២៤៤នាក់បានធ្វើការបញ្ជូនអ្នកជំងឺចំនួន ១៥៥នាក់។ ពិនិត្យផ្ទៃពោះមុនពេលសម្រាលកូនលើកទី២ចំនួន ១,៩៥០នាក់ ពិនិត្យលើកទី៤ចំនួន ១,៧២១នាក់ ពិនិត្យក្រោយសម្រាលលើកទី២ចំនួន ៧៥៦នាក់។ សកម្មភាពសម្រាលកូននៅក្នុងមណ្ឌលសុខភាពបានចំនួន ៦៦៥នាក់សកម្មភាពពន្យាកំណើតបង្អាក់កំណើតអ្នកកំពុងប្រើប្រាស់សរុបចុងឆ្នាំចំនួន ២,៩៥៦នាក់ សកម្មភាពនៃការចាក់ថ្នាំបង្ការកុមារអាយុក្រោម ១ឆ្នាំមានបង្ការជំងឺរបេងបានចំនួន ១,១៤០នាក់ បង្ការជំងឺក្អក មាន់ខាន់ស្លាក់ តេតាណុសបាន

[៩០] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២១, ទំព័រទី៣៤-៣៦

ចំនួន ២,៦៨១នាក់ បង្ការជំងឺកញ្រ្ជឹលបានចំនួន ២,៧៤០នាក់ បង្ការជំងឺតេតាណុសដល់ស្រ្តីមានផ្ទៃពោះបាន ចំនួន ១,៧៦៧នាក់ បង្ការរលាកថ្លើមប្រភេទបេក្រោម២៤ម៉ោងចំនួន ១,០៣៦នាក់ ចាក់សព្វគ្រប់ ២,៦៦៦នាក់។ សកម្មភាពប្រយុទ្ធប្រឆាំងទៅនឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលក្រុងបាត់ដំបងបានធ្វើការផ្សព្វផ្សាយការណែនាំដល់គ្រប់អង្គភាពការិយាល័យ និងគ្រប់សង្កាត់បង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការណែនាំដល់មន្ត្រីក្រោមឱវាទដល់ប្រជាពលរដ្ឋដែលគ្រប់អាយុត្រូវទទួលថ្នាំបង្ការជំងឺកូវីដ-១៩ និងទទួលនៅដុសជំរុញលើកទី១ ទី២ ទី៣ ទី៤ និងលើកទី៥ ដែលមានទីតាំងសម្រាប់ផ្តល់ចាក់ថ្នាំនៅតាមមណ្ឌលសុខភាពសង្កាត់ទាំង៨ ក្នុងក្រុងបាត់ដំបង។

របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងប្រចាំឆ្នាំ២០២២

| ល.រ | ឈ្មោះមណ្ឌលសុខភាព | បង់លុយដោយខ្លួនឯង | គម្រោងមូលនិធិសមធម៌ | បេឡាជាតិសន្តិសុខសង្គម | ករណីលើកលែង |
|---|---|---|---|---|---|
| ១ | ស្វាយប៉ោ | ៥,៦៧២ | ៤,១៥៣ | ៧០៧ | ២,៤៦៨ |
| ២ | ស្លាកែត | ២,២០៧ | ៦,៤៥៩ | ៤៨៨ | ៥១៨ |
| ៣ | ក្តុលដូនទាវ | ៤,០៣០ | ៦,០៦២ | ១៣៣ | ៣៩៩ |
| ៤ | ទួលតាឯក | ២,៨០៤ | ៤,២៩២ | ៣៨០ | ១០,៩៧៩ |
| ៥ | វត្តគរ | ៤,៥២០ | ៧,៩១៩ | ៧០២ | ២៦១ |
| ៦ | អូរម៉ាល់ | ១,៩៩៦ | ៥,១៦២ | ២២២ | ២,០៤០ |
| ៧ | រតនៈ | ១,៨៣៤ | ៤,៤៤៦ | ៥ | ១,៦៣១ |
| ៨ | ចំការសំរោង | ៥,៥៨៦ | ៧,២៣៥ | ២១៣ | ៦៥៩ |

ដោយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ជូនដល់ប្រជាពលរដ្ឋដូចខាងក្រោម ដូសទី១ សរុបចំនួន ៥២,៦៦៧នាក់/ស្រី ២៧,៦៩៩នាក់ និងការចាក់ដូសទី២ សរុបចំនួន ៥២,៧៧២នាក់/ស្រី ២៨,២៦២នាក់ ដូសទី៣ សរុបចំនួន ២៦,១០៧នាក់/ស្រី ១៤,៣៨០នាក់ ដូសទី៤ សរុបចំនួន២១,១៨៧នាក់/ស្រី ១១,៦៣៦នាក់ ដូសទី៥ សរុបចំនួន ៣,០៥៦នាក់/ស្រី ១,៥៨២នាក់។[៨១]

ការងារសង្គមកិច្ចមានការបែងចែកក្នុងការជួយអតីតយុទ្ធជនការងារជួយដល់ជនពិការដែលនៅក្នុងសង្កាត់រតនៈ ទួលតាឯក អូចារ មានជនពិការដោយសារតែគ្រាប់មីនសំណល់ជាតិផ្ទុះពីសង្គ្រាម និងកត្តាផ្សេងទៀតក្នុងការការពារកុមារពីការប្រើអំពើហិង្សា ការរំលោភបំពានផ្លូវភេទ ស្រីមានផ្ទៃពោះ កេងប្រវ័ញ្ច ការជួយកុមារដែលមានបញ្ហាស្មារតីការចុះសួរសុខទុក្ខប្រជាជនដែលមានការខ្វះខាត។ ដោយតាមមន្ទីរសង្គមកិច្ចរបស់រាជរដ្ឋាភិបាល

[៨១] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី២៨-៣២

កម្ពុជានៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២នេះ បានចេញសេចក្តីប្រកាសព័ត៌មានស្តីពីការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងការរៀបចំដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដើម្បីឆ្លើយតបសម្ពាធអតិផរណាសង្គមកិច្ចក្រោយពីចាប់ផ្តើមមានកូវីត-១៩ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាក្រុងបាត់ដំបងបានទទួលនៅជំនួយឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណាចំនួន ០៣លើកដែលលើកទី១ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ លើកទី២នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ និងលើកទី៣ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។ រាជរដ្ឋាភិបាលសម្រេចដាក់ចេញវិធានការអន្តរាគមន៍ជំនួយសង្គមដូចខាងក្រោមសម្រាប់ក្រុងបាត់ដំបងការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។ ដោយមើលឃើញពីភាពចាំបាច់ក្នុងការបន្តជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រងាយរងគ្រោះ ជាពិសេសក្នុងបរិបទនៃការទទួលរងនូវផលប៉ះពាល់ទ្វេដងពីវិបត្តិជំងឺកូវីដ-១៩ និងការកើនឡើងថ្លៃទំនិញខ្ពស់ដែលផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរ។ សម្រេចបន្តអនុវត្តកម្មវិធីជំនួយឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ រហូតដល់ដំណាច់ឆ្នាំ២០២២ និងបន្តពិនិត្យវាយតម្លៃស្ថានភាពរៀងរាល់បីខែម្តង ការរៀបចំដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដើម្បីឆ្លើយតបសម្ពាធអតិផរណារបស់ប្រជាជនមានភាពងាយរងគ្រោះនៃគ្រួសារប្រជាពលរដ្ឋងាយរងហានិភ័យត្រូវបានកំណត់ដោយផ្តោតលើគ្រួសារដែលរស់នៅកៀកបន្ទាត់នៃភាពក្រីក្រដោយមានរួមបញ្ចូលនៅក្នុងគ្រួសារនោះនូវជនទាំងឡាយដូចជា ជនមានពិការភាព កុមារអាយុក្រោម ០២ឆ្នាំ ជនចាស់ជរាមានអាយុចាប់ពី ៦០ឆ្នាំឡើង ដោយក្នុងនោះមានស្ត្រីជាមេគ្រួសារការរស់នៅដោយគ្មានស្វាមីគ្រួសារដែលមានសមាជិកសុទ្ធជាកុមារ និងមនុស្សចាស់ជរា (មិនមានសមាជិកគ្រួសារអាយុពី១៩ ដល់៥៩ឆ្នាំ)។[៩២]

### ២.៣.៣. បញ្ហាប្រឈម

តាមរយៈការសង្កេតក្នុងភាពជាក់ស្តែងស្របពេលដែលកំពុងអភិវឌ្ឍន៍នេះ ក៏នៅតែមានបញ្ហាប្រឈមកើតមានផងដែរ។ ជាការរាំងស្ទះក្នុងការអនុវត្តផែនការនៃការកំណត់គោលដៅបន្តបន្ទាប់ទៀតដែលគ្រងធ្វើបន្ថែមទៀតនាពេលខាងមុខ បញ្ហាមួយចំនួនដែលនៅក្នុងក្រុងតាមទីប្រជុំជន។ ដោយពុំទាន់មានការដោះស្រាយបានត្រឹមត្រូវមានប្រសិទ្ធមាននៅឡើយដោយបញ្ហាបច្ចុប្បន្នក្នុងក្រុងបាត់ដំបងរួមមាន ប្រព័ន្ធកសិកម្ម ការធ្វើប្រព័ន្ធលូតាមបណ្តាផ្លូវក្នុងក្រុង ការគ្រប់គ្រងសំរាម តំបន់ពាណិជ្ជកម្ម ទេសចរណ៍ សន្តិសុខសណ្តាប់ធ្នាប់ ការសាងសង់ផ្លូវ និងរចនាសម្ព័ន្ធ។

[៩២] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២, ទំព័រទី២៩-៣០

បញ្ហាធម្មជាតិកសិកម្មតែងតែមានការជួបប្រទះមិនល្អខ្លះអាស្រ័យលើអាកាសធាតុ ពូជស្រូវ ទឹក ដី គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះ ការរញ្ជួយដី ដែលជាបញ្ហាកើតឡើងមិនអាចធ្វើការបង្កមុនការលិច ទឹកជំនន់ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ដំណាំគ្រប់ប្រភេទ ជាពិសេសដំណាំស្រូវដែលធ្វើឱ្យរងការខូចខាត ខ្លាំងបណ្តាលឱ្យប៉ះពាល់ផ្ទៃដីដាំដុះស្រូវសរុប ៤៥,០១៥ហិកតា ផ្ទៃដីដែលខូចខាតមានចំនួន ២៦,៨០៥ហិកតា លើគ្រួសារសរុបប្រមាណជាង ២ម៉ឺនគ្រួសារហើយគ្រួសារដែលខូចខាតស្រូវមានចំនួន ១២,៤៥៤គ្រួសារ សម្រាប់ ប្រជាជនកសិករក្នុងការបង្កបង្កើនផលកសិកម្ម ការទទួលបានទិន្នផលតិច និងបញ្ហាប្រព័ន្ធទឹកធារាសាស្ត្រសម្រាប់ ផ្គត់ផ្គង់។ កង្វះពូជក្នុងការដាំដុះស្រូវ បន្លែនានាធ្វើឱ្យប្រជាកសិករទទួលបាននៅទិន្នផលទាប និងប៉ះពាល់ដល់ សេដ្ឋកិច្ចក្នុងខេត្តក្រុង ជាពិសេសប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ អន្តរជាតិ (ការនាំចេញ)។ រីឯការធ្វើប្រព័ន្ធលូតាម បណ្តាផ្លូវក្នុងក្រុងបាត់ដំបងតាមភាពជាក់ស្តែងនៅក្នុងក្រុងនៅតែមានបញ្ហានៃការកកស្ទះលូ ទឹកកង្វក់ជាបញ្ហា នៃប្រព័ន្ធបង្ហូរទឹកដោយគ្មានកន្លែងបង្ហូរចេញ ដែលជាកត្តានៃបញ្ហាដែលបណ្តាលឱ្យទឹកលិចនៅរដូវវស្សា រៀងរាល់ឆ្នាំមិនអាចផ្គត់ផ្គង់ទឹកស្អាតនៅក្នុងក្រុង និងអនាម័យសុខភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្រុង ការបោះចោលនៅសំរាមផ្តេសផ្តាសរបស់ប្រជាជនដែលមានទាំង ប្លាស្ទិច ក្រដាស សំបកកំប៉ុងដែលសំរាមក្នុង មួយថ្ងៃមាន ប្រហែល ៣០០តោន សំរាមមានការកកស្ទះដោយសារតែប្រជាជនមិនធ្វើការបង់ប្រាក់សម្រាប់ការ ដឹកជញ្ជូនសំរាមដែលសំរាមទាំងនោះគ្មានអ្នកមកយកដែលធ្វើឱ្យកកស្ទះ និងខូចខាតបរិស្ថានជាខ្លាំង បូករួមការ ចោលសំរាមតាមដងផ្លូវតាមភាពជាក់ស្តែងក្នុងក្រុងនៅមានសំរាមរៀបចំមិនទាន់បានត្រឹមត្រូវ ការរៀបចំកន្លែង ដាក់សំរាមនៅខ្វះខាតខ្លាំង។ លើសពីនេះតំបន់ពាណិជ្ជកម្ម ជាតំបន់ពិសេសក្នុងការអភិវឌ្ឍភាពរីកចម្រើនជាផ្នែក សេដ្ឋកិច្ចតែនៅខ្វះរបៀបរៀបរយនៃការគ្រប់គ្រង ការសាងសង់នៃសំណង់ដែលក្នុងដំណើរការអនុវត្តការងារ សាងសង់មិនទាន់បានល្អនៅឡើយទេ។[៩៣]

ផ្លូវថ្នល់ និងសណ្តាប់ធ្នាប់ក្រុងជាបញ្ហាចម្បងរួមមានកត្តាការខូចខាតផ្លូវដោយគ្រោះធម្មជាតិទឹកជំនន់ ការខូចខាតដោយការធ្វើដំណើរ និងការខូចខាតដោយការឈូសឆាយ។ល។ ដោយនៅក្នុងក្រុងបាត់ដំបងកំពុង តែមានការសាងសង់ និងជួសជុលផ្លូវជាច្រើនដោយសារតែការធ្វើដំណើរប្រជាពលរដ្ឋច្រើន ការធ្វើដំណើររបស់ រថយន្តធំដែលផ្ទុកនៅទំនិញលើសចំណុះពេលធ្វើដំណើរធ្វើឱ្យផ្លូវមានការខូចខាតជាទម្ងន់ដែលពិបាកធ្វើដំណើរ ជាខ្លាំងដែលទាមទារឱ្យមានការជួសជុលច្រើនទៅលើផ្លូវទាំងនោះជាការចំណាយថវិកាច្រើន។ ម្យ៉ាងវិញទៀត ដោយសារតែការធ្វើប្រព័ន្ធលូដែលត្រូវការធ្វើ និងឈូសឆាយនៅតាមដងផ្លូវដែលជាបញ្ហាសម្រាប់ប្រជាជនក្នុង ការធ្វើដំណើរមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ក្នុងក្រុងនៃការដាក់ស្លាកយីហោអនាធិបតេយ្យមិនសមស្រប

---

[៩៣] គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang ដកស្រង់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

តាមការដាក់ចេញនៃការរៀបចំ ការកំណត់បរិវេណ ការរៀបចំដែលតាមសេចក្តីណែនាំរដ្ឋបាលខេត្តក្រុងនៅតែមានផលប៉ះពាល់ការដាក់អីវ៉ាន់នៅចញ្ចើមផ្លូវ ការដាក់មកលើផ្លូវសាធារណៈធ្វើឱ្យបាត់បង់នៅសោភ័ណភាពក្រុង ចំណែកឯភាពអសន្តិសុខក្នុងក្រុងបាត់ដំបងមួយរយៈកើតមាន ដោយសារតែមានយុវជនមួយចំនួនបានប្រើប្រាស់អំពើហិង្សា ប្រើប្រាស់គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តបទល្មើសខុសច្បាប់ ដែលបញ្ហាចម្បងនៅក្នុងក្រុងបាត់ដំបងជាការបង្កនៅភាពរីករវនាំឱ្យមានភាពអសន្តិសុខធ្វើឱ្យប្រជាជនមានភាពភិតភ័យក្នុងការរស់នៅក្រុងបាត់ដំបងភាគច្រើនតាមការចុះផ្សាយរបស់រដ្ឋបាលក្រុងបាត់ដំបងនាពេលកន្លងមក។ ការប្រព្រឹត្តនៅបទល្មើសខុសច្បាប់ដែលឧស្សាហ៍កើតមានដូចជា លួច ឆក់ ប្លន់ ការគំរាមគំហែង ការបង្ករបួសដល់ប្រជាជនក្នុងក្រុងដែលជាភាពអសន្តិសុខខ្លាំងមានភាពចលាចល ដោយក្រុមក្មេងស្ទាវមួយចំនួនដែលអាចប៉ះពាល់ដល់សុវត្ថិភាពប្រចាំថ្ងៃសម្រាប់ប្រជាជនក្នុងក្រុងកើតចេញពីកត្តាទាំងនេះរបស់យុវជនមួយចំនួនដែលនាំឱ្យមានភាពមិនប្រក្រតីក្នុងក្រុង។[៩៤]

### ២.៣.៤. ដំណោះស្រាយ

ក្រោយពីទទួលបានវឌ្ឍនភាពពីគ្រប់វិស័យឃើញថាមានលក្ខណៈល្អប្រសើរច្រើនតែស្របពេលនេះក៏មានភាពខ្វះខាតមួយចំនួនដែលជាបញ្ហាបន្ថែម ក្រោយពីមានការអភិវឌ្ឍបញ្ហាដែលទាមទារក្នុងដំណោះស្រាយរួមមាន ការដោះស្រាយបញ្ហាក្រោយពីទឹកជំនន់ផ្ទៃដីដែលអាចធ្វើការស្តារឡើងវិញប្រហែលសរុប ១២,៥៥៤ ហិកតាត្រូវបានប្រើប្រាស់គ្រាប់ពូជចំនួន ១,២៤៥តោន និង៤០០គីឡូក្រាមដែលរហូតមកដល់ពេលនេះគ្រាប់ពូជទាំងនោះបានធ្វើការដាំដុះលូតលាស់បានយ៉ាងល្អប្រសើរស្ទើរតែ ១០០% ខណៈដែលប្រភពទឹកមានភាពគ្រប់គ្រាន់សម្រាប់ក្នុងផ្គត់ផ្គង់ និងធ្វើការប្រមូលផលបានល្អជាង។ ប្រជាកសិករបានទទួលពូជស្រូវក្នុងការស្តារលទ្ធភាពឡើងវិញធ្វើឱ្យដំណាំស្រូវមានការលូតលាស់បានយ៉ាងល្អ ការណែនាំបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអនុវត្តបច្ចេកទេសនៃការដាំដំណាំដែលធ្វើយ៉ាងណាឱ្យទទួលបានសមិទ្ធផលច្រើននឹងអាចបានប្រាក់កម្រៃខ្ពស់។ ការធ្វើប្រព័ន្ធលូតាមបណ្តាផ្លូវក្នុងក្រុងបាត់ដំបងកំពុងតែខិតខំព្យាយាមជួសជុល ដោះស្រាយឱ្យបានឆាប់រហ័សការកកស្ទះលូមានទឹកដក់តាមដងផ្លូវត្រូវធ្វើការត្រួតពិនិត្យពន្លឿននៃការដោះស្រាយជូនប្រជាជនដើម្បីសម្រួលដល់ការធ្វើដំណើររក្សានៅសោភ័ណភាពក្រុង ការផ្គត់ផ្គង់ទឹកស្អាត បន្ថែមការសាងសង់ប្រព័ន្ធទឹកការចម្រុះប្រត្តិកម្មទឹកស្អាតសម្រាប់ប្រជាជនប្រើប្រាស់ ការចុះត្រួតពិនិត្យការផ្សព្វផ្សាយរោងចក្រសហគ្រាសនានាពេលបញ្ចេញកាកសំណល់ត្រូវមានចម្រុះមុនបង្ហូរចូលលូកាកសំណល់នានា បូករួមទាំងការថែរក្សានៅបរិស្ថានក្នុងក្រុងបាត់ដំបង

[៩៤] គេហទំព័រ https://battambang.maff.gov.kh ដកស្រង់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

ការដាក់ធុងសំរាមតាមដងផ្លូវបន្ថែមទៀតឱ្យមានសណ្តាប់ធ្នាប់អនាម័យក្នុងក្រុង និងតាមបណ្តាផ្ទះប្រជាជនគួរធ្វើការទុកដាក់សំរាមមុខផ្ទះឱ្យមានរបៀបរៀបរយ ដើម្បីងាយស្រួលនៅពេលបុគ្គលិកមកប្រមូលសំរាម។

ក្រុងបាត់ដំបងមានតំបន់ពាណិជ្ជកម្មមួយចំនួនដែលកំពុងតែអភិវឌ្ឍន៍តាមសង្កាត់រតនៈ សង្កាត់អូរចារដែលមានការវិនិយោគច្រើនទាមទារឱ្យមន្ត្រីចុះត្រួតពិនិត្យ និងធ្វើការផ្សព្វផ្សាយរៀបចំប្រព័ន្ធនៃការសាងសង់ឱ្យមានសណ្តាប់ធ្នាប់ជាងនេះដែលស្របតាមគោលណ៍ការរបស់រដ្ឋាភិបាលក្នុងការសាងសង់នៃក្រុមហ៊ុនវិនិយោគធំៗ។ ទេសចរណ៍ជាផ្នែកសេដ្ឋកិច្ចសំខាន់សម្រាប់ក្នុងការជួយឱ្យជីវភាពរបស់ប្រជាជនក្នុងក្រុងបាត់ដំបងតាមជាយក្រុងនិងបណ្តាស្រុកទទួលបានជីវភាពធូរធារ ការដោះស្រាយបញ្ហាទាមទារឱ្យមាននៅយុទ្ធសាស្ត្រក្នុងការការពារអភិវឌ្ឍន៍បន្ថែមតាមតំបន់ចាប់ពីរដ្ឋបាលក្រុងតាមបណ្តាសង្កាត់នីមួយៗ ការផ្តល់មតិ ការចុះត្រួតពិនិត្យនៅតាមតំបន់ដែលមានធនធានធម្មជាតិក្នុងគោលបំណងជួយស្តាបនា ការផ្តល់ជាគំនិតមតិយោបល់តាមរមណីយដ្ឋានក្នុងតំបន់កម្សាន្ត ការរកវិធីសាស្ត្រយ៉ាងណាឱ្យមានភាពល្អប្រសើរទទួលបានការកើនឡើងនៃភ្ញៀវទេសចរ។ ជាពិសេសក្នុងជំនាញវិជ្ជាជីវៈក្នុងការណែនាំតាមតំបន់ធម្មជាតិសម្រាប់ភ្ញៀវទេសចរក្នុងការបង្ហាញនៅសារៈសំខាន់ការកកើតតំបន់នោះក្នុងន័យផ្សព្វផ្សាយតៗគ្នាពីតំបន់ធម្មជាតិ ការណែនាំសម្បត្តិធម្មជាតិប្រយោជន៍មានការចាប់អារម្មណ៍ធ្វើការស្វែងយល់សម្រាប់ធនធានធម្មជាតិ ផ្លូវថ្នល់ត្រូវមានសណ្តាប់ធ្នាប់។ រចនាសម្ព័ន្ធជាកត្តាសំខាន់សំដៅដល់ចំណីផ្លូវ សំណង់ផ្លូវថ្នល់ ចំណតរថយន្ត បរិវេណចំណតស្ថានីយសេវាតាមដងផ្លូវដែលត្រូវមានដំណោះស្រាយរួមមាន ផ្លូវថ្នល់ដោយធ្វើការផ្សព្វផ្សាយពីការធ្វើដំណើរចរាចរណ៍ផ្លូវគោកសម្រាប់ឱ្យប្រជាជនមានការយល់ដឹងមិនឱ្យដាក់របស់របរលើសចំនួនដែលនាំឱ្យខូចផ្លូវត្រូវមានការចុះត្រួតពិនិត្យឱ្យជាប់លាប់តាមដានផ្លូវថ្នល់ឱ្យមានរបៀបរៀបរយ ការរៀបចំតាមចិញ្ចើមផ្លូវ ការដាក់ស្លាកយីហោឱ្យសមរម្យស្របតាមសេចក្តីណែនាំរបស់រដ្ឋបាលក្រុងបាត់ដំបង។[៩៥] ការសាងសង់ផ្លូវបន្ថែមតាមរយៈការដាក់ផែនការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនដែលមានតួនាទីក្នុងការចាត់ចែងធ្វើការកែប្រែ ចូលរួមអភិវឌ្ឍន៍ការពង្រីកផ្លូវបន្ថែមតាមរយៈតម្រូវការរបស់ប្រជាជនក្នុងក្រុងបាត់ដំបង និងការគ្រប់គ្រងសណ្តាប់ធ្នាប់ឱ្យបានល្អ ជាមួយគ្នានេះការរៀបចំអនាម័យជាផ្នែកមួយយ៉ាងសំខាន់ក្នុងការយកចិត្តទុកដាក់របស់រដ្ឋបាលខេត្ត ក្រុងសម្រេចបាននូវការសាងសង់ទីលានកប់សំរាមមួយកន្លែងដែលមានផ្ទៃដីសរុប ២០៨ហិកតា ការញែកសំរាម រណ្តៅសំណល់គ្រោះថ្នាក់ រណ្តៅកប់សំរាម និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ចេញពីសំរាម។

[៩៥] សេចក្តីណែនាំស្តីពីការរៀបចំតាំងស្លាកយីហោ និងការប្រើប្រាស់ដីចំណីផ្លូវ នៅក្នុងតំបន់អភិរក្ស និងជុំវិញតំបន់អភិរក្សក្រុងបាត់ដំបង ខេត្តបាត់ដំបង, លេខ០០៨/២២សណន, ទំព័រទី១

សន្តិសុខសុវត្ថិភាពក្នុងគោលបំណងដើម្បីពង្រឹងនៅសុវត្ថិភាពការជួយទប់ស្កាត់ និងធ្វើការដោះស្រាយឱ្យទាន់ពេល។ ដោយចូលរួមការពង្រឹងនៅសន្តិសុខក្នុងក្រុងឱ្យមានភាពតឹងរឹង ការចុះពិនិត្យតាមទីសាធារណៈក្នុងក្រុងតាមតំបន់សំខាន់ ការដាក់កងកម្លាំងការពារប្រជាជន ការអប់រំ និងផ្សព្វផ្សាយសម្រាប់យុវជន ជាពិសេសការត្រួតពិនិត្យនៅតាមហាងមួយចំនួននៅពេលយប់ ដើម្បីជៀសវាងអំពីបញ្ហានានានៃបទល្មើសដែលខុសច្បាប់ដែលឧស្សាហ៍កើតមានដូចជា លួច ឆក់ ប្លន់ ការគំរាមគំហែង និងការបង្ករបួសដល់ប្រជាជនក្នុងក្រុងដែលជាភាពអសន្តិសុខខ្លាំង ការបង្កភាពចលាចលដោយក្រុមក្មេងស្ទាវមួយចំនួនក្នុងក្រុងដែលជាបញ្ហាចម្បងប៉ះពាល់ដល់សុវត្ថិភាពប្រចាំថ្ងៃរបស់ប្រជាជនក្នុងក្រុងបាត់ដំបងដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ក៏ដូចជាការចុះត្រួតពិនិត្យជាប្រចាំទៅតាមតំបន់សំខាន់ក្នុងក្រុងបាត់ដំបង ការអនុវត្តផែនការឱ្យជាប់លាប់ និងការចូលរួមពីប្រជាជន ការសហការជាមួយនគរបាលក្នុងការអនុវត្តតាមការណែនាំរបស់នគរបាលក្រុងបាត់ដំបងក្នុងដំណើរការការងារក៏ដូចជាការដើរហើរនៅពេលយប់ធ្វើយ៉ាងណាឱ្យមានសុវត្ថិភាព។[៩៦]

[៩៦] គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang ដកស្រង់នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០ មានផែនការអភិវឌ្ឍន៍ច្បាស់លាស់ ក៏ដូចជាការរៀបចំទៅតាមប្លង់គោលដែលបានដាក់ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បច្ចុប្បន្ននេះក្រុងបាត់ដំបងកំពុងតែខិតខំប្រឹងប្រែងក្នុងការកែប្រែ និងផ្លាស់ប្តូរទៅជាមុខមាត់ថ្មី គឺជាកត្តាមួយយ៉ាងសំខាន់ ក្នុងការកំណត់ទិសដៅអភិវឌ្ឍន៍ក្នុងគម្រោងនៃការអនុវត្តទីក្រុងបាត់ដំបងឱ្យមានភាពជឿនលឿននិងមានសណ្តាប់ធ្នាប់របៀបរៀបរយ។ ជាពិសេសក្រុងបាត់ដំបងបច្ចុប្បន្នកំពុងតែមានការអភិវឌ្ឍតំណាលគ្នានៃការកែប្រែទៅជាទីក្រុងវៃឆ្លាត និងការតម្រង់ទិសតាមផែនការចក្ខុវិស័យឆ្នាំ២០៣០ ក្នុងទិសដៅនៃគោលការណ៍អភិវឌ្ឍន៍តាមវិស័យសំខាន់ៗជាច្រើនទៀតដែលកំពុងអនុវត្តដាក់ដំណើរការនៅក្នុងក្រុងបាត់ដំបង។ ការអភិវឌ្ឍនៃផែនការរបស់ក្រុងបាត់ដំបងនេះផ្ទាល់បន្ថែមទៅលើវិស័យ ឧស្សាហកម្ម ប្រព័ន្ធដឹកជញ្ជូន ការកែតម្រូវលំនៅដ្ឋានផ្លូវសម្រាប់ការធ្វើដំណើរដូចជា ផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាសដែលជាការអភិវឌ្ឍសំខាន់នៃការចូលរួមជំរុញតាមវិស័យមាន កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សេដ្ឋកិច្ច សាលារៀន មន្ទីរពេទ្យ តាមវិស័យផ្សេងទៀតដែលឱ្យមានភាពល្អប្រសើរឡើងបន្ថែមទៀត។

ម៉្យាងវិញទៀតតាមរយៈការខិតខំប្រឹងប្រែងក្នុងការអនុវត្តការងាររបស់អភិបាលខេត្ត និងអភិបាលក្រុងមន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងការសហការគ្នាក្នុងការអនុវត្តការងារកន្លងមកដើម្បីបម្រើទៅដល់ផលប្រយោជន៍របស់ប្រជាជន ការពារសុវត្ថិភាព ការរៀបចំនៅសណ្តាប់ធ្នាប់សន្តិសុខ និងថែរក្សាតំបន់អភិរក្សក៏ដូចជាតំបន់ធម្មជាតិទេសចរណ៍ឱ្យមានរបៀបរៀបរយ និងប្រកបសុខសុវត្ថិភាព។ ទោះបីជាមានការរីកចម្រើន និងការខិតខំប្រឹងប្រែងអនុវត្តគម្រោងលើការរៀបចំសណ្តាប់ធ្នាប់សោភ័ណភាពទីក្រុង ការជួយជំរុញសេដ្ឋកិច្ច និងតំបន់ពាណិជ្ជកម្មជាពិសេសប្រព័ន្ធផ្លូវក្នុងការធ្វើដំណើររបស់ប្រជាជន រីឯការសាងសង់លំនៅដ្ឋាន និងបញ្ហាអសន្តិសុខមួយចំនួនទៀតក៏ប៉ុន្តែនៅតែមានបញ្ហាមួយចំនួនដែលជាចំនុចខ្វះខាតតាមភាពជាក់ស្តែងដែលជាបញ្ហាតាមវិស័យ។

សរុបមកផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០ គឺជាផ្នែកមួយក្នុងការយល់ដឹងនៃការអភិវឌ្ឍថ្មីៗ ការស្វែងយល់ ការសង្កេត ការតាមដានដែលជាមូលដ្ឋានគ្រឹះសំខាន់ពីព្រោះផែនការអភិវឌ្ឍន៍ក្រុងបាត់ដំបងឆ្នាំ២០២០-២០៣០ នេះជាការចូលរួមបង្ហាញនៃការរីកចម្រើនយ៉ាងខ្លាំងក្លាសម្រាប់ក្រុងបាត់ដំបងដែលប្រកបដោយប្រសិទ្ធភាព ដោយសារតែផែនការនេះក៏សំដៅដល់ការរៀបចំ និងអភិវឌ្ឍន៍ក្រុងបាត់ដំបងដែលជាប៉ូលបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ និងទេសចរណ៍ពិភពលោក។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសង្កេតរបស់នាងខ្ញុំទាំងពីរនាក់ក្នុងការចូលរួមពិនិត្យមើលលើស្ថានភាពជាក់ស្តែងក្នុងក្រុងបាត់ដំបងបានឃើញថា ក្រុងបាត់ដំបងកំពុងតែមានការកែប្រែជាខ្លាំងក្នុងដំណើរការអភិវឌ្ឍទៅតាមផែនការចក្ខុវិស័យ២០៣០ និងការអភិវឌ្ឍជាទីក្រុងវៃឆ្លាតនៅពេលខាងមុខ ដោយក្នុងនោះរួមមានការអភិវឌ្ឍប្រព័ន្ធផ្លូវសាធារណៈ ការធ្វើប្រព័ន្ធលូ ការជួសជុលហេដ្ឋារចនាសម្ព័ន្ធមួយចំនួនធំក្នុងក្រុងបាត់ដំបង ប៉ុន្តែនៅតែបញ្ហាមួយចំនួនទៀតដែលនាំឱ្យមានភាពយឺតយ៉ាវនៅក្នុងការរៀបចំកន្លែងលក់ដូររបស់ប្រជាជនតាមដងស្ទឹងសង្កែនៅមានភាពរញ៉េរញ៉ៃនៅឡើយ។

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ នាងខ្ញុំទាំងពីរនាក់សូមមានជាមតិសំណូមពរមួយចំនួនដូចខាងក្រោម៖

- សំណូមពរដល់ថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ច ជួយពន្លឿនការអភិវឌ្ឍនៃការកសាងផ្លូវធ្វើដំណើរក្នុងក្រុង និងតាមសង្កាត់នីមួយៗឱ្យបានឆាប់រហ័ស ការពង្រឹងលើការយកចិត្តទុកដាក់ថែទាំផ្លូវធ្វើដំណើរមួយចំនួនដែលរងការខូចខាត ដើម្បីជួយសម្រួលដល់ការធ្វើដំណើរក៏ដូចជាផ្តល់ភាពងាយស្រួលជូនប្រជាជន។
- សំណូមពរដល់ថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ច ក្នុងការជួយត្រួតពិនិត្យទៅលើប្រព័ន្ធលូតាមបណ្តាក្រុង តាមសង្កាត់នៅមានការកកស្ទះលិចទឹកតាមចិញ្ចើមផ្លូវមួយចំនួន ដូច្នោះសំណូមពរឱ្យថ្នាក់ដឹកនាំជួយចាត់វិធានការរៀបចំប្រព័ន្ធលូក្រោមដីបន្ថែម ដើម្បីជួយសម្រួលដល់ប្រជាជន។
- សំណូមពរដល់ថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ច មេត្តាស្វែងរកវិធានការដែលមាន ប្រសិទ្ធភាពខ្ពស់ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពដូចជា ការរៀបចំសោភ័ណភាព ការទប់ស្កាត់នូវការប្រើប្រាស់ចំណីផ្លូវសាធារណៈសម្រាប់អាជីវកម្មរបស់ខ្លួនដែលប៉ះពាល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- សំណូមពរដល់ថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ច ជួយពង្រឹងលើការថែរក្សាអនាម័យ ការរៀបចំធុងសំរាមឱ្យមានរបៀបរៀបរយ ការចូលរួមផ្សព្វផ្សាយការថែរក្សាបរិស្ថាន ជៀសវាងការបោះចោលសំរាមផ្តេសផ្តាសនាំឱ្យបាត់បង់សោភ័ណភាព។
- សំណូមពរដល់ថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ច ឆាប់ពន្លឿនការសាងសង់ទីក្រុងបាត់ដំបងទៅជាទីក្រុងវៃឆ្លាតក្នុងគោលបំណងទាក់ទាញការវិនិយោគពីសហគ្រាសធំៗ ក៏ដូចជាទេសចរណ៍មកលេងទីក្រុងបាត់ដំបងកាន់តែច្រើន។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់, លេខ០៤/នស/៩៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤
- អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, លេខ១៨២អនក្រ.បក, ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩
- អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង (ផែនការរៀបចំដែនដីខេត្តបាត់ដំបង), លេខ៨០អនក្រ.បក, ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨
- អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- សេចក្តីប្រកាសព័ត៌មានលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តបាត់ដំបង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣
- ប្រកាសស្តីពីតួនាទីភារកិច្ច របៀបរបបគ្រប់គ្រងការងាររបស់ក្រសួងមហាផ្ទៃ, លេខ៣៤៨, ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០
- សេចក្តីណែនាំស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក, លេខ០៤៧សណក, ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២
- សេចក្តីណែនាំស្តីពីការរៀបចំតាំងស្លាកយីហោ និងការប្រើប្រាស់ដីចំណីផ្លូវ នៅក្នុងតំបន់អភិរក្ស និងជុំវិញតំបន់អភិរក្សក្រុងបាត់ដំបង ខេត្តបាត់ដំបង, លេខ០០៨/២២សណន
- សេចក្តីណែនាំពីបច្ចេកទេសស្តីពីការរៀបចំក្រុង និងកសាងផែនការអភិវឌ្ឍន៍ក្រុង, លេខ៨២ផក, ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧
- សេចក្តីសម្រេច យន្តការ និងនីតិវិធីនៃការអនុវត្តកម្មវិធីឧបត្ថម្ភប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា, លេខ២០ប្រកព, ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២
- អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ស្តីពី «ភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តបាត់ដំបង», លេខ០២៦/២៣អអរ, ឆ្នាំ២០១៨-២០២២

- សេចក្តីជូនដំណឹងស្តីពីការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងការរៀបចំដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយ រងហានិភ័យ ដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា, លេខ៤៨អនក្រ.បក, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០
- ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោយជាតិ នៅក្នុងក្រុងបាត់ដំបង, ចុះខែវិច្ឆិកា ឆ្នាំ២០១៦
- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២
- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២១
- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២០
- របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ដែលសម្រេចបានរយៈពេល ៥ឆ្នាំ ២០១៨-២០២២ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត
- សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២២-២០២៣
- រាជរដ្ឋាភិបាលកម្ពុជា (យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤របស់រដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា)។

## ៣. ឯកសារយោងជាគេហទំព័រទេបសាយ

- គេហទំព័រ https://nubb.edu.kh/
- គេហទំព័រ https://www.battambang.gov.kh/
- គេហទំព័រ https://propertyarea.asia/archives/59915
- គេហទំព័រ https://www.mlmupc.gov.kh
- គេហទំព័រ https://dap-news.com/national/2020/05/13/54298/
- គេហទំព័រ https://battambanglife.wordpress.com/
- គេហទំព័រ https://hunnghivietnamcampuchia.thoidai.com.vn/dtail-article-11917.html
- គេហទំព័រ https://www.battambang.gov.kh/topics/attraction
- គេហទំព័រ https://www.kampucheathmey.com/local-news/452620
- គេហទំព័រ https://thmeythmey25.com/detail/93689

- គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang
- គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang
- គេហទំព័រ https://www.mpwt.gov.kh/kh/contact-us/battambang
- គេហទំព័រ https://www.battambang.gov.kh/detail/organization/
- គេហទំព័រ http://mosvy.gov.kh
- គេហទំព័រ https://www.battambang.gov.kh
- គេហទំព័រ https://www.interior.gov.kh/report/detail/11231

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី២៖** ច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, លេខ១៨២អនក្រ.បក, ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង (ផែនការរៀបចំដែនដីខេត្តបាត់ដំបង), លេខ៨០អនក្រ.បក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី៦៖** របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលក្រុង ប្រចាំឆ្នាំ២០២២

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីខេត្តបាត់ដំបង និងរដ្ឋបាលក្រុងបាត់ដំបង

**ឧបសម្ព័ន្ធទី២៖** តំបន់សេដ្ឋកិច្ច

**ឧបសម្ព័ន្ធទី៣៖** តំបន់ទេសចរណ៍

**ឧបសម្ព័ន្ធទី៤៖** ផែនទីអភិវឌ្ឍន៍ខេត្តបាត់ដំបង២០៣០

**ឧបសម្ព័ន្ធទី៥៖** ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង២០៣០

**ឧបសម្ព័ន្ធទី៦៖** សមិទ្ធផលនៃវឌ្ឍនភាពការងារ

**ឧបសម្ព័ន្ធទី៧៖** គម្រោងការអភិវឌ្ឍជាទីក្រុងវៃឆ្លាត

**ឧបសម្ព័ន្ធទី៨៖** ការអភិវឌ្ឍប្រព័ន្ធផ្លូវ និងសកម្មភាពដំណើរការការងារ

# ផ្នែកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. រដ្ឋបាលក្រុង

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **ក). ការងាររដ្ឋបាល** | | |
| ១ | របៀបរបបការងារ ការចរាចរលិខិតស្នាម និង ទំនាក់ទំនងការងារមិនទាន់ឆ្លើយតបនិងតម្រូវការរវាងអង្គភាពពាក់ព័ន្ធ និង ប្រជាពលរដ្ឋ | មន្ត្រីគ្រប់លំដាប់ថ្នាក់ត្រូវដាក់ចិត្តដាក់កាយ បង្កើនឆន្ទៈយក ចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការបំពេញការងារនិងក្នុងការទទួលខុសត្រូវរួមគ្នាដើម្បីកែលម្អការអនុវត្តមុខងារ ភារកិច្ច |
| ២ | ការងារប្រមូលទទួលចែករំលែក ផ្សព្វផ្សាយ និង គ្រប់គ្រងព័ត៌មាននៅមានកំរិត មិនទាន់ស៊ីជម្រៅ និងមិនទាន់ចេះប្រើប្រាស់ព័ត៌មាន | បើកវគ្គពង្រឹងបន្ថែមលើការងារគ្រប់គ្រងព័ត៌មាន រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបណ្តាញនិងផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយ ច្បាស់លាស់ពិតប្រាកដ ។ |
| ៣ | ខ្វះបន្ទប់សម្រាប់ការិយាល័យនីមួយៗ ធ្វើការ | សុំសាងសង់អគារ បន្ទប់ធ្វើការបន្ថែម |
| **ខ). ការងារផែនការ និងការគាំទ្រឃុំ សង្កាត់** | | |
| ១ | ខ្វះសំភារៈ បរិក្ខា និង សង្ហារឹម | ស្នើសុំសំភារៈបន្ថែម(កុំព្យូទ័រ.ម៉ាស៊ីនព្រីន) |
| **គ). ការគ្រប់គ្រងធនធានមនុស្ស** | | |
| ១ | ខ្វះមន្ត្រីនៅតាមបណ្តាការិយាល័យ បរិមាណការងារច្រើន | សុំមន្ត្រីជំនាញបន្ថែម ដើម្បីជានាឲ្យបានសមស្របតាមទំហំនៃការងារ |
| ២ | សមត្ថភាពមន្ត្រីនៅមានកំរិតមន្ត្រីថ្មីខ្វះបទពិសោធន៍ | សុំបើកវគ្គបណ្តុះបណ្តាលតាមជំនាញ ( ច្បាប់ហិរញ្ញវត្ថុ រដ្ឋបាល ) |
| **ឃ). ការងារនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន** | | |
| ១ | - ទទួលប្រឹក្សាយោបល់ប្រជាពលរដ្ឋផ្នែកច្បាប់<br>-ទទួលសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ | ខិតខំរកវិធីធ្វើការសម្របសម្រួលវិវាទប្រកបដោយប្រសិទ្ធិភាព។ |
| **ង). ការងារត្រួតពិនិត្យផ្ទៃក្នុង** | | |
| ១ | - បទពិសោធន៍អំពីការត្រួតពិនិត្យផ្ទៃក្នុង នៅមានកម្រិត | សុំឲ្យមានវគ្គបណ្តុះបណ្តាល |
| **ច). ការងារហិរញ្ញវត្ថុ** | | |
| ១ | ការងារគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា ក្រុង សង្កាត់ អនុវត្តតាមការណែនាំថ្មី | សុំឲ្យមានការគាំទ្រសម្របសម្រួល នឹងណែនាំពាក់ព័ន្ធផ្នែកបច្ចេកទេស |
| **ឆ). ការងារច្រកចេញចូលតែមួយ** | | |
| ១ | បន្ទប់ធ្វើការងារចង្អៀតពិបាកទុកឯកសារ | សុំជួយរកបន្ទប់រៀបចំឯកសារ |
| ២ | ខ្វះមន្ត្រីជួរមុខ | ស្នើសុំដោះស្រាយបន្ថែមមន្ត្រី |
| ៣ | សម្ភារៈ និងបរិក្ខាប្រើប្រាស់កាន់តែចាស់ៗ (កុំព្យូទ័រ ម៉ាស៊ីនព្រីន កៅអីមន្ត្រី និងកៅអីទទួលភ្ញៀវ | សុំសម្ភារៈប្រើប្រាស់ថ្មីបន្ថែម |
| ៤ | ការបម្រើសេវាការងារអត្រានុកូលដ្ឋាន និង ការងារនីត្យានុកូលកម្មមានការយឺតយ៉ាវ (ដោយសារការស្នើសុំរបស់អតិថិជនមានចំនួនច្រើន និងខ្វះក្រដាសអត្រានុកូលដ្ឋាន | សំណើរដោះស្រាយបន្ថែមមន្ត្រីអត្រានុកូលដ្ឋាន នីត្យានុកូកម្ម និងក្រដាសអត្រានុកូលដ្ឋានឲ្យបានគ្រប់ចំនួនតាមការស្នើសុំ |
| **ជ.ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍** | | |
| ១ | កសិករមិនទាន់យល់ច្បាស់ពីពូជស្រូវទាំង ១០ មុខ | បើកវគ្គបណ្តុះបណ្តាលស្តីពីពូជស្រូវទាំង១០និងបង្ហាញ ពីពូជស្រូវមានគុណភាព |

| | | |
|---|---|---|
| ២ | បច្ចេកទេសកសិកម្មរបស់កសិករនៅមានកម្រិត | ធ្វើការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មី ៗ ដល់ មន្ត្រីកសិកម្ម និងកសិករ |
| ៣ | កសិករកែច្នៃផលិតផលកសិកម្មមិនទាន់បានត្រឹមត្រូវ តាមស្តង់ដារ | បណ្តុះបណ្តាលបច្ចេកទេសក្រោយពេលប្រមូលផល (ការទុកដាក់ ការញែក ការរក្សាទុកនៅក្នុងឃ្លាំង ការដឹកជញ្ជូន ) តាមកម្រិតស្តង់ដារ ជាតិ អន្តរជាតិ |
| ៤ | កង្វះព័ត៌មានទីផ្សារកសិផល កសិកម្ម | ពង្រីកការផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម ក្នុង ស្រុក |
| ៥ | កសិករនៅកង្វះខាតទុនក្នុងការធ្វើផលិតកម្ម កសិកម្ម កែច្នៃ | ជួយស្វែងរកវិនិយោគទុន អង្គការដៃគូផ្នែកកសិកម្មឲ្យដល់មូលដ្ឋាន កសិករការងារបច្ចេកទេស ពីពិធកម្មផ្នែកកសិកម្ម |
| ៦ | ចំនួនវ៉ាក់សាំង និងថ្នាំព្យាបាលសត្វពុំគ្រប់គ្រាន់ | ស្នើសុំបង្កើនបន្ថែម |
| ៧ | ម្ចាស់សិប្បកម្មមួយចំនួនពុំទាន់អនុវត្តទាំងស្រុងតាមការណែនាំនិងពុំទាន់យល់ ច្បាស់ពីច្បាប់គ្រប់គ្រងរោងចក្រ និងសិប្បកម្ម | ធ្វើការចុះណែនាំ និងធ្វើអធិការកិច្ច ជាពិសេសសិប្បកម្ម នំចំណីម្ហូបអាហារ និងជម្រុញឲ្យមកសុំច្បាប់បន្ត សុពលភាព |
| ៨ | ការផ្តល់ទិន្នន័យស្ថិតិភ្ញៀវជាតិ និងអន្តរជាតិពីបណ្តាផ្ទះសំណាក់មួយចំនួនពុំទាន់សុក្រិត | ចុះធ្វើការណែនាំតាមផ្ទះសំណាក់ សូមផ្តល់ទិន្នន័យស្ថិតិ ភ្ញៀវ ចូលមកសំណាក់ពិតប្រាកដច្បាស់លាស់ |
| ៩ | គុណភាព សេវាកម្ម ក្នុងមូលដ្ឋានអាជីវកម្មខ្លះនៅ មានកម្រិតនៅឡើយ | ចុះធ្វើការអប់រំណែនាំ និងមានការបណ្តុះបណ្តាល |
| ១០ | អាជីវកម្ម សេវាកម្ម វិស័យទេសចរណ៍មួយចំនួនពុំមានការអនុញ្ញាត និងខ្លះទៀតហួសសុពលភាពមានការយឺតយ៉ាវក្នុងការបន្តច្បាប់អនុញ្ញាត | ចុះធ្វើការជូនដំណឹង ជម្រុញឲ្យមកសុំច្បាប់ និងបន្តច្បាប់អនុញ្ញាតឬ អនុវត្តការផាកពិន័យតាមច្បាប់ទេសចរណ៍ |
| **ឈ.ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម** | | |
| | | |
| **ញ. ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាល** | | |
| ១ | ការយល់ដឹងពីច្បាប់ពាក់ព័ន្ធវិស័យដីធ្លី និង សំណង់ របស់ប្រជាពលរដ្ឋមូលដ្ឋាននៅមានកម្រិត | បន្តផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងវិស័យដីធ្លី និង សំណង់ |
| ២ | បាតុភាពទំនាស់ដីធ្លីនៅមានបន្តបន្ទាប់ | បន្តផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធវិស័យដីធ្លី ជាពិសេសច្បាប់ភូមិបាល និង សារាចរ លេខ ០៣ |
| ៣ | នៅមានការជួសជុល និងសាងសង់ដោយគ្មានច្បាប់ អនុញ្ញាតខុសគម្រោងប្លង់ ខុសរចនាបទសំណង់ និង មានការបោះទីតាំងបណ្តោះអាសន្ននៅលើដីចំណីផ្លូវ | បន្តផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធវិស័យសំណង់ និងរៀបចំក្រុមការងារចំនាញរដ្ឋបាលក្រុង ជាមួយមន្ទីរ ដ.ន.ស និង មានវិធានការទប់ស្កាត់ទាន់ពេលវេលា តាមវិធានការអប់រំណែនាំ និងអនុវត្តវិធានការច្បាប់ |
| ៤ | លិខិតផ្អាកការសាងសង់ ការជួសជុលពុំសូវមានប្រសិទ្ធភាព | ស្នើសុំមានវិធានការតាមច្បាប់ |
| ៥ | គ្មានពេលវេលាគ្រប់គ្រាន់ចុះពិនិត្យសំណង់មានច្បាប់ខុសច្បាប់មានប្រជាពលរដ្ឋមួយចំនួនមិនគោរពច្បាប់ | ផ្សព្វផ្សាយច្បាប់សំណង់ មានវិធានការផ្លូវច្បាប់ចំពោះអ្នកសាងសង់ឥតច្បាប់ សំណង់សង់លើដីសាធារណៈរបស់រដ្ឋ |
| ៦ | សាងសង់សំណង់ខុសច្បាប់គឺឆ្លៀតឱកាសសាងសង់នៅពេលមន្ត្រីឈប់សម្រាកពីការងារ | ពង្រឹងអាជ្ញាធរមូលដ្ឋាន ភូមិ សង្កាត់គួរផ្តល់ព័ត៌មាន និងជួយទប់ស្កាត់ |
| ៧ | ទីតាំងសីសម្បទានសង្គមកិច្ចដែលធ្វើអត្តសញ្ញាណកម្មរួច នៅមានជនខិលខូចចូលទន្ទ្រានយកដី | ស្នើសុំឲ្យមានការផ្សព្វផ្សាយ និងការពារ (មូលដ្ឋានភូមិ សង្កាត់ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង) |

| | | |
|---|---|---|
| ៨ | ការផ្តល់សេវាលើការផ្ទេរកម្មសិទ្ធដីធ្លីមិនទាន់សំណូមពររបស់ប្រជាពលរដ្ឋដោយមូលហេតុ ការស្នើសុំសេវាច្រើន និងប្រធានអនុប្រធានការិយាល័យបំពេញបេសកម្មការងារផ្សេងៗច្រើន | សំណូមពរៈ សុំតែងតាំងអនុប្រធានការិយាល័យបំពេញបន្ថែមជំនួសអនុប្រធានការិយាល័យដែលបានចូលនិវត្តន៍ |
| ៩ | ខ្វះខាតសម្ភារៈបរិក្ខាការិយាល័យ និងសម្ភារៈបច្ចេកទេស (ឧបករណ៍វាស់វែងទំនើប) | ស្នើសុំឧបករណ៍វាស់វែងទំនើប dgps ខ្សែម៉ែត្របង្គោលតំរង់ |
| ១០ | ការរំលោភប្រើប្រាស់ដីសាធារណៈរបស់រដ្ឋដូចជាដីចំណីផ្លូវ ប្រឡាយ ស្ទឹង សាងសង់តូប និងសង់ឃ្លូបដែកប្រើប្រាស់សម្រាប់លក់ដូរ ដាក់ស្លែងប្លុកផ្សារបឹងឈូក និង ១៣មករា ។ល។ | សំណូមពរលោកប្រធានមន្ទីរដ.ន.ស.ស និងរដ្ឋបាលក្រុង មានវិធានការតាមផ្លូវច្បាប់ទប់ស្កាត់លើជនរំលោភកាន់កាប់ដីរដ្ឋខុសច្បាប់ ករណីសាងសង់គ្រប់ប្រភេទលើចំណីផ្លូវ ចំណីប្រឡាយ ចំណីស្ទឹង អូរដែលធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ការកកស្ទះចរាចរបំពុលបរិស្ថានខូចសោភ័ណ្ឌភាពដល់ការអភិវឌ្ឍក្រុង។ |
| ១១ | ការសាងសង់សំណង់រឹងមាំនៅក្នុងសំណង់បណ្តោះអាសន្ននៅតែបន្តមិនអាចហាមឃាត់បាន។ | រដ្ឋបាលក្រុង មន្ទីរដ.ន.ស.ស មានវិធានការគ្មានច្បាប់ និងបន្តជម្រុញការផ្សព្វផ្សាយ និងរឹតបន្តឹងការអនុវត្តច្បាប់ |
| **ង. ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ** | | |
| ១ | ខ្វះសម្ភារៈបច្ចេកទេសសម្រាប់បម្រើការងារ | ស្នើសុំសម្ភារៈដូចជា ខ្សែម៉ែត្រ ឧបករណ៍វាស់ស្ទង់ |
| ២ | ប្រព័ន្ធលូរំដោះទឹកចាស់ក្នុងក្រុងមួយចំនួនស្ទះ មិនអាចដំណើរការបាន | ស្នើសុំជួសជុល កែលម្អប្រព័ន្ធ លូរំដោះទឹក |
| ៣ | បន្ទប់លូក្នុងក្រុងតូច ពុំគ្រប់គ្រាន់មានសភាពចាស់ទ្រុឌទ្រោម ងាយមានការកកស្ទះ | ស្នើរៀបចំបន្ទប់លូបន្ថែម និងជួសជុលកែលម្អបន្ទប់លូចាស់ |
| ៤ | ខ្វះសម្ភារៈមធ្យោបាយក្នុងការបំរើការងារ | ស្នើសុំសម្ភារៈ និង មធ្យោបាយ ដើម្បីគ្រប់គ្រងជួសជុលថែទាំទ្រព្យសម្បត្តិសាធារណៈ |
| ៥ | នៅមានប្រជាពលរដ្ឋមួយចំនួនពុំសូវចាប់អារម្មណ៍ ក្នុងការ គ្រប់គ្រងកាកសំណល់ អនាម័យ បរិស្ថាន | សុំមានការគាំទ្រធ្វើការអប់រំផ្សព្វផ្សាយជាសាធារណៈលើទីតាំងដាក់ស្លែងពីការគ្រប់គ្រងកាកសំណល់ អនាម័យ បរិស្ថាន បង្កើនធុងសំរាម និង ការគ្រប់គ្រង |
| ៦ | កិច្ចសហការជាមួយក្រុមហ៊ុន ស៊ិន ទ្រី មានភាពលំបាក | សូមអោយមានការទទួលខុសត្រូវ ច្បាស់លាស់ របស់ ក្រុមហ៊ុនស៊ិនទ្រី ជាមួយសាលាក្រុង ដោយមានផែនការជានា ក្នុងការអនុវត្តប្រមូលកាកសំណល់ |
| ៧ | មានកញ្ចប់ថវិកាតិចតួចមិនគ្រប់គ្រាន់សម្រាប់ការថែទាំ ជួសជុលសួនច្បារ ភ្លើងបំភ្លឺ សាធារណៈ និង ដើមផ្កា | សុំបង្កើនកញ្ចប់ថវិកាសម្រាប់ធ្វើការថែទាំជួសជុល សួនច្បារ ភ្លើង បំភ្លឺ សាធារណៈ និង ដើមផ្កា មធ្យោបាយសម្រាប់ស្រោចស្រព |

## ផ្នែកទី៤
## ទិសដៅការងារត្រីមាសបន្ទាប់

### ៤.១. រដ្ឋបាលក្រុង

| ល.រ | សកម្មភាពអាទិភាព | ពេលវេលា | | |
|---|---|---|---|---|
| | | ខែមករា | ខែកុម្ភៈ | ខែមីនា |
| **ក. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការ** | | | | |
| ១ | សម្របសម្រួលរាល់បញ្ហាប្រឈម នៃកិច្ចការនានា ដែលស្ថិតក្នុងដែនសមត្ថកិច្ច របស់ក្រុមប្រឹក្សាក្រុង | ✓ | ✓ | ✓ |
| ២ | ផ្តល់អនុសាសន៍ និងការណែនាំដល់គណៈអភិបាលក្រុងអំពីមុខការដែលត្រូវ អនុវត្ត តួនាទីដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់ មូលដ្ឋាន | ✓ | ✓ | ✓ |
| ៣ | ជម្រុញការអនុវត្តភារកិច្ចរបស់រដ្ឋបាលក្រុងដោយផ្តោតលើគោលការណ៍ណែនាំ លិខិតបទដ្ឋាន និងឯកសារគតិយុត្តិផ្សេងៗ របស់គណៈកម្មការជាតិសម្រាប់ការ អភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យថ្នាក់រដ្ឋបាលក្រោមជាតិ | ✓ | ✓ | ✓ |
| ៤ | ប្រជុំក្រុមប្រឹក្សាប្រចាំខែ | ✓ | ✓ | ✓ |
| ៥ | គ.ក.ស.កចូលរួមប្រជុំជាមួយក្រុមប្រឹក្សាប្រចាំខែ | ✓ | ✓ | ✓ |
| ៦ | គ.ក.ស.ករៀបចំកិច្ចប្រជុំប្រចាំខែ | ✓ | ✓ | ✓ |
| ៧ | គ.ក.ស.កចូលរួមប្រជុំប្រចាំខែរបស់ គ.ក.ន.ក សង្កាត់និងគាំទ្រសេវាសង្គម | ✓ | ✓ | ✓ |
| ៨ | ទទួលការជួបជាមួយប្រជាពលរដ្ឋមកទំនាក់ទំនងការងារនៅថ្ងៃ ច័ន្ទ រៀងរាល់ថ្ងៃធ្វើការ | ✓ | ✓ | ✓ |
| **ខ. ការងារគណៈអភិបាល** | | | | |
| ១ | ពង្រឹងការអនុវត្តតួនាទីភារកិច្ច របស់គណៈអភិបាលដោយធ្វើការពិគ្រោះក្នុងគណៈអភិបាល | ✓ | ✓ | ✓ |
| ២ | ណែនាំដល់បណ្តាការិយាល័យ អង្គភាពនានាជុំវិញក្រុង ឲ្យអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន បានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធ ឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋាន | ✓ | ✓ | ✓ |
| ៣ | ពង្រឹងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ ការយល់ដឹងការអនុវត្តច្បាប់ ព្រមទាំងធានាឲ្យមានការការពារ និងគោរពសិទ្ធមនុស្ស និងបន្តការជម្រុញការអនុវត្តគោលនយោបាយភូមិ.ឃុំមានសុវត្ថិភាព | ✓ | ✓ | ✓ |
| ៤ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ✓ | ✓ | ✓ |
| ៥ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាស)របស់គណៈអភិបាល | ✓ | ✓ | ✓ |
| ៦ | ចូលរួម សិក្ខាសាលា កម្មវិធី  កិច្ចប្រជុំនានា | ✓ | ✓ | ✓ |
| ៧ | ចូលរួមសកម្មភាពផ្សេងៗ | ✓ | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| **គ.ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ** | | | | |
| ១ | គ្រប់គ្រងនិងចរាចរលិខិតរដ្ឋបាល | ✓ | ✓ | ✓ |
| ២ | រៀបចំកិច្ចប្រជុំនានា | ✓ | ✓ | ✓ |
| ៣ | អនុវត្តផែនការហិរញ្ញវត្ថុឆ្នាំ២០២៣ | ✓ | ✓ | ✓ |
| ៤ | គាំទ្រអនុវត្តថវិកាសង្កាត់ឆ្នាំ២០២៣ | ✓ | ✓ | ✓ |
| **ឃ. ការិយាល័យផែនការ និងគាំទ្រសង្កាត់** | | | | |
| ១ | តាមដានការអនុវត្តគម្រោងមូលនិធិសង្កាត់ | ✓ | ✓ | ✓ |
| ២ | គាំទ្រការធ្វើរបាយការណ៍ របស់សង្កាត់ | ✓ | ✓ | ✓ |
| ៣ | រៀបចំកម្មវិធី វិនិយោគបីឆ្នាំរំកិលរបស់ក្រុង ( ២០២៣-២០២៥) | ✓ | ✓ | ✓ |
| ៤ | ជម្រុញការអនុវត្តផែនការវិនិយោគសង្កាត់ឆ្នាំ ២០២៣ | ✓ | ✓ | ✓ |
| **ង. ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទ** | | | | |
| ១ | ផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ |
| ២ | សំរុះសំរួលទំនាស់ផ្នែករដ្ឋបាល និងក្រៅប្រព័ន្ធតុលាការ | ✓ | ✓ | ✓ |
| ៣ | អនុវត្តមុខងារ ភារកិច្ចនានាដែលបានប្រគល់ជូន និងការងារស្នូលរបស់ការិយាល័យ | ✓ | ✓ | ✓ |
| **ច. ការិយាល័យច្រកចេញចូលតែមួយ** | | | | |
| ១ | បន្តផ្តល់សេវាតាមប្រតិភូកម្មអំណាចដែលមានស្រាប់និងត្រួតពិនិត្យប្រសិទ្ធិភាព សេវាដែលបានផ្តល់ | ✓ | ✓ | ✓ |
| ២ | ការគ្រប់គ្រង និងផ្តល់សេវាតាមកម្មវិធីព័ត៌មានវិទ្យា | ✓ | ✓ | ✓ |
| ៣ | ពង្រីកសេវាកម្មឬករណីមានប្រតិភូកម្មអំណាចបន្ថែមទៀត | ✓ | ✓ | ✓ |
| **ឆ. អង្គភាពលទ្ធកម្ម** | | | | |
| ១ | រៀបចំឯកសារលទ្ធកម្មលើកញ្ចប់ថវិកាក្រុង | ✓ | ✓ | ✓ |
| ២ | រៀបចំកិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្មក្រុងបាត់ដំបង ដើម្បីវាយតម្លៃប្រគល់កិច្ចសន្យា ដល់ក្រុមហ៊ុន ដែលបានចូលរួមដាក់សំណើពិគ្រោះថ្លៃទៅតាមនីតិវិធីបានកំណត់ | ✓ | ✓ | ✓ |
| **ជ. ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៏សហគមន៍** | | | | |
| ១ | ជម្រុញការដាំដុះដំណាំបង្កបង្កើនផល ស្រូវរដូវវស្សា | ✓ | ✓ | ✓ |
| ២ | កិច្ចសហការតាមបណ្តាអង្គការ ដែលពាក់ព័ន្ធ និង វិស័យ កសិកម្ម | ✓ | ✓ | ✓ |
| ៣ | ចុះអន្តរាគមន៍តាមបណ្តាសង្កាត់ ដែលមានដំណាំស្រូវ ដំណាំបន្លែ ដំណាំ ឧស្សាហកម្ម ដែលមានបញ្ហាជម្ងឺ និង សត្វល្អិតបំផ្លាញ | ✓ | ✓ | ✓ |
| ៤ | ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ និង អ្នកផ្សព្វផ្សាយ | ✓ | ✓ | ✓ |
| ៥ | ចុះស្រង់ទីតាំងសិប្បកម្ម និងជម្រុញសិប្បកម្ម ដែលពុំទាន់មានច្បាប់ឲ្យមកសុំច្បាប់ | ✓ | ✓ | ✓ |
| ៦ | បន្តការងាររៀបចំទីក្រុងស្អាតតាមសូចនាករគោល របស់លេខាធិការដ្ឋានគណៈ កម្មាធិការ ជាតិវាយតម្លៃទីក្រុងស្អាត | ✓ | ✓ | ✓ |
| ៧ | បន្តរៀបចំបច្ចុប្បន្នភាពគេហទំព័រក្រុងដោយសហការជាមួយ អាជ្ញាធរ មន្ទីរ អង្គភាព ការិយាល័យនានា | ✓ | ✓ | ✓ |
| **ឈ. ការិយាល័យ អប់រំ យុវជន និងកីឡា** | | | | |
| ១ | សម្របសម្រួលអន្តរាគមន៍ សហប្រតិបត្តិការជាមួយអង្គការដែល មានកម្មវិធីលើវិស័យអប់រំ | ✓ | ✓ | ✓ |
| ២ | អភិវឌ្ឍន៍កម្មវិធីសាលាមេត្រីគ្រប់កម្រង | ✓ | ✓ | ✓ |
| ៣ | ប្រមូលព័ត៌មានអប់រំពីគ្រប់សាលារៀន | ✓ | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| ៤ | បង្កើនការចូលរៀនរបស់កុមារអាយុ ៥ ឆ្នាំ | ✓ | ✓ | ✓ |
| ៥ | ជួយជម្រុញអាណាព្យាបាលឲ្យយល់ដឹងពីតួនាទី និងភារកិច្ច ក្នុងការជម្រុញការសិក្សាកូន | ✓ | ✓ | ✓ |
| ៦ | កាត់បន្ថយអត្រាបោះបង់ការសិក្សា | ✓ | ✓ | ✓ |
| ៧ | បន្តកាត់បន្ថយអក្ខរជន និងបង្កើនកម្រិតវប្បធម៌ ដល់សិស្សបោះបង់ការសិក្សា | ✓ | ✓ | ✓ |
| **៣. ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម** | | | | |
| ១ | បង្កើនការពិនិត្យផ្ទៃពោះ | ✓ | ✓ | ✓ |
| ២ | បង្កើនអត្រាសេវាពន្យាកំណើត | ✓ | ✓ | ✓ |
| ៣ | កាត់បន្ថយការចម្លងមេរោគអេដស៍ ពីម្តាយទៅកូន ពង្រឹងការប្រឹក្សាយោបល់ | ✓ | ✓ | ✓ |
| ៤ | ពង្រឹងមណ្ឌលសុខភាពទាំង ៨ | ✓ | ✓ | ✓ |
| ៥ | បង្កើនអត្រាគ្របដណ្តប់ផ្តល់ថ្នាំបង្ការសព្វគ្រប់ ដល់កុមារអាយុតិចជាង១ឆ្នាំ | ✓ | ✓ | ✓ |
| ៦ | លើកកម្ពស់សេវាសុខាភិបាលពង្រឹងគុណភាពសេវាឯកជន | ✓ | ✓ | ✓ |
| ៧ | ទប់ស្កាត់ការជួញដូរមនុស្សនិងអប់រំអំពើហឹង្សាក្នុងគ្រួសារ | ✓ | ✓ | ✓ |
| ៨ | អន្តរាគមន៍ជួយគ្រួសារងាយរងគ្រោះនិងគ្រោះមហន្តរាយ | ✓ | ✓ | ✓ |
| ៩ | រកដំណោះស្រាយធ្វើការទប់ស្កាត់ និងកាត់បន្ថយជនអនាថា កុមារអនាថា និងអ្នកសុំទាន | ✓ | ✓ | ✓ |
| ១០ | ពង្រឹងសមត្ថភាពដល់រដ្ឋបាលក្រុងដើម្បីដោះស្រាយលើករណីកុមារស្ថិតក្នុងហានិភ័យខ្ពស់ក្នុងក្រុង គាំទ្រដោយគម្រោង DAR | ✓ | ✓ | ✓ |
| ១១ | បន្តធ្វើបច្ចុប្បន្នភាពនិវត្តន៍ជន ជួយសម្រួលដល់មុខសញ្ញាបើកប្រាក់ពីប្រព័ន្ធ ធនាគារគ្រប់មុខសញ្ញា | ✓ | ✓ | ✓ |
| ១២ | លើកកម្ពស់វប្បធម៌ជាតិ ទប់ស្កាត់ការហូរចូលវប្បធម៌មិនល្អ | ✓ | ✓ | ✓ |
| ១៣ | សម្របសម្រួលអន្តរាគមន៍ក្នុងវិស័យសាសនា | ✓ | ✓ | ✓ |
| ១៤ | ចូលរួមសកម្មភាពបុណ្យទាននានា | ✓ | ✓ | ✓ |
| **ង. ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង** | | | | |
| ១ | ផ្សព្វផ្សាយផែនការប្រើប្រាស់ដីធ្លីក្រុងបាត់ដំបង | ✓ | ✓ | ✓ |
| ៣ | ពង្រឹងអនុវត្តផែនការ ចំពោះសំណង់ឥតច្បាប់ | ✓ | ✓ | ✓ |
| ៤ | អនុវត្តការងារគណៈកម្មការសុរិយោដី | ✓ | ✓ | ✓ |
| ៥ | អនុវត្តការវាស់វែងដីជូនប្រជាពលរដ្ឋលើដីអតីតគ្រោងសួនច្បារព្រៃកព្រះស្តេច | ✓ | ✓ | ✓ |
| **ឋ. ការិយាល័យសាធារណការ ដឹកជញ្ជូន បរិស្ថាន អនាម័យ សណ្តាប់ធ្នាប់សាធារណៈ** | | | | |
| ១ | សហការជាមួយរដ្ឋបាលក្រុងនិងមន្ទីរសាធារណការខេត្តលើ វិស័យសាធារណៈការ | ✓ | ✓ | ✓ |
| ២ | ជួសជុលនិងដាំដើមឈើ កាត់លម្អ ថែទាំដើមឈើតាមផ្លូវសំខាន់ៗក្នុងក្រុង | ✓ | ✓ | ✓ |
| ៣ | ការអប់រំផ្សព្វផ្សាយណែនាំដល់ប្រជាពលរដ្ឋសហគមន៍ គ្រប់ស្ថាប័ន អោយទុកដាក់ វេចខ្ចប់សំណល់អោយបានត្រឹមត្រូវ | ✓ | ✓ | ✓ |
| ៤ | តាមដាននិងត្រួតពិនិត្យការប្រមូលនិងការយកសេវាប្រមូល | ✓ | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| | សម្រាមរបស់ក្រុមហ៊ុនស៊ិនទ្រី និងក្រុមហ៊ុន លៀប លឹម | | | |
| ៥ | ធ្វើការកែលម្អជួសជុលសួនច្បារនិងភ្លើងបំភ្លឺសាធារណៈ | ✓ | ✓ | ✓ |
| ៦ | ចាត់វិធានការទប់ស្កាត់ផាកពិន័យចំពោះជនល្មើសដែលចោលសម្រាមតាម ទីសាធារណៈ | ✓ | ✓ | ✓ |
| **ឌ. ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង** | | | | |
| ១ | អនុវត្តមុខងារភារកិច្ចនានាដែលបានប្រគល់ជូន និងការងារស្នូលរបស់ការិយាល័យ | ✓ | ✓ | ✓ |
| ២ | ចូលរួមក្នុងកិច្ចប្រជុំនានារបស់រដ្ឋបាលក្រុង | ✓ | ✓ | ✓ |
| ៣ | ណែនាំ និងពង្រឹងលើការអនុវត្តវិន័យបទបង្ហាញផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គលិករដ្ឋបាលក្រុង | ✓ | ✓ | ✓ |
| ៤ | ចុះពិនិត្យ និងធ្វើកំណត់ហេតុលើការស្នើសុំសាងសង់សំណង់ និងការអភិវឌ្ឍដីក្នុងក្រុងបាត់ដំបង | ✓ | ✓ | ✓ |

## ផ្នែកទី៥
## សេចក្តីសន្និដ្ឋាន

លទ្ធផល និងសកម្មភាពការងារដែលរដ្ឋបាលក្រុងបាត់ដំបង សម្រេចបានលើគ្រប់វិស័យក្នុង ឆ្នាំ២០២២ នេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់អាស្រ័យដោយការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ការទទួលខុសត្រូវ ការចូលរួមយ៉ាងសកម្មពីបណ្តាមន្ត្រីគ្រប់បណ្តាអង្គភាព ការិយាល័យ គ្រប់ផ្នែក ជំនាញវិស័យ និងធ្វើទំនាក់ទំនងសហការល្អជាមួយបណ្តាមន្ទីរ ស្ថាប័ន សប្បុរសជន ដៃគូរអភិវឌ្ឍន៍នានា ព្រមទាំងអនុវត្តយ៉ាងខ្ជាប់ខ្ជួន ការគោរពច្បាប់ លិខិតបទដ្ឋាននានា គោរពសិទ្ធមនុស្ស គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងមានការដឹកនាំផ្ទាល់ពីឯកឧត្តមអភិបាលខេត្ត ព្រមទាំងផ្នែកតាមលក្ខណៈភូមិសាស្ត្រជាក់ស្តែងរបស់មូលដ្ឋានផងនោះ ។ ទោះបីនៅភូមិសាស្ត្រក្រុងបាត់ដំបងជួបនូវបញ្ហាប្រឈម និងស្ថានភាពរីករាលដាលជម្ងឺកូវី-១៩ មួយចំនួនក៏រដ្ឋបាលក្រុងបានពុះពារសម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់៖

- ចំពោះវិស័យកសិកម្មទោះបីឆ្នាំនេះជួបគ្រោះមហន្តរាយទឹកជំនន់ក្តីយើងបានខិតខំជម្រុញការងារបង្កបង្កើនផលដោយស្តារឡើងវិញលើដំណាំស្រូវលើសផែនការ និងបង្កើនការដាំដំណាំរួមផ្សំ ចិញ្ចឹមសត្វ បង្កើនជីវភាពប្រចាំថ្ងៃ ប្រជាពលរដ្ឋបានមួយកម្រិតថែមទៀត ។
- ផែនការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច សង្គមកិច្ចៈ យើងពិនិត្យឃើញថាមានការរីកចំរើនទៅមុខជាប្រក្រតីទៅតាមផែនការជាអាទិភាពដែលបានដាក់ចេញ ។ ក្រោមកិច្ចឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ខេត្ត មន្ទីរ សប្បុរសជន ដៃគូរអភិវឌ្ឍន៍នានា ។
- ចំពោះអនាម័យសោភ័ណ្ឌភាពក្រុង ពីមួយថ្ងៃទៅមួយថ្ងៃត្រូវបានលើកកម្ពស់ ដូចជាការរៀបចំសណ្តាប់ធ្នាប់សាធារណៈធ្វើអនាម័យបរិស្ថាន ការកែលម្អជួសជុសសាងសង់លំនៅឋាន អគាររដ្ឋ ការបំពាក់បង្គោលដាក់ភ្លើងតាមផ្លូវ ការដាក់លូរំដោះទឹក ការដឹកជញ្ជូនកាកសំណល់ចេញពីទីក្រុង ។ ល។ ធ្វើឲ្យទីប្រជុំជនក្រុងបាត់ដំបង ទទួលបានសោភ័ណភាពមួយកម្រិតទៀត ។ វិស័យសុខុមាលភាពរបស់ប្រជាពលរដ្ឋក៏មានភាពល្អប្រសើរផងដែរ ដោយសារយើងមានមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព តាមបណ្តាសង្កាត់ជិតលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ដែលបានទទួលការពិនិត្យព្យាបាលទាន់ពេល ។
- ចំពោះការអភិវឌ្ឍន៍ថ្នាក់សង្កាត់ ភូមិ បានអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួន តាមគោលការណ៍រដ្ឋបាលឯកភាព ដែលមានក្រុមប្រឹក្សាក្រុង សង្កាត់ជាតំណាងបានធ្វើការពង្រឹងការគ្រប់គ្រងប្រជាពលរដ្ឋ ការផ្តល់សេវារដ្ឋបាល ការបង្កើនជីវភាពរស់នៅប្រជាពលរដ្ឋប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរ បន្ថែមមួយកម្រិតថែមទៀត ។
- ចំពោះសភាពការណ៍ សន្តិសុខសណ្តាប់ធ្នាប់យើងបានយកចិត្តទុកដាក់អនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពដោយធ្វើការពង្រឹងកម្លាំងប្រជាការពារប្រចាំការតាមគោលដៅដែលមានកម្លាំងនគរបាល ប៉ុស្តិ៍ជាបង្អែក និងពង្រឹងសមត្ថភាពជំនាញអនុវត្តនូវវិធានការបង្ការ បង្ក្រាបបានទាន់ពេលបានធ្វើឲ្យសភាពការណ៍សន្តិភាពល្អ មិនបង្កការភ័យខ្លាច ដល់ការរស់នៅ ការប្រកបមុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឡើយ ។

ជារួមការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានផ្សេងៗ ដែលដាក់ចេញពីថ្នាក់ជាតិ រដ្ឋបាលខេត្ត និងផ្អែកតាមលក្ខណៈភូមិសាស្ត្រជាក់ស្តែង ក្រុងបាត់ដំបង សម្រេចទៅតាមផែនការបានយ៉ាងល្អប្រសើរព្រមទាំងដាក់ចេញនូវទិសដៅផែនការសកម្មភាពជាក់ស្តែងអនុវត្តជាបន្តបន្ទាប់ ដើម្បីធ្វើយ៉ាងណាអភិវឌ្ឍន៍ក្រុងឲ្យមានការរីកចម្រើន ។

របាយការណ៍ប្រចាំឆ្នាំ ២០២២ នេះ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី៤៣នាថ្ងៃសុក្រ ៧ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ។

ថ្ងៃ.....................ខែ.............ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

បាត់ដំបង.ថ្ងៃទី........ ខែ............ ឆ្នាំ ២០២២

**អភិបាលក្រុង**

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖ ផែនទីខេត្តបាត់ដំបង និងរដ្ឋបាលក្រុងបាត់ដំបង






# ផែនទីក្រុងបាត់ដំបង



# ឧបសម្ព័ន្ធទី២៖ តំបន់សេដ្ឋកិច្ច



ទីតាំង៖ ផ្សារធំថ្មី (ផ្សារណាត់)



ទីតាំង៖ រោងម៉ាស៊ីនកិនស្រូវ



ទីតាំង៖ រោងចក្រស៊ីម៉ង់ត៍




ទីតាំង៖ សណ្ឋាគារ




ទីតាំង៖ ភោជនីយដ្ឋានជាប់ដងស្ទឹងសង្កែ



ទីតាំង៖ បុរីភូពុយ

# ឧបសម្ព័ន្ធទី៣៖ តំបន់ទេសចរណ៍



ទីតាំង៖ រូបសំណាកតាក្រញូង



ទីតាំង៖ ព្រះវិហារវត្តពោធិ៍វាល



ទីតាំង៖ សំណង់អគារអភិរក្ស



ទីតាំង៖ សារមន្ទីរប្រវត្តិសាស្ត្រខេត្ត




ទីតាំង៖ សារមន្ទីរខេត្ត



ទីតាំង៖ ស្ពានរថភ្លើង

## ឧបសម្ព័ន្ធទី៤៖ ផែនទីអភិវឌ្ឍន៍ខេត្តបាត់ដំបង២០៣០




## ឧបសម្ព័ន្ធទី៥៖ ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង២០៣០



# ឧបសម្ព័ន្ធទី៦៖ សមិទ្ធផលនៃវឌ្ឍនភាពការងារកសិកម្ម



កសិកម្ម៖ បានអញ្ជើញចុះពិនិត្យ និងស្វែងយល់ការផលិតពូជស្រូវ នៅក្នុងភូមិសាស្ត្រអាងពោធិ៍ ដែលស្ថិតនៅ សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង



សកម្មភាពការប្រមូលផលិតផលស្រូវ



ការចិញ្ចឹមសត្វរបស់ប្រជាជនក្រុងបាត់ដំបងតាមសង្កាត់




សិប្បកម្មកែច្នៃអាហារមួយចំនួនក្នុងក្រុងបាត់ដំបង

# ឧបសម្ព័ន្ធទី៧៖ គម្រោងការអភិវឌ្ឍជាទីក្រុងវៃឆ្លាត












គម្រោង សួនសម្តេចក្រឡាហោមវិមានឯករាជ្យ
សិក្សាប្លង់ និង សាងសង់ដោយ:







## គម្រោងផ្សាររាត្រី TO Park ក្រុងបាត់ដំបង



# ឧបសម្ព័ន្ធទី៨៖ ការអភិវឌ្ឍប្រព័ន្ធផ្លូវ និងសកម្មភាពដំណើរការការងារ



កំណាត់ផ្លូវជាតិលេខ៥ ពីបាត់ដំបង-សិរីសោភ័ណសម្រេចការសាងសង់ប្រវែងជិត ៨៥គីឡូម៉ែត្រដាក់ប្រើប្រាស់ ឆ្នាំ២០២២



ផ្លូវក្រវ៉ាត់ក្រុងបាត់ដំបង




ផ្លូវលេខ២ និងច្រកផ្សារណាត់ចេញពីវត្តពិភិទ្ធក្រុងបាត់ដំបង




ការចាក់កៅស៊ូនៅរង្វង់មូលតាក្រញូង




ការធ្វើប្រព័ន្ធបេតុងតាមសង្កាត់ក្នុងក្រុងបាត់ដំបង



ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ (ទំនប់ទឹក) ការរៀបចំប្រព័ន្ធសាធារណៈក្នុងក្រុងបាត់ដំបង



ការធ្វើប្រព័ន្ធរំដោះទឹក




ការរៀបចំសួនច្បារតាមដងស្ទឹងសង្កែ




ការរុះរើផ្លាយយីហោ និងការកែប្រែជាថ្មី




ការរៀបចំសំយ៉ាបផ្ទះ និងស្លាកយីហោ



កន្លែងកែច្នៃសំរាម និងកន្លែងចាក់សំរាម